**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Èconomiques

Royal University Of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិរបស់ជនល្មើស និងទណ្ឌិតនៅក្នុងពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ រហូតដល់ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ក. ខូច ស្រីគីន**

**ក. ចិន ឡាយអ៊ី**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **អំណះអំណាង**

យើងខ្ញុំឈ្មោះ **ខូច ស្រីគីន** និងឈ្មោះ **ចិន ឡាយអ៊ី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រុម L4A4 ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាបានជ្រើសរើសប្រធានបទស្តីពី "**សិទ្ធិរបស់ជនល្មើស និងទណ្ឌិតនៅក្នុងពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា**" ពិតប្រាកដមែន។

យើងខ្ញុំសូមធានាអះអាងថា ស្នាដៃមួយនេះ ពិតជាបានរៀបចំចងក្រង និងធ្វើការសិក្សាស្រាវជ្រាវដោយដោយផ្ទាល់ពិតប្រាកដមែន ដោយរួមទាំងចំណេះដឹងដែលយើងខ្ញុំបានទទួលនាពេលកន្លងមកក្នុងឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ពីលោក លោកស្រីសាស្ត្រចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

បន្ថែមពីនេះ យើងខ្ញុំសូមធានាអះអាងផងដែរថាស្នាដៃ នៃការស្រាវជ្រាវនេះ យើងខ្ញុំមិនបានចម្លងចេញពីស្នាដៃរបស់អ្នកដទៃឡើយ វៀរលែងតែមានកំណត់ច្បាស់លាស់ ដែលមានចង្អុរបង្ហាញក្នុងអត្ថបទ នៃចំណុចនីមួយៗក្នុងប្រភពឯកសារ និងសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំនិស្សិតឆ្នាំទី៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានរាយនាមដូចខាងក្រោម៖

**១. កញ្ញា ខូច ស្រីគីន**

**២.កញ្ញា ចិន ឡាយអ៊ី**

យើងខ្ញុំសូមលំអោនកាយគោរពជូនពរ ព្រមទាំងសម្តែងនូវកត្តញ្ញូតាធម៌ និងគុណូបការៈដ៏ធំធេងក្រៃលែងចំពោះ៖

លោកឪពុក និងអ្នកម្តាយ របស់យើងខ្ញុំទាំងពីរនាក់ ដែលបានផ្តល់ឪកាសឲ្យយើងខ្ញុំបានស្គាល់ពិភពលោកដ៏ស្រស់ស្អាតមួយនេះ មិនត្រឹមតែប៉ុណ្ណោះលោកទាំងទ្វេរបានចិញ្ចឹមបីបាច់ថែរក្សាយ៉ាងកក់ក្តៅ អប់រំ និងផ្តល់ដំបូន្មានយ៉ាងច្រើនអនេកទើបរូបយើងខ្ញុំមានថ្ងៃនេះ។

ស្របពេលជាមួយគ្នានេះដែរ រយៈពេល៤ឆ្នាំកន្លងមក ចាប់តាំងពីថ្នាក់ឆ្នាំមូលដ្ឋាន រហូតដល់ថ្នាក់បរិញ្ញាបត្រយើងខ្ញុំសូម ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចូលរួមបណ្តុះបណ្តាល បង្ហាត់បង្រៀន អប់រំ ណែនាំ ផ្តល់ឱវាទល្អៗដល់រូបយើងខ្ញុំ ឲ្យបានក្លាយជាធនធានមនុស្ស និងជាសរសរទ្រូងនៃប្រទេសជាតិនាពេលអនាគត។

ជាពិសេស លោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាសាស្ត្រាចារ្យដឹងនាំ ផ្តល់នូវទស្សនៈទានថ្មីៗជុំវិញប្រធានបទ ក្នុងការស្រាវជ្រាវមួយនេះ រួមទាំងជួយកែលម្អចំណុចខ្វះខាត ត្រួសត្រាយព្រមទាំងផ្តល់មតិរិះគន់ដើម្បីស្ថាបនាសព្វបែបយ៉ាងក៏ដើម្បីឲ្យកិច្ចការនេះសម្រេចបានល្អប្រសើរឡើង។

យើងខ្ញុំសូមឧទ្ទិសនូវស្នាដៃនេះ ជូនដល់បុព្វការីជន បុព្វបុរស វីរជនស្នេហាជាតិ យុទ្ធជន យុទ្ធនារី និងនិស្សិតបញ្ញាវន្តខ្មែរគ្រប់រូបដែលបានពលីជីវិតដើម្បីបុព្វហេតុជាតិ។

ជាកិច្ចចុងក្រោយ យើងខ្ញុំមានតែលើកម្រាមដៃ១០ ប្រណម្យ បួងសួង សូមឲ្យវត្ថុស័ក្តសិទ្ធិក្នុងលោកតាមជួយបីបាច់ថែរក្សាលោកអ្នកមានគុណព្រមទាំងពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លាឃ្លាតឡើយ។

# អារម្ភកថា

ប្រជាពលរដ្ឋខ្មែរ គ្រប់រូបមានសិទ្ធិរៀងៗខ្លួនចាប់តាំងពីចាប់កំណើតមកម្ល៉េះ។ ប៉ុន្តែរាល់សិទ្ធិទាំងអស់នោះ មិនបានអនុវត្តពេញលេញឡើយ ពោលគឺបុគ្គលគ្រប់រូបទទួលបានសិទ្ធិ និងករណីកិច្ចយ៉ាងពេញពេញលេញ នៅពេលដែលបុគ្គលនោះ ឈានដល់វ័យនីតិភាព ដែលអាចទទួលខុសត្រូវចំពោះមុខច្បាប់បានដោយខ្លួនឯង។ បន្ថែមពីនេះនៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏បានចែងអំពីសិទ្ធិមួយចំនួនដូចជា សេរីភាពក្នុងការសម្តែងមតិ យោបល់ សិទ្ធិក្នុងការដើរហើរ សិទ្ធិបុគ្គលឯកជន សិទ្ធិក្នុងការទទួលបានការជំនុំជម្រះចំពោះមុខច្បាប់ ជាអាទិ៍ ក៏ប៉ុន្តែសិទ្ធិទាំងអស់នេះត្រូវបានស្ថិតនៅក្រោមបទបញ្ញត្តិច្បាប់ជាធរមាន។ ដោយឡែក ទោះបីជា ច្បាប់បានផ្តល់ឲ្យបុគ្គលគ្រប់រូបនូវសិទ្ធិសេរីភាពយ៉ាងណាក៏ដោយ ក៏នៅក្នុងជីវភាពរស់នៅ មនុស្សតែងតែមានការបំពារបំពានចំពោះគ្នាទៅវិញទៅមកជាក់ជាមិនខានឡើយ។ ហើយបុគ្គលខ្លះបំពារបំពានចំពោះអ្នកដទៃត្រឹមកម្រិតស្រាល នៃទោសត្រឹមតែពិន័យជាប្រាក់ និងការស្តីបន្ទោសពីស្ថាប័នមានសមត្ថកិច្ចតែប៉ុណ្ណោះ ពោលគឺត្រឹមជាបទល្មើសលហុ ប៉ុន្តែបុគ្គលខ្លះទៀតប្រព្រឹត្តបទល្មើស ធ្ងន់ធ្ងររហូតឈានទៅដល់ការជាប់ពន្ធនាគារទៀតផង។ បានសេចក្តីថា ច្បាប់ចែងឡើងដើម្បីការពារជនគ្រប់រូបទោះបីជាបុគ្គលនោះជាជនល្មើស ឬជាជនរងគ្រោះក៏ដោយ។ ពិតប្រាកដណាស់ថាមនុស្សមួយចំនួនធំបានដឹងតែអំពីសិទ្ធិរបស់ខ្លួននៅពេលមិនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយប៉ុណ្ណោះ ប៉ុន្តែពួកគេមិនបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួននៅពេលដែលប្រព្រឹត្តបទល្មើសឡើយ។ ជាងនេះទៅទៀត បើទោះបីជាជនជាប់ឃុំ ឬទណ្ឌិត ត្រូវបានបាត់បង់សេរីភាពមួយចំនួនផ្ទាល់ខ្លួននៅក្នុងពេលអនុវត្តទោសក៏ដោយ ក៏ពួកគេនៅតែមានសិទ្ធិក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេផងដែរ។

អាស្រ័យហេតុនេះ ទើបយើងខ្ញុំ បានជ្រើសរើសយកប្រធានបទស្តីពី "**សិទ្ធិរបស់ជនល្មើស និង ទណ្ឌិតនៅក្នុងពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា**" មកធ្វើការស្រាវជាវ និងធ្វើការពន្យល់អំពីសិទ្ធិរបស់ជនល្មើសនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់សិទ្ធិរបស់ទណ្ឌិត ដែលកំពុងតែអនុវត្តទោសនៅបណ្តាពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា តាមអំណាចសាលក្រម ឬសាលដីការជាស្ថាពររបស់តុលាការ។

យើងខ្ញុំសូមធ្វើការអភ័យទោសរាល់កំហុស ខុសឆ្គងទោះដោយចេតនាក្តី ឬអចេតនាក្តី ដែលមាននៅក្នុងស្នាដៃមួយនេះនិងសូមធ្វើការគោរពជូនពរចំពោះអ្នកសិក្សាគ្រប់រូបឲ្យជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ.................................. ខែ..............ឆ្នាំ........ ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ..............ឆ្នាំ២០២១

# មាតិកា

**ទំព័រ**

**វាយក្យសព្ទ**....................iv

## សេចក្ដីផ្ដើម

១. លំនាំ នៃការស្រាវជ្រាវ....................០១
២. ចំណោទបញ្ហា និងការស្រាវជ្រាវ....................០២
៣. គោលបំណងនៃការស្រាវជ្រាវ....................០២
៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ....................០២
៥. វិធីសាស្ត្រស្រាវជ្រាវ....................០២
៦. សារៈប្រយោជន៍ នៃការស្រាវជ្រាវ....................០៣
៧. រចនាសម្ព័ន្ធស្រាវជ្រាវ....................០៣

## ជំពូកទី១

## សញ្ញាណទូទៅរបស់ជនល្មើស និងទណ្ឌិត

**ផ្នែកទី១៖ សញ្ញាណទូទៅ**....................០៥
**១.១. គោលបំណង នៃការបង្កើតច្បាប់**....................០៥
**១.២. និយមន័យ**....................០៦
១.២.១. ជនសង្ស័យ....................០៦
១.២.២. ជនល្មើស....................០៦
១.២.៣. ជនត្រូវចោទ....................០៧
១.២.៤. ជនជាប់ចោទ....................០៧
១.២.៥. ពិរុទ្ធជន....................០៧
១.២.៦. ទណ្ឌិត....................០៧
**ផ្នែកទី២៖ សិទ្ធិ និងករណីកិច្ចក្នុងដំណាក់កាលនីមួយៗ**....................០៧
**២.១. ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌**....................០៧
ក. ករណីបទល្មើសជាក់ស្ដែង....................០៧
ក.២.១. សិទ្ធិរបស់ជនល្មើស ជាអនីតិជន....................០៧
ក.២.២. សិទ្ធិរបស់ជនល្មើស ជានីតិជន....................០៩
ខ. ករណីបទល្មើសមិនជាក់ស្ដែង....................១១

**២.២. ដំណាក់កាលអយ្យការ**.....១២
២.២.១. សិទ្ធិរបស់ជនត្រូវចោទ ជាអនីតិជន.....១២
២.២.២. សិទ្ធិរបស់ជនត្រូវចោទ ជានីតិជន.....១៣
**២.៣. ដំណាក់ចៅក្រមស៊ើបសួរ**.....១៣
២.៣.១. សិទ្ធិរបស់ជនត្រូវចោទ ជាអនីតិជន.....១៤
២.៣.២. សិទ្ធិរបស់ជនត្រូវចោទ ជានីតិជន.....១៥
**២.៤. ដំណាក់កាលជំនុំជម្រះ**.....១៦
២.៤.១. សិទ្ធិរបស់ជនជាប់ចោទ ជាអនីតិជន.....១៧
២.៤.២. សិទ្ធិរបស់ជនជាប់ចោទ ជានីតិជន.....១៨

## ជំពូកទី២

## របប នៃការប្រកាសទោស

**ផ្នែកទី១៖ គោលការណ៍ឯកត្តកម្ម នៃទោស**.....១៩
១.១. ការប្រកាសមូលទោស.....១៩
១.២. ការប្រកាសទោសជំនួស.....១៩
១.៣. ការប្រកាសទោសបន្ថែម លើមូលទោស.....២០
**ផ្នែកទី២៖ ការប្រកាសទោសការងារសហគមន៍**.....២០
២.១. ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍.....២០
២.២. បែបបទ នៃការអនុវត្តទោសសហគមន៍.....២១
**ផ្នែកទី៣៖ ការប្តឹងទាស់ និងបណ្តឹងឧបាស្រ័យ**.....២១
៣.១. បណ្តឹងទាស់.....២១
៣.២. បណ្តឹងឧទ្ធរណ៍.....២២
៣.៣. បណ្តឹងសាទុក្ខ.....២៤

## ជំពូកទី៣

## សិទ្ធិរបស់ទណ្ឌិតក្នុងអំឡុងពេលអនុវត្តទោស

**ផ្នែកទី១៖ សិទ្ធិរបស់ទណ្ឌិតជាទូទៅក្នុងអំឡុងពេលអនុវត្តទោស**.....២៥
១.១. ការទទួលបាននូវសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ចាំបាច់.....២៦
១.២. ការទទួលបានរបបអាហារ និងទឹក.....២៦
១.៣. សិទ្ធិទទួលបានពត៌មាន និង ស្វ័យសិក្សា.....២៧

១.៤. សិទ្ធិខាងជំនឿសាសនា............................................................................................២៧
១.៥. ការទទួលបានសេវាពេទ្យ............................................................................................២៨
១.៦. ការទទួលបានការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន............................................................................២៨
១.៧. ការទទួលបានរបបជីវភាព............................................................................................២៩
**ផ្នែកទី២៖ សិទ្ធិរបស់ទណ្ឌិតជាពិសេសក្នុងអំឡុងពេលអនុវត្តទោស**.....................................២៩
២.១. សិទ្ធិរបស់ទណ្ឌិតជាស្ត្រី............................................................................................២៩
២.២. សិទ្ធិជាមូលដ្ឋានរបស់ទណ្ឌិតជាអនីតិជន............................................................................៣០
២.៣. សិទ្ធិរបស់ទណ្ឌិជាជនបរទេស............................................................................................៣២
**ផ្នែកទី៣៖ សិទ្ធិទទួលបានការលើកលែងទោស ឬការបន្ធូរបន្ថយទោស**.....................................៣២
៣.១. សិទ្ធិទទួលបានការលើកលែង ឬការបន្ធូរបន្ថយទោសក្រោមច្បាប់អន្តរជាតិ.....................................៣៣
៣.២. សិទ្ធិទទួលបានការលើកលែង ឬការបន្ធូរបន្ថយទោសក្រោមច្បាប់ជាតិ.........................................៣៤
**សេចក្តីសន្និដ្ឋាន**............................................................................................៣៦
**អនុសាសន៍**............................................................................................៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# វាក្យសព្ទ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអត្ថបទនេះ មាននិយមន័យដូចតទៅ៖

**នីតិសម្បទា៖** សំដៅដល់ការព្រម សមប្រកប បរិបូរណ៍ដោយច្បាប់ ឬការមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់។

**ពន្ធនាគារ៖**សំដៅទៅដល់ទីកន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមរយៈលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផងដែរ។

**ជនជាប់ឃុំ៖** សំដៅទៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិត ដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុកាលារ។

**មន្ត្រីពន្ធនាគារ៖** សំដៅដល់មន្ត្រីដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ។

**មន្ត្រីពេទ្យពន្ធនាគារ៖**សំដៅដល់មន្ត្រីដែលត្រូវបានតែងតាំងឲ្យផ្តល់សេវាថែទាំសុខភាពជនជាប់ឃុំក្នុងពន្ធនាគារ និងត្រូវបានទទួលស្គាល់ ឬបានចុះបញ្ជីជាគ្រូពេទ្យ ឬមន្ត្រីពេទ្យនៅក្រសួងសុខាភិបាល។

**អ្នកសួរសុខទុក្ខ៖** សំដៅដល់ជនដែលត្រូវបានអនុញ្ញាតឲ្យចូលក្នុងពន្ធនាគារ ដើម្បីសួរសុខទុក្ខ ឬផ្តល់ជំនួយដល់ជនជាប់ឃុំ។

**អ្នកសួរសុខទុក្ខផ្លូវការ៖** សំដៅដល់មន្ត្រីសាធារណៈ ឬតំណាងបុគ្គលមកពីអង្គការនានា ដែលទទួលបានការអនុញ្ញាតឲ្យទៅធ្វើទស្សនកិច្ចឃ្លាំមើលតាមពន្ធនាគារនានា ឬផ្តល់ជំនួយដល់ជនជាប់ឃុំ។

**ទារុណកម្ម៖** អំពើកាច អំពើអាក្រក់ អំពើសាហាវយង់ឃ្នង។

**ទណ្ឌកម្ម៖** ការធ្វើទោសផ្ទាលតាមដំណើរធ្វើខុសនឹងវិន័យបញ្ញត្តិ។

**អនីតិជន៖** ជនដែលមានអាយុក្រោម ១៨ឆ្នាំ។

**ទទ្បីករណ៍៖**ភាពមិនច្បាប់លាស់។

**អសារឥតការ៖** ចាត់ទុកថាគ្មានន័យ។

**សមាហរណកម្ម៖** ដំណើរការ នៃការញ្ចូលគ្នាការចូលរួមជាមួយគ្នា។

**អ្នកតំណាងដែលច្បាប់បានកំណត់៖** មានដូចជា អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំ នៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា បានក្លាយជារដ្ឋភាគី នៃភាគីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ តួយ៉ាង នៅក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា បានធានាការពារអនុសញ្ញានេះ ថាជាផ្នែកមួយនៃច្បាប់របស់ខ្លួន។ ជាក់ស្តែង យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិអំពីការធានារ៉ាប់រងមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាម្នាក់ឡើយ ពោលគឺច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ភេទ ឬនិន្នាការនយោបាយឡើយ។ ជានេះទៅទៀត បើក្រឡេកទៅមើលសិទ្ធិ និងសេរីភាពរបស់ជនប្រព្រឹត្តបទល្មើស នៅសម័យអាណាចក្រភ្នំ (ឆ្នាំ៥០-៥៥០) កាលណាមានជនជាប់ចោទ គេឲ្យជននោះអត់បាយ៣ថ្ងៃ រួចគេតម្រូវឲ្យលូកយកវត្ថុផ្សេងៗពីទឹកដាំពុះ ឬកាន់ពូថៅ ឬច្រវ៉ាក់ដុតក្រហម កាន់ដើរ៧ជំហាន បើមានកំហុសមែន ដៃរបស់ជននោះត្រូវរលាយរលួយ ផ្ទុយទៅវិញបើគ្មានកំហុស គឺគ្មានហ្មងសៅឡើយ។ ក្នុងករណីបើមានកំហុសស្រាល គេពិន័យ ឬដាក់ទណ្ឌកម្មធម្មតាប៉ុណ្ណោះ ប៉ុន្តែដោយឡែក បើមានកំហុសធ្ងន់វិញ គេយកជនដែលមានទោសនោះ បោះឲ្យក្រពើស៊ី ឬសត្វសាហាវស៊ីតែម្តង ហើយនៅសម័យនោះ គ្មានគុកទេ ។ រហូតមកដល់ក្រោយសម័យអង្គរ (សម័យចតុមុខដំបូង សម័យលង្វែក សម័យឧដុង្គ) ទើបស្ថាប័នជម្រះក្តីមានលក្ខណៈប្រសើរជាងមុន ដោយអនុវត្តន៍ទៅតាមទម្រង់ព្រះរាជក្រម ដែលបានកំណត់បទល្មើស ហើយក្រមទាំងនោះរួមមាន ក្រមចោរ ក្រមទោសភរិយា ក្រមបំណុល ក្រមសាក្សីពិសោធន៍ ជាដើម។ ម្យ៉ាងវិញទៀត នៅសម័យនោះ ជនសង្ស័យមានសិទ្ធិក្នុងការដេញដោលរកសេចក្តីពិតនៅចំពោះមុខអង្គព្រះមហាក្សត្រ។ រហូតមកដល់ស្ថាប័នខ្មែរសម័យទំនើប ទើបបង្កើនឲ្យមានការរៀបចំប្រសើរជាងមុន នៃជីវភាពរបស់ពួកទណ្ឌិត[១]។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងរជ្ជកាល ព្រះបាទស៊ីសុវត្ថិទ្រង់បានចេញនូវព្រះរាជបញ្ញត្តិប្រកាសឲ្យប្រើច្បាប់មួយចំនួន ដោយក្នុងនោះ មានបញ្ញត្តិឲ្យលុបចោលនូវការធ្វើទុក្ខបុកម្នេញលើរាងកាយនៃជនមានទោស និងជនជាប់ចោទ (ឆ្នាំ១៩០៤)។

ដោយឡែកចាប់តាំងពីឆ្នាំ១៩៧៥-១៩៧៩ ដែលជាសម័យកាលរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបប៉ុលពត ដោយញ៉ាំងឲ្យការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរមានការរឹតត្បិតសិទ្ធិសេរីភាពយ៉ាងខ្លាំង ហើយអ្វីកាន់តែសង្វេក និងអមនុស្សធម៌នោះគឺ ការធ្វើទុក្ខបុកម្នេញ ដោយបានវាយដំជាន់ធាត់យ៉ាងសាហាវយង់ឃ្នងមកលើប្រជាជនខ្មែរ ជាពិសេសគឺការកាត់ទោសប្រហារជីវិតយកទៅវាយសម្លាប់ចោលការបាញ់សម្លាប់ចោល ដែលជាអំពើព្រៃផ្សៃ ឬ អមនុស្សធម៌ផ្ទុយទៅនឹងគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ។

(១) កំណែទម្រង់ព្រះរាជបញ្ញត្តិ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧ គ្រង់បញ្ញត្តិទាក់ទងនឹងតុលាការ(ជីវភាពរបស់ពួកទណ្ឌិត ត្រូវបានរៀបចំឲ្យបានប្រសើរជាងមុន)។

## ២ ចំណោតបញ្ហា នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "សិទ្ធិរបស់ជនល្មើស និងទណ្ឌិតនៅក្នុងពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា" គឺផ្តោតសំខាន់ទៅលើចំណោតបញ្ហាចំនួនគឺ០៤៖

១/ហេតុអ្វីបានជាជនល្មើសនិងទណ្ឌិតនៅតែមានសិទ្ធិមួយចំនួនបើទោះបីជាពួកគេបានប្រព្រឹត្តអំពើល្មើសច្បាប់ក៏ដោយ?

២/តើជនល្មើស និងទណ្ឌិតត្រូវទទួលបានសិទ្ធិអ្វីខ្លះនៅក្នុងអំឡុងពេលសាលាជម្រះក្តីកំពុងអនុវត្តនីតិវិធីរបស់ខ្លួន?

៣/តើសិទ្ធិរបស់ជនល្មើស និងទណ្ឌិត ត្រូវបានទទួលតាមរូបភាពបែបណាខ្លះ?

៤/តើមានភាពចាំបាច់ដែរឬទេ ដែលជនប្រព្រឹត្តអំពើផ្ទុយច្បាប់បានកំណត់ យល់ដឹងនូវសិទ្ធិសេរីភាពរបស់ខ្លួនតាមគោលការណ៍របស់អង្គការសិទ្ធិមនុស្ស?

## ៣ គោលបំណងនៃ ការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះរួមមាន៖

១/ ចែករំលែកអំពីសិទ្ធិរបស់ជនជាប់ឃុំ និងទណ្ឌិត នៅក្នុងអំឡុងពេលដំណើរការនីតិវិធី។

២/ជម្រុញឲ្យមានការគោរពសិទ្ធិគ្នាទៅវិញទៅមកតាមគោលការណ៍សិទ្ធិមនុស្ស នៅក្នុងពន្ធនាគារ។

៣/ លើកកម្ពស់អំពីសិទ្ធិមនុស្សជាមូលដ្ឋាន នៅក្នុងពន្ធនាគារ។

ដើម្បីសម្រេចនូវគោលបំណងទាំងនេះ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដោយផ្អែកលើអត្ថបទស្រាវជ្រាវបរទេស អត្ថបទជាតិ គេហទំព័រសំខាន់ៗ ការសង្កេតផ្ទាល់ខ្លួន បទពិសោធន៍ អ្នកអនុវត្តច្បាប់ និងច្បាប់កម្ពុជា។

## ៤ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះ យើងខ្ញុំនឹងលើកយកសិទ្ធិរបស់បុគ្គលមកធ្វើជាមូលដ្ឋានសំខាន់ជាងគេ ក៏ប៉ុន្តែការសិក្សាស្រាវជ្រាវអំពីសិទ្ធិបុគ្គលទាំងមូលមានវិសាលភាពធំទូលាយពេក ហេតុដូច្នេះ ការស្រាវជ្រាវនេះនឹងផ្តោតសំខាន់ទៅលើសិទ្ធិរបស់ជនជាប់ឃុំ រហូតមកដល់ សិទ្ធិទណ្ឌិត ដែលកំពុងតែអនុវត្តទោសនៅក្នុងពន្ធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ៥ វិធីសាស្ត្រស្រាវជ្រាវ

ក. ប្រភពឯកសារសំខាន់ៗមាន៖

- គេហទំព័ររបស់ ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា
- គេហទំព័រ បណ្ណាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- គេហទំព័ររបស់អង្គការតាមដានទិន្នន័យអ្នកជាប់ពន្ធនាគារទូទាំងពិភពលោក។
- បទពិសោធន៍ផ្ទាល់ខ្លួន។

ខ. វិធីសាស្រ្តប្រមូលទិន្នន័យ

- ការអានឯកសារជាតិ បរទេស ជារបាយការណ៍។
- ការស្រាវជ្រាវចេញឯកសារពីគេហទំព័រ និងឯកសារអេឡិចត្រូនិចដែលអាចទុកចិត្តបាន។
- ការសម្ភាសន៏ដោយផ្ទាល់ពីសំណាក់អ្នកអនុវត្តច្បាប់។
- ការសង្កេតផ្ទាល់ខ្លួន។

## ៦. សារប្រយោជន៍ នៃការស្រាវជ្រាវ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងផ្តល់សារប្រយោជន៍ជូនជាគុណតម្លៃ និងវិភាគទានសម្រាប់អ្នកសិក្សាជំនាន់ក្រោយ និងមិត្តអ្នកអានទាំងឡាយ ជាពិសេសសាធារណជនគ្រប់ស្រទាប់ វណ្ណៈ ក្នុងនាមជាម្ចាស់សិទ្ធិនៃខ្លួនឯង ដែលជាក្រុមគោលដៅសំខាន់បំផុតនៃសារណាស្រាវជ្រាវមួយនេះចង់ទៅដល់ ដើម្បីបានជាការស្វែងយល់ផ្សាភ្ជាប់ជាមួយការអនុវត្តសិទ្ធិនេះនៅក្នុងពន្ធនាគារ ក្នុងការបង្កើនការគោរពសិទ្ធិមនុស្សនៅកម្ពុជាឲ្យបានប្រសើរថែមមួយកម្រិតទៀត។

## ៧. រចនាសម្ព័ន្ធ

នាពេលនេះ ដើម្បីពិនិត្យថា សិទ្ធិរបស់ជនល្មើស និងទណ្ឌិតនៅក្នុងពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា យើងត្រូវពិនិត្យលើដំណើរការវិវត្តសិទ្ធិជាទូទៅ ដែលជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស ដូចមានចែងក្នុងកតិកាសញ្ញាស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ និងរដ្ឋធម្មនុញ្ញជាអាទិ៍។

រចនាសម្ព័ន្ធខ្លឹមសារនៃសារណាស្រាវជ្រាវនេះ ក្រៅពីមាតិកា សេចក្តីថ្លែងអំណរគុណ អំណះអំណាង អារម្ភកថា និងឧបសម្ព័ន្ធ រចនាសម្ព័ន្ធត្រូវបានបែងជាដូចខាងក្រោម៖

**សេចក្តីផ្តើម៖** លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង វិសាលភាព និងដែនកំណត់ សារប្រយោជន៍ និងរចនាសម្ព័ន្ធ នៃសារណាស្រាវជ្រាវនេះ។

**ជំពូកទី១៖ សញ្ញាណទូទៅរបស់ជនល្មើស និងទណ្ឌិត**

ជំពូកនេះនិងឆ្លុះបញ្ចាំងយកនូវទិដ្ឋភាពនៃគោលបំណងក្នុងការបង្កើតពន្ធនាគារអំពីសិទ្ធិ និងករណីកិច្ចនៅក្នុងដំណាក់កាលនីមួយៗនៃនីតិវិធីរបស់សាលាជម្រះក្តី របស់ជនប្រព្រឹត្តបទល្មើសជានីតិជន អនីតិជន ដោយក្នុងនោះរួមមាន ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ។

**ជំពូកទី២៖ របប នៃការប្រកាសទោស**

ដោយឡែក ជំពូកទី២នេះ នឹងធ្វើការស្រាវជ្រាវទៅលើរបបនៃការប្រកាសទោស មុននឹងឈានទៅដល់ការអនុវត្តទោសទៅលើទណ្ឌិត។

**ជំពូកទី៣៖ សិទ្ធិរបស់ទណ្ឌិតក្នុងអំឡុងពេលអនុវត្តទោស**

បន្ទាប់ពីរបបនៃការប្រកាសទោស ឬបន្ទាប់ពីសាលក្រម ឬសាលដីរបស់សាលាជម្រះក្ដីបានចូលជាស្ថាពរហើយនោះ គឺទណ្ឌិតគ្រប់រូបត្រូវបានដកហូតសិទ្ធិរបស់ខ្លួនមួយចំនួន តាមរយៈការអនុវត្តទោសទណ្ឌដោយអំណាចសាលក្រម ឬសាលដីកាចូលជាស្ថាពរនោះ។ ប៉ុន្តែដោយឡែក បន្ទាប់ពីមានការដកហូតសិទ្ធិសេរីភាពរបស់ជនល្មើស និងទណ្ឌិតមួយផ្នែកធំក៏ដោយ ក៏ពួកគេនៅតែមានសិទ្ធិរស់នៅតាមរយៈលក្ខខណ្ឌសង្គមជាទូទៅផងដែរ។ ជាពិសេស សិទ្ធិដែលទណ្ឌិតជាអនីតិជន និងជាស្ត្រីគួរតែទទួលបាននៅក្នុងអំឡុងពេលអនុវត្តទោសទណ្ឌនៅក្នុងពន្ធនាគារនេះផងដែរ។

# ជំពូកទី១

# សញ្ញាណាទូទៅរបស់ជនល្មើស និង ទណ្ឌិត

# ជំពូកទី១
# សញ្ញាណទូទៅរបស់ជនល្មើស និងទណ្ឌិត

## ផ្នែកទី១៖ សញ្ញាណទូទៅ

### ១.១. គោលបំណង នៃការបង្កើតច្បាប់

ផ្អែកតាមច្បាប់ស្តីពីពន្ធនាគារ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២។ ច្បាប់នេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់នេះមានគោលដៅដូចជា៖

- អប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និងទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី។
- គ្រប់គ្រងជនជាប់ឃុំឲ្យធានាបានសន្តិសុខ សុវត្ថិភាព សុខភាព និងមនុស្សធម៌ស្របតាមគោលការណ៍ច្បាប់អន្តរជាតិ និងវិធានរបស់អង្គការសហប្រជាជាតិ។ សម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធសេរីភាព។
- បណ្តុះបណ្តាលវិជ្ជាជីវៈនានាតាមតម្រូវការទីផ្សារបច្ចុប្បន្នដែលអាចផ្តល់ឲ្យជនជាប់ឃុំមានជំនាញយ៉ាងពិតប្រាកដ អាចប្រកបមុខរបរចិញ្ចឹមជីវិតនៅក្នុងសង្គមបាន(២)។
- បន្តការងារអប់រំផ្នែកសតិអារម្មណ៍ដល់ជនជាប់ឃុំជាប្រចាំ។
- ពង្រឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពិរុទ្ធជន និងទណ្ឌិត។
- បន្តសហប្រតិបត្តិការជាមួយស្ថាប័នអង្គភាព និងអង្គការអន្តរជាតិដែលពាក់ព័ន្ធឲ្យដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់ផ្នែកសិទ្ធិមនុស្ស ។

តាមប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារលេខ ២១៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៣ ប្រកាសនេះបង្កើតឡើង ក្នុងគោលបំណងដើម្បីផ្តល់សិទ្ធិអំណាចក្នុងការរៀបចំសន្តិសុខ របៀបរៀបរយក្នុងពន្ធនាគារ និងការគ្រប់គ្រងអ្នកទោសឲ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាពល្អក្នុងសង្គម។

(២) មាត្រា ៦៧ ច្បាប់ស្តីអំពីពន្ធនាគារ

ចំពោះប្រកាសនេះផងដែរត្រូវបានអនុវត្តចំពោះអ្នកទោស មន្ត្រីពន្ធនាគារគ្រប់រូបចំពោះប្រកាសនេះផងដែរត្រូវបានអនុវត្តចំពោះអ្នកទោស និងមន្ត្រីពន្ធនាគារគ្រប់រូបដោយមិនប្រកាន់ពូជសាសន៍ ភេទ ពណ៌ សម្បុរ ភាសា ទស្សនៈនយោបាយ សញ្ជាតិ សាសនា ស្ថានភាពសង្គម ភាពមានគភ៌ និងការអន់ថយផ្នែកកម្លាំងកាយ និងស្មារតី [៣]។

### ១.២. និយមន័យ

នៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "ជនជាប់ចោទណាក៏ដោយចាត់ទុកថាគ្មានទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ" ហេតុនេះហើយបានជាការតាក់តែងច្បាប់ដែលប្រើពាក្យ ជនសង្ស័យ ជនល្មើស ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន និងទណ្ឌិត គឺឲ្យស្របទៅនឹងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល [៤]។

#### ១.២.១. ជនសង្ស័យ

**ជនសង្ស័យ** ពាក្យនេះគឺប្រើសម្រាប់ហៅបុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស អាចជាចារី សហចារី អ្នកសមគំនិត និងអ្នកផ្តើមគំនិត។ **ចារី** សំដៅទៅលើបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលមានចែងទុក ចំពោះបទមជ្ឈិម (មាត្រា ២៥ នៃក្រមព្រហ្មទណ្ឌ)។ រីឯ **សហចារី** សំដៅទៅលើបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ (មាត្រា ២៦ នៃក្រមព្រហ្មទណ្ឌ)។ **អ្នកផ្តើមគំនិត** បុគ្គលណាដែល ជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា បង្កឲ្យមានបទឧក្រិដ្ឋ ឬមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន (មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ)។ **អ្នកសមគំនិត** ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រួលបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថមរបស់ខ្លួន។ នគរបាលយុត្តិធម៌ប្រើពាក្យនេះនៅក្នុងកំណត់ហេតុផ្សេងៗ ស្ថិតក្នុងការស៊ើបអង្កេតរបស់ខ្លួន ព្រោះដំណាក់កាលនេះ បុគ្គលនោះឋិតនៅក្នុងការសង្ស័យនៅឡើង ពុំទាន់មានការចោទប្រកាន់ពីអយ្យការទេ។

#### ១.២.២. ជនល្មើស

**ជនល្មើស** ន័យដូចពាក្យ **ជនសង្ស័យ** ដែរ គឺជាជនទាំងឡាយណាដែលប្រព្រឹត្តបទល្មើសដោយសកម្មក្តី ឬអកម្មក្តី ហើយដែលអំពើប្រព្រឹត្តនោះដោយផ្ទាល់ហៅថា **ចារី** ឬប្រព្រឹត្តដោយប្រយោលក្តីដែលបង្ករឲ្យមានព្យសនកម្មដល់សង្គម ហើយដែលច្បាប់ព្រហ្មទណ្ឌបានចែងរួចជាស្រេច។ ដោយលក្ខខណ្ឌ នៃជនល្មើសមានដូចជា៖

-ជាមនុស្ស (មិនមែនសត្វ)។

-កំពុងមានជីវិត (មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

-មានសមត្ថភាពទទួលខុសត្រូវ ដោយមានសតិសម្បជញ្ញៈល្អ។

-មានអាយុកំណត់តាមច្បាប់ព្រហ្មទណ្ឌ។

(៣) ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ

(៤) មាត្រា ៣៨ នៃរដ្ឋធម្មនុញ

**១.២.៣ ជនត្រូវចោទ**

**ជនត្រូវចោទ** គឺបុគ្គលដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។

**១.២.៤. ជនជាប់ចោទ**

**ជនជាប់ចោទ** អត្ថន័យ នៃពាក្យនេះ គឺជាបុគ្គលដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

**១.២.៥. ពិរុទ្ធជន**

**ពិរុទ្ធជន** គឺជាជនជាប់ចោទដែលត្រូវបានប្រកាសសាលក្រមនៅពេលសវនាកាជាសាធារណៈ។

**១.២.៦. ទណ្ឌិត**

**ទណ្ឌិត** គឺជាជនដែលកំពុងអនុវត្តទោសពន្ធនាគារតាមអំណាចសាលក្រម ឬសាលដីកាជាស្ថាពរ។

**ផ្នែកទី២៖ សិទ្ធិ និងករណីកិច្ចក្នុងដំណាក់កាលនីមួយៗ**

**២.១. ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌**

ក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌទាមទារនៅកិច្ចផ្សេងៗរបស់មន្ត្រីនគរបាលយុត្តិធម៌ ដូចជាការត្រួតពិនិត្យបទល្មើស និងស្រាវជ្រាវដើម្បីដាក់បន្ទុកនៃបទល្មើសទៅលើបុគ្គលម្នាក់ ឬច្រើននាក់ ដែលត្រូវធ្វើការកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់។ ការអន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិធម៌ អាចកើតឡើងយ៉ាងពិតប្រាកដ ក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ដើម្បីបើកការស៊ើបអង្កេតក្នុងករណីជាករណីបទល្មើសជាក់ស្តែងក្តី ឬ ករណីបទល្មើសមិនជាក់ស្តែងក្តី។ បន្ថែមពីនេះមន្ត្រីនគរបាលយុត្តិធម៌ គឺជាបុគ្គលត្រូវបានទទួលស្គាល់ដោយច្បាប់ ដែលជាមន្ត្រីនគរបាលយុត្តិធម៌ ឬនាយទាហាន នៃកងរាជអាវុធហត្ថ ចាប់ពីអនុសេនីយ៍ត្រីឡើងទៅ និងធ្លាប់បានបំពេញការងារក្នុងជួរក្រសួងមហាផ្ទៃ រយៈពេល ២ឆ្នាំ [៥]។ មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចក្នុងការត្រួតពិនិត្យបទល្មើសឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដើម្បីកំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុងតាង។

**ក. ករណីបទល្មើសជាក់ស្តែង**

ដើម្បីចាត់ទុកថាជាបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង កាលណាក្រោយពេលមានបទល្មើសរួចមក ជនដែលគេសង្ស័យ ត្រូវបានសារធារណៈជនស្រែកដេញប្រផាប់ចាប់ប្រភីង បុគ្គលនោះត្រូវបានគេរកឃើញមានវត្ថុ ឬមានស្នាកស្នាម ឬតម្រុយច្បាស់លាស់ហើយមានភាពស៊ីចង្វាក់ផ្សេងទៀតដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើស [៦]។

(៥) មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៦) មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

### ក.២.១. សិទ្ធិរបស់ជនល្មើសជាអនីតិជន

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានកម្រិតស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងច្បាស់លាស់ ហើយនីតិភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី១៨(ដប់ប្រាំបី)ឆ្នាំ ឡើងទៅ។ ដោយហេតុថា ជនដែលមានអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ គឺជាអនីតិជន ដូចច្នេះការយល់ដឹង និងការវិនិច្ឆ័យរបស់ពួកគេនៅមានកម្រិត។ បើអនីតិជនបានប្រព្រឹត្តបទល្មើសណាមួយ វិធានការអនុវត្តចំពោះអនីតិជនគឺមានតែ វិធានការអប់រំណែនាំ វិធានការពារ តែប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅក្នុងក្រមព្រហ្មទណ្ឌអនុវត្តទៅលើអនីតិជនអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំឡើងប្រសិនបើកាលៈទេស នៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ អនីតិជនអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ដល់១៨ (ដប់ប្រាំបី) ឆ្នាំ អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនបានប្រព្រឹត្ត បើកាលៈទេសនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ ប៉ុន្តែមុននិងឈានដល់ការបើកសវនាការ លើសំណុំរឿងអនីតិជនក៏ត្រូវឆ្លងកាត់ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ជាមុនសិនហើយក្នុងដំណាក់កាលនេះ។

ដូចនេះអនីតិជនមានសិទ្ធិដូចខាងក្រោមៈ

- មានសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី។
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង។
- សិទ្ធិរក្សាការសម្ងាត់ នៃជីវិតឯកជន។
- សិទ្ធិទទួលបានការឲ្យដំណឹងចំពោះការបទចោទប្រកាន់។
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់។
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការជ្រើសតាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុត នៃនីតិវិធី។
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តីប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន។
- សិទ្ធិបង្ហាញភស្តុងតាងបាន [៧]។
- សិទ្ធិទទួលជំនួយអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់។
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស។

បន្ទាប់ពីធ្វើកំណត់ហេតុស្តាប់ចម្លើយរួចហើយមុននឹងចុះហត្ថលេខា ឬផ្តិតមេដៃ ជនសង្ស័យអាចស្នើរសុំឲ្យមន្ត្រីនគរបាលអានកំណត់ហេតុឡើងវិញបាន ដូចមានចែងក្នុង នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ ២០០៧[៨]។

(៧)មាត្រា ២៦នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

(៨) មាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

កំណត់ហេតុឃាត់ខ្លួន ចំពោះជនសង្ស័យដែលប្រព្រឹត្តបទឧក្រិដ្ឋ ៣៦ (សាមសិបប្រាំមួយ) ម៉ោង បទមជ្ឈិម ២៤ (ម្ភៃបួន) ម៉ោង (**ករណីជនសង្ស័យជាអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់ជននេះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញ)** ជនសង្ស័យអនីតិជននេះមានសិទ្ធិដឹងអំពីមូលហេតុនៃការឃាត់ខ្លួននេះ ដោយផ្អែកលើមាត្រា ៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងរយៈពេល នៃការឃាត់ខ្លួន ជនសង្ស័យត្រូវបានទទួលបានសិទ្ធិសន្ទនាជាមួយ អ្នកតំណាងដែលច្បាប់បានកំណត់ និង មេធាវីការពារក្តី ដែល បានជ្រើសរើស ការជួបសន្ទនាឬទាក់ទងគ្នាមានរយៈពេល៣០ នាទី(៩)។ អនីតិជនមានសិទ្ធិមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមគំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ (១០)។

### ក.២.២ សិទ្ធិរបស់ជនល្មើសជានីតិជន

នីតិភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌចាប់ពីអាយុ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ ការប្រព្រឹត្តបទល្មើស គឺត្រូវបានច្បាប់ចាត់ទុកជាអំពើល្មើសច្បាប់ ឬត្រូវផ្តន្ទាទោសចំពោះអំពើនោះផងដែរ។ ប៉ុន្តែក្នុងករណីខ្លះជនល្មើសក៏អាចត្រូវរួចផុតពីកាចោទប្រកានដែរ អាចនិយាយបានថា ជនល្មើសអាចនឹងមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ អាចកើតមានក្នុង ៥ ករណីដូចខាងក្រោម៖

1) ការមិនទទួលខុសត្រូវដោសារមូលហេតុវិបល្លាសស្មារតី (១១)

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឲ្យ បាត់បង់ការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស។

2) ការអនុញ្ញាដោយ ច្បាប់ ឬអាជ្ញាធរ(១២)

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។

(៩) មាត្រា ២១នៃច្បាប់ស្តីពីយុត្តិម៌អនីតិជន

(១០)មាត្រា ២៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

(១១) មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ

(១២) មាត្រា ៣២ នៃក្រមព្រហ្មទណ្ឌ

3) ការការពារស្របច្បាប់[១៣]

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលតែមួយជាមួយគ្នា។
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្រង់ នៃការឈ្លានពាន។

4) សច្ចធារណ៍នៃការពារស្របច្បាប់[១៤]

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ៖

- បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយប្រើល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។
- បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា។

បន្ទាប់ពីកំណត់អត្តសញ្ញាណ និងចាប់យកវត្តុតាងជនសង្ស័យរួមមក មន្ត្រីនគរបានយុត្តិធម៌ធ្វើកំណត់ហេតុស្តាប់ចម្លើយ ក្នុងពេលធ្វើកំណត់ហេតុស្តាប់ចម្លើយ ជនសង្ស័យមានសិទ្ធិដូចជា៖

- មានសិទ្ធិឆ្លើយដោយខ្លួនឯង ឬ ត្រូវការរកមេធាវីការពារសិទ្ធិដើម្បីឆ្លើយអម ជននេះមានសិទ្ធិឆ្លើយនូវអ្វីដែលខ្លួនបានដឹងនិងការពិត ដោយគ្មានការធ្វើទារុណកម្ម ឬការបង្ខិតបង្ខំឲ្យឆ្លើយឡើយ។
- ក្នុងករណីជនជាតិបរទេសដែលមិនអាចនិយាយឬស្តាប់ភាសាខ្មែរបាននោះជននោះអាចមានសិទ្ធិក្នុងការទទួលបានអ្នកបកប្រែនូវច្បាប់ជាភាសាខ្មែរបាន ដោយអនុលោមតាមកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

នៅលើកំណត់ហេតុស្តាប់ចម្លើយដែលជនសង្ស័យបានឆ្លើយមុននឹងចុះហត្ថលេខា ឬផ្តិតមេដៃ ជននេះមានសិទ្ធិអានកំណត់ហេតុនេះឡើយវិញបាន ក្នុងករណីដែលជននេះមិនចេះអក្សរ អាចស្នើសុំឲ្យមន្ត្រីនគរបាល អ្នកបកប្រែអាន ឬបកប្រែនូវកំណត់ហេតុនេះឡើងវិញ[១៥]។

(១៣) មាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌ ២០០៧

(១៤) មាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌ ២០០៧

(១៥) មាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌ធ្វើការចាប់ខ្លួន ក៏ដូចជាកំណត់អត្តសញ្ញាណជនសង្ស័យថាពិតបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមរួចមក ។ មន្ត្រីនគរបាលយុត្តិធម៌សម្រេចឃាត់ខ្លួនជនសង្ស័យ តែមុខនឹងធ្វើការឃាត់ខ្លួនជននេះមានសិទ្ធិដឹងពីបទល្មើស មូលហេតុ នៃការសម្រេចឃាត់ខ្លួន ក្នុងរយៈពេលឃាត់ខ្លួនជនសង្ស័យមានសិទ្ធិ ឬអាចសុំសន្ទនាជាមួយមេធាវីការពារសិទ្ធិ រយៈពេល ៣០ នាទីនៅក្នុងកន្លែងឃាត់ខ្លួនបាន [១៦] ការឃាត់ជនសង្ស័យដែលប្រព្រឹត្តបទឧក្រិដ្ឋ ៤៨ (សែសិបប្រាំបី) ម៉ោង បទមជ្ឈិម ៣៦ (សាមសិបប្រាំមួយ) ម៉ោង ។ ការបើកការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ថេរវេលានៃការស៊ើបអង្កេតមិនអាចលើសពី៧ថ្ងៃ គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស[១៧]។ ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។ កាលណាបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះកាបញ្ជូនកំណត់ហេតុ និងវត្ថុតាង ត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ[១៨]។

### ខ. បទល្មើសមិនជាក់ស្តែង

ដើម្បីចាត់ទុកថាជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម មិនជាក់ស្តែង កាលណាក្រោយពេលមានបទល្មើសរួចបន្តិចមកគ្មានវត្តមានជនដែលគេសង្ស័យនៅនឹងកន្លែងប្រព្រឹត្តដោយបុគ្គលនោះរត់គេចខ្លួនដោយគ្មានតម្រុយច្បាស់លាស់។ នគរបាលយុត្តិធម៌មានមុខងារស្រាវជ្រាវបទឧក្រិដ្ឋ ឬមជ្ឈិម ប្រមូលភស្តុងតាង ចាប់អ្នកប្រព្រឹត្តបទល្មើសបញ្ជូនទៅតុលាការ។ ក្នុងករណីស៊ើបអង្កេតដែលមិនមែនជាបទល្មើសជាក់ស្តែងនោះ គឺនគរបាលយុត្តិធម៌អាចចាប់ឃាត់ខ្លួនបានដែរ នៅពេលមានភស្តុតាងបញ្ជាក់ថាជនណាម្នាក់ជាប់សង្ស័យបទល្មើស ក្នុងដំណាក់កាលស៊ើបអង្កេត បើសិនជាមានភស្តុងតាងច្បាស់លាស់ទេនគរបាលយុត្តិធម៌អាចឃាត់ខ្លួនជនសង្ស័យបាន។

## ២.២. ដំណាក់កាលអយ្យការ

នៅពេលព្រះរាជអាជ្ញា ទទួលពាក្យបណ្តឹងទាមទារ ឬបណ្តឹងបរិហា ដែលខ្លួនបានទទួលតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវចុះ ឬបង្គាប់ឲ្យក្រឡាបញ្ជីអយ្យការណាមួយឲ្យចុះពាក្យបណ្តឹងក្នុងបញ្ជីនៃពាក្យបណ្តឹងជាបន្ទាន់ ទោះជាបទល្មើសជាក់ស្តែងក្តី ឬមិនជាក់ស្តែងក្តី ឬមិនជាក់ស្តែងក្តី វាខុសគ្នាត្រង់ថាមានខ្លួនជនជាប់សង្ស័យ ឬគ្មានខ្លួនជនសង្ស័យ។

បើសិនបើជាបទល្មើសជាក់ស្តែងមានខ្លួនជនជាប់សង្ស័យព្រះរាជអាជ្ញាអាចសួរចម្លើយបាន ដោយគាត់អាចបង្គាប់ឲ្យក្រឡាបញ្ជីអយ្យការណាម្នាក់ សួរចម្លើយជំនួសខ្លួន ហើយព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយចុះលេខពិសេស ហើយបញ្ជូនទៅប្រធានតុលាការដើម្បីចាត់ចៅក្រមស៊ើបសួរ។

(១៦) មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(១៧) មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(១៨) មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

បើសិនជាបទល្មើសមិនជាក់ស្តែងគ្មានជនជាប់សង្ស័យទេ ក្រោយពីទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌មកនោះ ព្រះរាជអាជ្ញា ត្រូវធ្វើការស៊ើបសង្កេតបឋមរកវិមតិសង្ស័យតទៅទៀតនូវតម្រុយចំណុចត្រង់ណាដែលសង្ស័យ ដើម្បីធ្វើការចោទប្រកាន់ដោយសាកសួរ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬ សាក្សី។

### ២.២.១. សិទ្ធិរបស់ជនត្រូវចោទជាអនីតិជន

ក្នុងករណីបទល្មើសជាក់ស្តែងដែលជនសង្ស័យ បន្ទាប់ពីព្រះរាជអាជ្ញាទទួលពាក្យបណ្តឹងពីមន្ត្រីនគរបាលយុត្តិធម៌រួចមក ព្រះរាជអាជ្ញាបង្គាប់ឲ្យក្រឡាបញ្ជីអយ្យការណាមួយដើម្បីសាកសួរចម្លើយជនសង្ស័យរូបនេះហើយ ក្រឡាបញ្ជីអយ្យការត្រូវធ្វើកំណត់ហេតុយកចម្លើយមុននឹងសាកសួរជនសង្ស័យ ក្រឡាបញ្ជីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនសង្ស័យ រួចទើបសាកសួរចម្លើយ តែក្នុងដំណាក់កាលក្រឡាបញ្ជីអយ្យការ ប្រាប់ពីសិទ្ធិដែលជនត្រូវចោទ ទទួលបានដូចខាងក្រោម៖

- ផ្ទៀងផ្ទាត់អត្តសញ្ញាជនត្រូវចោទ(១៩)
- ប្រាប់ជននេះពីសិទ្ធិបានដឹងអំពីបទចោទប្រកាន់ និងពន្យល់អំពីធាតុផ្សំតាមផ្លូវច្បាប់អំពីបទល្មើសដែលត្រូវចោទប្រកាន់
- ជនសង្ស័យ មានសិទ្ធិទទួលបានមេធាវីដោយជ្រើសតាំង ឬចាត់តាំង (អនីតិជនត្រូវមានមេធាវីអមជានិច្ច)។
- សិទ្ធិមិនឆ្លើយដោយដាក់បន្ទុកលើខ្លួនឯង សិទ្ធិរក្សាការសម្ងាត់ឯកជន សិទ្ធិក្នុងការជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។
- សិទ្ធិទទួលជំនួយអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់។
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស ក្រោយធ្វើការសួរចម្លើយជនសង្ស័យ មានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរអាន កំណត់ហេតុឡើងវិញ។ ពេលឆ្លើយចប់មុនពេលផ្តិតមេដៃលើកំណត់ហេតុជននេះមានសិទ្ធិស្នើសុំឲ្យអានឡើងវិញ។ រួចព្រះរាជអាជ្ញាចោទប្រកាន់បទល្មើសតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយបញ្ជូនទៅប្រធានតុលាការដើម្បីចាត់តាំងចៅក្រមស៊ើបសួរណាមួយត្រូវទទួលបន្ទុក។

(១៩) មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

### ២.២.២. សិទ្ធិរបស់ជនត្រូវចោទជានីតិជន

ក្នុងករណីបទល្មើសជាក់ស្តែងដែលជនសង្ស័យ បន្ទាប់ពីព្រះរាជអាជ្ញាទទួលពាក្យបណ្តឹងពីមន្ត្រីនគរបាលយុត្តិធម៌រួចមក ព្រះរាជអាជ្ញាបង្គាប់ឲ្យក្រឡាបញ្ជីអយ្យការណាមួយដើម្បីសាកសួរចម្លើយជនសង្ស័យរូបនេះ។ ហើយក្រឡាបញ្ជីអយ្យការត្រូវធ្វើកំណត់ហេតុយកចម្លើយមុននឹងសាកសួរជនសង្ស័យ ក្រឡាបញ្ជីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនសង្ស័យ រួចទើបសាកសួរចម្លើយ តែក្នុងដំណាក់កាលនេះជនសង្ស័យ បើក្នុងករណីគ្មានមេធាវីជននេះមានសិទ្ធិឆ្លើយដោយខ្លួនឯងក៏បាន ឬក៏ស្វែងរកមេធាវីដើម្បីឆ្លើយអមក៏បាន (ដោយក្រឡាបញ្ជីទុករយៈពេលកំណត់ណាមួយក្នុងការស្វែងរកមេធាវីដើម្បីចូលឆ្លើយ) បើក្នុងករណីជននេះជាជនជាតិបរទេស មិនអាចស្តាប់ភាសាខ្មែរ និងនិយាយបាន ជននេះមានសិទ្ធិទទួលបានអ្នកបកប្រែប្រាប់ជាភាសាខ្មែរដោយចាត់តាំងដោយតុលាការផ្ទាល់ សិទ្ធិទទួលបានការជូនដំណឹង និងទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុលភ្លាមៗ។ ពេលឆ្លើយចប់មុនពេលផ្តិតមេដៃលើកំណត់ហេតុជននេះមានសិទ្ធិស្នើសុំឲ្យអានឡើងវិញបាន បើក្នុងករណីជននេះមិនចេះអក្សរអាចស្នើឲ្យក្រឡាបញ្ជី ឬអ្នកបកប្រែអានឲ្យស្តាប់បាន។ ព្រះរាជអាជ្ញាចោទប្រកាន់បទល្មើសតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងបញ្ជូនទៅប្រធានតុលាការដើម្បីចាត់តាំងចៅក្រមស៊ើបសួរណាមួយឲ្យទទួលបន្ទុកក្នុងរឿងក្តីនេះ។

### ២.៣. ដំណាក់កាលចៅក្រមស៊ើបសួរ

ដំណាក់កាលចៅក្រមស៊ើបសួរ គឺជានីតិវិធីមួយដ៏សំខាន់ក្នុងនីតិវិធីព្រហ្មទណ្ឌ ព្រោះដំណាក់កាលនេះត្រូវបានធ្វើឡើងដោយគោរពសិទ្ធិរបស់ភាគី ទោះជាជនរងគ្រោះ ឬជនត្រូវចោទក៏ដោយ ពោលគឺចៅក្រមស៊ើបសួរ ជាអ្នកស្វែងរកប្រមូលភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដើម្បីធ្វើយ៉ាងណាធានាឲ្យបាននូវការពិត មុននឹងសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ(២០)។ ហេតុនេះដើម្បីឲ្យចៅក្រមស៊ើបសួរស្វែងរកការពិតបាន ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិអំណាចក៏ដូចជាតួនាទីយ៉ាងសំខាន់ ដល់ចៅក្រមស៊ើបសួរក្នុងវិធានការ នៃការស្រាវជ្រាវក្នុងដំណាក់កាលស៊ើបសួររបស់ខ្លួន។ បន្ទាប់ពីបានទទួលសំណុំរឿងពីប្រធានតុលាការក្នុងករណីបទមិនជាក់ស្តែងក្តី ឬពីព្រះរាជអាជ្ញាក្នុងករណីបទល្មើសមិនជាក់ស្តែង ខុសគ្នាត្រង់មានខ្លួន ឬគ្មានខ្លួនប៉ុណ្ណោះ (ឃុំខ្លួន ឬមិនឃុំខ្លួន)។ ក្នុងដំណាក់កាលនេះចៅក្រមស៊ើបសួរគឺស៊ើបសួរតែទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរប៉ុណ្ណោះ។

(២០) មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

### ២.៣.១. សិទ្ធិរបស់ជនត្រូវចោទជាអនីតិជន

ក្នុងករណីបទល្មើសជាក់ស្តែងនៅដំណាក់កាលចៅក្រមស៊ើបសួរនេះក៏មិនខុសគ្នាទៅនឹងដំណាក់កាលមន្ត្រីនគរបាល និងដំណាក់កាលអយ្យការនោះទេ ក្នុងដំណាក់កាលចៅក្រមស៊ើបសួរនេះ ក៏មានការសាកសួរចម្លើយជនត្រូវចោទដូចគ្នា។ បន្ទាប់ពីបានទទួលសំណុំរឿងពីអយ្យការ ឬពីរដ្ឋបាលដែលប្រធានតុលាការចាត់មក ចៅក្រមស៊ើបសួរ ក្នុងអំឡុងពេលការសួរចម្លើយជនត្រូវចោទ នៅពេលដែលជនត្រូវចោទ ចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើសួរត្រូវចាត់វិធានការប្រាប់ពីសិទ្ធិដែលជនត្រូវចោទទទួលបានដូចខាងក្រោម(២១)។

- ផ្ទៀងផ្ទាត់អត្តសញ្ញាណជនត្រូវចោទ។
- ប្រាប់ជននេះពីសិទ្ធិឲ្យបានដឹងអំពីបទល្មើសដែលចោទប្រកាន់ និងពន្យល់អំពីធាតុផ្សំតាមផ្លូវច្បាប់អំពីបទល្មើសដែលត្រូវចោទប្រកាន់តាមដីការបញ្ជូនរឿងឲ្យរបស់ព្រះរាជាអាជ្ញា។
- ជនត្រូវចោទ មានសិទ្ធិទទួលបានមេធាវីដោយជ្រើសតាំង ឬចាត់តាំង(អនីតិជនត្រូវមានមេធាវីអម ជានិច្ច)។
- សិទ្ធិមិនឆ្លើយដោយដាក់បន្ទុកលើខ្លួន សិទ្ធិរក្សាការសម្ងាត់ឯកជន សិទ្ធិក្នុងការជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។
- សិទ្ធិទទួលជំនួយអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់។
- សិទ្ធិ ទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស។

ក្រោយធ្វើការសួរចម្លើយជនត្រូវចោទ ជននោះមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរអាន កំណត់ហេតុឡើងវិញ (ក្នុងករណីជននោះជាអនក្ខរជន)។ បន្ទាប់ពីសួរចម្លើយរួចមកចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឬមិនឃុំបណ្តោះអាសន្នតាមការស្នើសុំរបស់ព្រះរាជអាជ្ញា អនីតិជនអាយុ១៦ (ដប់ប្រាំមួយ) ឆ្នាំ បទមជ្ឈិមមិនឲ្យលើសពី ២ (ពីរ) ខែ។ អនីតិជនអាយុ១៦ (ដប់ប្រាំមួយ) ដល់១៨ (ដប់ប្រាំបី) ឆ្នាំ មិនឲ្យលើសពី៤ (បួន) ខែ(២២)។ នៅក្នុងដំណាក់ឃុំខ្លួននេះជនត្រូវចោទមានសិទ្ធិស្នើសុំឲ្យនៅក្រៅឃុំ មេធាវីការពារជនត្រូវចោទ ដែលជាប់ឃុំអាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន(២៣)។ ពេលចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរផ្តល់ព័ត៌មាន ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ នៅក្នុងរយៈពេល ២ថ្ងៃ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅឲ្យព្រះរាជអាជ្ញាដើម្បីពិនិត្យ(២៤)។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាពុំចាំបាច់មានការស៊ើបសួរបន្តបន្ថែមទៀតនោះព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ការបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញនេះត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទស្ថិតនៅក្នុងឃុំឬក្នុងរយៈពេល១ (មួយ) ខែ ប្រសិនបើជនត្រូវចោទនៅ

(២១) មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន
(២២) មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧
(២៣) មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧
(២៤) មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

ក្រៅឃុំ ព្រះរាជអាជ្ញាអាចស្នើឲ្យចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាទាំង ២ប្រភេទ ដែល[២៥]៖

១. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ (ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ) ។

២. ដីកាលើកលែងការចោទប្រកាន់ (ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមិនមែនជាបទបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ មិនស្គាល់អត្តសញ្ញាណជនត្រូវចោទ ពុំមានភស្តុតាងគ្រប់គ្រាន់ និងមូលហេតុរលត់បណ្តឹងអាជ្ញា)។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិ នៃការរលត់បណ្តឹងអាជ្ញាបានដោយមូលហេតុ មរណភាព នៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍ នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ[២៦]។

### ២.៣.២. សិទ្ធិរបស់ជនត្រូវចោទជានីតិជន

នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ដែលជនត្រូវចោទ អាចចូលបង្ហាញខ្លួនភ្លាម ឬបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវចាត់វិធានការប្រាប់អំពីសិទ្ធិដែលជនត្រូវចោទ ទទួលបានដូចខាងក្រោម៖

- ប្រាប់ជននេះអំពីសិទ្ធិឲ្យបានដឹងអំពីបទចោទប្រកាន់ និងពន្យល់អំពីធាតុផ្សំតាមផ្លូវច្បាប់អំពីបទល្មើសដែលត្រូវចោទប្រកាន់។
- សិទ្ធិក្នុងការពឹងពាក់មេធាវី ឬការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន។

ជនត្រូវចោទអាចត្រូវបានសួរចម្លើយបានតែចំពោះមុខមេធាវីតែប៉ុណ្ណោះ(ករណីមានមេធាវីការពារសិទ្ធ)[២៧] លើកលែងតែមានករណីពិសេស ឬប្រសិនបើជននេះបោះបង់សិទ្ធិរបស់ខ្លួនក្នុងការពឹងពាក់មេធាវី។ បើការសួរចម្លើយជនត្រូវចោទ បានធ្វើឡើងដោយពុំមានវត្តមានមេធាវី កំណត់ចំណាំនៃការបោះបង់នេះត្រូវបានចុះក្នុងកំណត់ហេតុនៃការសួរចម្លើយជាលាយលក្ខណ៍អក្សរ។

- ជនត្រូវចោទមានសិទ្ធិអាចស្នើទៅចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរណាមួយបាន នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដូចជាស្នើឲ្យសួរចម្លើយខ្លួនបន្ថែមទៀតនៅចំណុចណាមួយមិនបានសួរតទល់ជាមួយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលនេះជាឱកាសសម្រាប់ជនត្រូវចោទក្នុងការវែកញែកនិងពិភាក្សាអំពីបទចោប្រកាន់ដោយផ្ទាល់ជាមួយសាក្សីឬដើមបណ្តឹងរដ្ឋប្បវេណី សាកសួរនិងការពារបទចោទប្រកាន់ដែលបានធ្វើឡើងប្រឆាំងនឹងខ្លួននៅចំពោះមុខតុលាការ[២៨]។

(២៥) មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(២៦) មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(២៧) មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(២៨) មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

ក្រោយធ្វើការសួរចម្លើយជនត្រូវចោទ មានសិទ្ធិអាចស្នើសុំឲ្យចៅក្រមស៊ើបសួរអាន កំណត់ហេតុឡើងវិញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់ខ្លួន។ បន្ទាប់ពីសួរចម្លើយរួចមកចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចឃុំខ្លួន ឬមិនខ្លួនឃុំបណ្ដោះអាសន្ន តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ដោយចំពោះអនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នអាចពន្យា២ (ពីរ) ដង ម្ដងបាន៦ (ប្រាំមួយ) ខែ ដោយឡែកការឃុំខ្លួនចំពោះបទមជ្ឈិមអាចត្រូវបានពន្យាពេលបានតែម្ដងគត់ ដោយពន្យាបាន២ (ពីរ)ខែ[២៩]។ នៅដំណាក់កាលឃុំខ្លួននេះជនត្រូវចោទមានសិទ្ធិស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្នបាន ហើយមេធាវីការពារជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្ដីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ពេលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវផ្ដល់ ពត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតាមរយៈលិខិតជូនដំណឹងអំពីការបិទបញ្ចប់ការស៊ើបសួរ។ នៅក្នុងរយៈពេល២(ពីរ)ថ្ងៃ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅឲ្យព្រះរាជអាជ្ញាដើម្បីពិនិត្យបន្ថែម។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាពុំចាំបាច់មានការស៊ើបសួរបន្តបន្ថែមទៀត នោះព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ការបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញនេះត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទស្ថិតនៅក្នុងឃុំ ឬក្នុងរយៈពេល១ (មួយ) ខែ ប្រសិនបើជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាអាចស្នើឲ្យចៅក្រមស៊ើបសួរចេញដីកាណាមួយក្នុងចំណោមទាំង២ប្រភេទ៖

១. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ។

២. ដីកាលើកលែងការចោទប្រកាន់។

## ២.៤. ដំណាក់កាលជំនុំជម្រះ

នៅក្នុងដំណាក់កាលជំនុំជម្រះនេះ ចៅក្រមជំនុំជម្រះ មានភារកិច្ចចម្បងក្នុងការដឹកនាំនីតិវិធីសវនាការ និងសម្រេចសេចក្ដីលើជនជាប់ចោទបន្ទាប់ពីខ្លួនទទួលបានដីកាចាត់តាំងចៅក្រមជំនុំជម្រះតាមរយៈដីកាមួយពីរបស់រដ្ឋលេខាធិកាដ្ឋានរួចមក ក្នុងពេលជាមួយគ្នាចៅក្រមជំនុំជម្រះ ត្រូវកំណត់កាលបរិច្ឆេទដើម្បីបើកសវនាការ ដោយធ្វើការកោះហៅជនជាប់ចោទ មេធាវីជនជាប់ចោទ ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីដំណើរការនីតិវិធី។ ចៅក្រមជំនុំជម្រះមានភារកិច្ចក្នុងការដឹកនាំនីតិវិធីជំនុំជម្រះឲ្យប្រព្រឹត្តទៅរលូន ដើម្បីសម្រេចគោលដៅនៃការបង្ហាញការពិតក្នុងការសម្រេចសេចក្ដី។ការពិភាក្សាដេញដោលនេះ ចៅក្រមជំនុំជម្រះជាអ្នកអាចមានសិទ្ធិសម្រេចអំពីការបើកសវនាការជាសាធារណៈ ឬ អសាធារណៈ។

(២៩) មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

### ២.៤.១. សិទ្ធិរបស់ជនជាប់ចោទជាអនីតិជន

នៅក្នុងដំណាក់កាលជំនុំជម្រះ ការពិភាក្សាដេញដោលចំពោះបទឧក្រិដ្ឋ និងករណីផ្សេងទៀតដែលបទមជ្ឈិម និងបទលហុមានជាប់ទាក់ទិន។ បទចោទពីបទឧក្រិដ្ឋ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះ ចៅក្រម ៣(បី) រូប។ ចំពោះបទមជ្ឈិម និងបទលហុការប្រព្រឹត្តទៅដោយចៅក្រម ១ (មួយ) រូបជាអ្នកដឹកនាំសវនាការ ជនជាប់ចោទមានសិទ្ធិជាអាទិ៍ដូចតទៅៈ

- មានសិទ្ធិទទួលបានសវនាការជាអសាធារណៈនៅក្នុងការជំនុំជម្រះករណីរបស់ខ្លួន **ការពិភាក្សាដេញដោយអាចត្រូវបានធ្វើឡើងទាំងស្រុងឬ មួយផ្នែកជាសម្ងាត់** ។
- សិទ្ធិក្នុងការទទួលបានជំនួយមេធាវីដាច់ខាត។
- សិទ្ធិក្នុងការសំណូមពរឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជនឲ្យចូលរួមសវនាការ (៣០)។

ក្នុងអំឡុងពេលសវនាការ ជនត្រូវបានសាកសួរដោយចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះ ព្រះរាជអាជ្ញា និងមេធាវី។ ហើយជនជាប់ចោទត្រូវបានសន្មតថាគ្មានទោស រហូតដល់តុលាការសម្រេចថាមានពិរុទ្ធភាព ជនជាប់ចោទអាចទទួល ឬមិនទទួលយកការចោទប្រកាន់របស់តុលាការក្នុងដំណាក់នេះ ជនជាប់ចោទមានសិទ្ធិសំណូមពរលើកចុងក្រោយ។ នៅជិតបញ្ចប់សវនាការ ប្រសិនបើចៅក្រមពិនិត្យឃើញថាជនជាប់ចោទគ្មានពិរុទ្ធភាព ជនជាប់ចោទនោះត្រូវបានដោះលែងឲ្យមានសេរីភាព តែបើពិនិត្យឃើញថាជនជាប់ចោទមានពិរុទ្ធភាព ជនជាប់ចោទនោះត្រូវបានផ្តន្ទាទោសតាមច្បាប់កំណត់។

បន្ទាប់ពីសវនាការ ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព ការផ្តន្ទាទោសសម្រាប់ជនជាប់ចោទជាអនីតិជន អាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ ទោសដែលត្រូវទទួលពាក់កណ្តាល នៃទោសជនជាប់ចោទនីតិជន និងត្រូវសមាមាត្រទៅនឹងបទល្មើសដែលបានប្រព្រឹត្ត។ តុលាការក៏អាចនឹងពិចារណាអំពីស្ថានសម្រាល ទៅតាមកាលៈទេសៈដែលបានប្រព្រឹត្តបទល្មើស និងស្ថានភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទនៅពេលនោះ។ បន្ទាប់ពីបានពិភាក្សាក្នុងសវនាការរួចមក ចៅក្រមជំនុំជម្រះត្រូវថយទៅធ្វើការពិភាក្សាសម្រេច។ គ្មានទឡ្ហីករណ៍ណាមួយអាចនឹងត្រូវលើកយកមកសម្អាងទៀតបានឡើយ នៅពេលដែលចៅក្រមថយទៅពិភាក្សាសម្រេច។ សេចក្តីម្រេចអាចត្រូវប្រកាសនៅក្នុងថ្ងៃដដែលឬតុលាការអាចលើកទៅប្រកាសសេចក្តីសម្រេចរបស់នៅកាលបរិច្ឆេទក្រោយទៀតក៏បាន។នៅក្នុងករណីណាក៏ដោយសេចក្តីសម្រេចជនជាប់ចោទត្រូវប្រកាសជាអសាធារណៈក្នុងសេចក្តីម្រេចនោះដោយទុកសិទ្ធិឲ្យជនជាប់ចោទ ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ធ្វើបណ្តឹងតាមកំណត់ច្បាប់ (៣១)។

(៣០) មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

(៣១) មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

### ២.៤.២. សិទ្ធិរបស់ជនជាប់ចោទជានីតិជន

នៅក្នុងដំណាក់កាលជំនុំជម្រះជនជាប់ចោទនីតិជន គឺមានភាពមិនខុសគ្នាប៉ុន្មានទៅនឹងសិទ្ធិរបស់ជនជាប់ចោទអនីតិជនឡើយ វៀរលែងតែក្នុងបើកសវនាអសាធារណៈ និងសាធារណៈប៉ុណ្ណោះមានន័យថា ជនជាប់ចោទមានសិទ្ធិជាអាទិ៍ដូចតទៅៈ

- ជនជាប់ចោទ មានសិទ្ធិទទួលបានសវនាការជាសាធារណៈជាទូទៅនិងដោយសារធារណៈក្នុងករណីបទរំលោភសេពសន្ថវៈ (**លើកលែងតែក្នុងកាលៈទេសៈពិសេស ការពិភាក្សាដេញដោយអាចត្រូវបានធ្វើឡើងទាំងស្រុងឬ មួយផ្នែកជាសម្ងាត់**) ។
- ជនជាប់ចោទ(នីតិជន)មានសិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង ក៏បានតែបើគ្មានលទ្ធភាពជ្រើសរើសមេធាវីអ្នកនឹងត្រូវផ្តល់ជំនួយមេធាវីដោយឥតគិតកម្រៃ។ ក្នុងអំឡុងពេលសវនាការ ជនជាប់ចោទត្រូវបានសាកសួរដោយចៅក្រម ព្រះរាជអាជ្ញា និងមេធាវី។

ជនជាប់ចោទត្រូវបានសន្មតថាគ្មានទោស រហូតដល់តុលាការសម្រេចថាមានពិរុទ្ធភាព ជនជាប់ចោទអាចទទួល ឬមិនទទួលយកការចោទប្រកាន់របស់តុលាការ។ ជនជាប់ចោទមានសិទ្ធិនិយាយសម្តីចុងក្រោយ ។ នៅចុងសវនាការ ប្រសិនបើចៅក្រមពិនិត្យឃើញថាជនជាប់ចោទគ្មានពិរុទ្ធ ជនជាប់ជាប់ចោទនោះត្រូវបានដោះលែងឲ្យមានសេរីភាព តែបើពិនិត្យឃើញថាជនជាប់ចោទមានពិរុទ្ធភាព ជនជាប់ចោទនោះត្រូវបានផ្តន្ទាទោសតាមច្បាប់កំណត់។ បន្ទាប់ពីសវនាការ ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព ទោសដែលត្រូវទទួលទោសរបស់ជនជាប់ចោទត្រូវសមាមាត្រ ឬគិតទៅតាមអតិបរមា និងអប្បរមា នៃទោសដែលច្បាប់បានកំណត់[៣២]។

(៣២) មាត្រា ៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

# ជំពូកទី២
# របប នៃការប្រកាសទោស

# ជំពូកទី២

# របប នៃការប្រកាសទោស

## ផ្នែកទី១. គោលការណ៍ឯកត្តកម្ម នៃទោស

គោលការណ៍ឯកត្តកម្ម នៃទោស គឺជាគោលការណ៍ដែលមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ហើយគោលការណ៍នេះជាគោលការណ៍ដែលត្រូវគ្របដណ្ដប់លើការប្រកាសទោសរបស់ចៅក្រមជំនុំជម្រះ ដូច្នេះទាមទារឲ្យចៅក្រមត្រូវប្រកាន់ពីការអនុវត្តគោលការណ៍នេះឲ្យបានត្រឹមត្រូវ។ បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ហើយតុលាការ ក៏ប្រកាសទោសដោយផ្អែកលើស្ថានទម្ងន់ និងកាលៈទេសៈ នៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុព្រមទាំងកិរិយាមាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ (៣៣)។

### ១.១. ការប្រកាសទោសមូលទោស

មូលទោសអាចមានទាំងទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង ហើយទោសពិន័យជាប្រាក់នេះត្រូវគិតតជាប្រាក់រៀល(៣៤) ហើយប្រាក់ដែលទទួលបានពីការពិន័យត្រូវបង់ចូលជាថវិការដ្ឋ (៣៥)។

ចំពោះមូលទោសនេះតុលាការអាចប្រកាស៖

- ទោសដាក់ពន្ធនាគារ ផងនិងពិន័យជាប្រាក់ផង។
- ទោសដាក់ពន្ធនាគាតែមួយប៉ុណ្ណោះ។
- ទោសពិន័យជាប្រាក់តែមួយប៉ុណ្ណោះ។

### ១.២. ការប្រកាសទោសជំនួស

ការប្រកាសទោសជំនួសមាន ២គឺ ការងារសហគមន៍ និងការស្ដីបន្ទោស។ ដោយះ

- ការងារសហគមន៍៖ អាចប្រកាសបានលុះត្រាតែទោសដាក់ពន្ធនាគារមានអតិបរមាតិចជាង ឬស្មើនឹង ៣(បី) ឆ្នាំ តុលាការអាចប្រកាសបាន។ ចំពោះការងារសហគមន៍ នេះមានរយៈពេលចន្លោះពី ៣០(សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង ការងារនេះជាប្រយោជន៍សារធារណៈ ផ្អែកតាមមាត្រា ៧២ នៃក្រមព្រហ្មទណ្ឌ។ ទោសការងារសហគមន៍ជំនួសមូលទោស ករណីនេះតុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ (៣៦)។

(៣៣) មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ២០០៧

(៣៤) មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ២០០៧

(៣៥) មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌ ២០០៧

(៣៦) មាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌ ២០០៧

- ទោសស្ដីបន្ទោស កាលបើទោសនេះរងនោះ ទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើ ៣ (បី)ឆ្នាំ តុលាការអាចប្រកាសបានក្នុងលក្ខខណ្ឌភាពចលាចល ដល់សណ្ដាប់ធ្នាប់ជាសារធារណៈ ដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់ ការខូចខាតត្រូវបានជួសជុល និងជនជាប់ចោទបានបង្ហាញការធានារួមរស់នៅក្នុងសង្គមវិញ[៣៧]។ ទោសស្ដីបន្ទោសជំនួសមូលទោស ករណីនេះតុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ (មាត្រា៩៨ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ)។

### ១.៣. ការប្រកាសទោសបន្ថែម លើមូលទោស

កាលបើបទល្មើសមួយត្រូវបានផ្ដន្ទាទោសដោយទោសបន្ថែម មួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមលើមូលទោស លើកលែងតែបទបញ្ញត្តិ នៃមាត្រា១០០ នៃក្រមព្រហ្មទណ្ឌ។ ទណ្ឌកម្ម ដែលបន្ថែមលើមូលទោស ទោសនេះអាចប្រកាសបានលុះត្រាតែមានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់នោះ។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន តែបើត្រូវប្រកាសជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងជាក់លាក់[៣៨] ។ ឧទាហរណ៍៖ ទោសបន្ថែមលើបទល្មើសមនុស្សឃាតដោយចេតនា(មាត្រា ២០៨ នៃក្រមព្រហ្មទណ្ឌ) ទោសបន្ថែមលើបទទទួលផលចោរកម្ម (មាត្រា ៤០៣ នៃក្រមព្រហ្មទណ្ឌ) ។ តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែម មួយ ឬច្រើន កាលបើជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ កាលបើជនជាប់ចោទទទួលទោស ដាក់ពន្ធនាគារដែលមានអតិបរមាស្មើ ឬតិចជា ៣(បី)ឆ្នាំ។ ករណីនេះតុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។

## ផ្នែកទី២៖ ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍ អាចប្រកាសបានលុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ហើយយល់ព្រមទទួលធ្វើការងារនេះ ។ នៅពេលប្រកាសទោសតុលាការប្រាប់សាម៉ីខ្លួនពីសិទ្ធិប្រកែក មិនព្រមធ្វើហើយចម្លើយត្រូវចុះក្នុងសេចក្ដីសម្រេច សាលក្រម ឬសាលដីកា។

### ២.១ ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍

ចំពោះការងារសហគមន៍ តុលាការត្រូវកំណត់ថិរវេលា នៃការងារ និងរយៈពេលដែលត្រូវបំពេញ រយៈពេលនេះមិនលើសពី ១(មួយ)ឆ្នាំទេ [៣៩]។

(៣៧) មាត្រា ៧៤ នៃក្រមព្រហ្មទណ្ឌ ២០០៧

(៣៨) មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ ២០០៧

(៣៩) មាត្រា ១០២ នៃក្រមព្រហ្មទណ្ឌ ២០០៧

### ២.២. បែបបទ នៃការអនុវត្តទោសសហគមន៍

បែបបទ នៃការអនុវត្តទោសសហគមន៍ត្រូវបានកំណត់ដោយព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាជាអ្នកចង្អុលប្រាប់ឈ្មោះ នីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា [៤០]។

## ផ្នែកទី៣៖ ការប្ដឹងទាស់ និងបណ្ដឹងឧបាស្រ័យ

### ៣.១. ការប្ដឹងទាស់

ជាគោលការណ៍ ឬតាមផ្លូវច្បាប់នៅពេលតុលាការបើកសវនាការជំនុំជម្រះលើពិរុទ្ធជន ឬជនជាប់ចោទណាម្នាក់ដោយកំបាំងមុខ គឺគាត់អាចប្ដឹងឲ្យតុលាការជំនុំជម្រះឡើងវិញបាន។ ការប្ដឹងសុំឲ្យតុលាការជំនុំជម្រះឡើងវិញនេះភាសាច្បាប់ហៅថា "បណ្ដឹងទាស់"។ បណ្ដឹងទាស់ អាចធ្វើប្រឆាំងនឹងសាលក្រមកំបាំងមុខ មានន័យថានៅពេលដែលជនជាប់ចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនបានបង្ហាញខ្លួននៅពេលសវនាការ និងបានបង្ហាញថាខ្លួនបានដឹងអំពីដីកាកោះហៅ នោះសាលក្រមនឹងបើកផ្លូវឲ្យធ្វើបណ្ដឹងទាស់។

បណ្ដឹងទាស់ ត្រូវបានធ្វើឡើងដោយពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជី នៃតុលាការដែលបានប្រកាសសាលក្រម នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន[៤១]។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ប៉ុន្តែមេធាវីត្រូវតែមានលិខិតអនុញ្ញាតឲ្យធ្វើបណ្ដឹងទាស់តាមរយៈពាក្យសុំពឹងពាក់មេធាវី។ ពិរុទ្ធជនអាចត្រូវបានដោយតំណាងដោយឪពុកម្ដាយ ឬអាណាព្យាបាលក្នុងការប្ដឹងទាស់ទៅតុលា ក្នុងករណីនេះ អ្នកតំណាងឲ្យពិរុទ្ធជនមិនចាំបាច់មានលិខិតអនុញ្ញាតទេ។ បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ដោយចាប់ផ្ដើមគិតពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ដល់ពិរុទ្ធជនដោយផ្ទាល់ដៃ ឬ គិតចាប់ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ [៤២]។

អានុភាពនៃបណ្ដឹងទាស់៖ បណ្ដឹងទាស់អនុញ្ញាតឲ្យទុកជាសូន្យនូវសេចក្ដីសម្រេច និងការព្យួរអានុភាពសេចក្ដីសម្រេចនេះ។ ប៉ុន្តែដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែបន្តមានអានុភាព ។ តុលាការនៅតែមានសមត្ថកិច្ចដើម្បីសម្រេចអំពីការដោះលែងជនជាប់ចោទឲ្យមានសេរីភាពវិញ។ កាលណាបណ្ដឹងទាស់ធ្វើឡើងប្រឆាំងទៅនឹងសេចក្ដីសម្រេចផ្នែក

(៤០) មាត្រា ១០៣ នៃក្រមព្រហ្មទណ្ឌ ២០០៧

(៤១) មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៤២) មាត្រា ៣៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

រដ្ឋប្បវេណីមានតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះដែលទុកជាអសារបង់។រាល់ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនេះត្រូវព្យួរ។ អានុភាពរំលត់នៃសេចក្តីសម្រេចមានគោលដៅអនុញ្ញាតឲ្យតុលាការដែលវិនិច្ឆ័យលើបណ្តឹងទាស់អាចប្តឹងមកខ្លួនឯងបាននូវរឿងក្តីទាំងមូល ឬត្រឹមតែចំណុចដែលពាក់ព័ន្ធនឹងបណ្តឹងទាស់។

សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅចំពោះមុខតុលាការដដែល។ បើអ្នកប្តឹងទាស់ចូលមកបង្ហាញខ្លួនយ៉ាងពិតប្រាកដនៅសវនាការ អំណាចរបស់តុលាការមិនត្រូវបានកំណត់ក្នុងគ្រប់វិស័យ(បណ្តឹងអាជ្ញា ឬបណ្តឹងរដ្ឋប្បវេណី) និងក្នុងគ្រប់អត្ថន័យ។ បណ្តឹងទាស់អាចបន្ថយ ឬតម្លើងការផ្តន្ទាទោស ប៉ុន្តែប្រសិនបើអ្នកប្តឹងទាស់មិនបានបង្ហាញខ្លួននៅពេលសវនាការ តុលាការអាចប្រកាសបណ្តឹងទាស់ទុកជាអសាឥតការ[៤៣] ។

### ៣.២. បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ ជាការតវ៉ាជំទាស់ទៅនឹងសេចក្តីសម្រេចរបស់សាលាដំបូងរាជធានី/ខេត្ត ទៅកាន់សាលាឧទ្ធរណ៍តំបន់[៤៤]។

បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បានមានៈ

- ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី/ខេត្ត ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តំបន់។
- ពិរុទ្ធជន។
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី តែត្រូវមានពាក្យសុំពឹងពាក់មេធាវី ឬប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែចំពោះ ពិរុទ្ធជនដែលជាអនីតិជន អាចតំណាងដោយឪពុកម្តាយ ឬអាណាព្យាបាល។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍។ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចតំណាងដោយមេធាវី សហព័ន្ធ ឬញាតិលោហិតបាន។អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍ជំនួស[៤៥]។ ចំពោះពិរុទ្ធជនដែលកំពុងជាប់ឃុំនៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន អាចសម្តែងឆន្ទៈរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍នៅមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដោយបំពេញពាក្យបណ្តឹងឧទ្ធរណ៍នេះដែលត្រូវបានចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ឬស្នាមមេដៃ។ ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវចុះបញ្ជីដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួននៅលើបញ្ជីពិសេស

(៤៣) មាត្រា ៣៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៤៤) មាត្រា ៣៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៤៥) មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

ហើយឲ្យពិរុទ្ធជនចុះហត្ថលេខា ឬស្នាមមេដៃ នៅរឹម នៃទំព័របញ្ជីនេះ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវបញ្ជូនពាក្យបណ្តឹងនេះក្នុងរយៈពេលខ្លីបំផុតទៅក្រឡាបញ្ជី នៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យបណ្តឹងឧទ្ធរណ៍នេះទៅលើបញ្ជីបណ្តឹងឧទ្ធរណ៍ នៃតុលាការសាមុី។

ចំពោះការប្តឹងរបស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យបណ្តឹងនៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីចុះលិខិតប្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យ នៃសាលាឧទ្ធរណ៍។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា។ នៅក្នុងការប្តឹងឧទ្ធរណ៍ ក្រមនីតិវិធីព្រហ្មទណ្ឌបានទុករយៈពេលដូចខាងក្រោម៖

- សម្រាប់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ការប្តឹងឧទ្ធរណ៍ត្រូវធ្វើក្នុង រយៈពេល១(មួយ)ខែ [៤៦]។
- ការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល១(មួយ)ខែ
- ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល៣(បី)ខែ[៤៧]។

ក្នុងករណីពិសេស នៅក្នុងរឿងឃុំខ្លួន ការប្តឹងឧទ្ធរណ៍ ត្រូវធ្វើដោយព្រះរាជអាជ្ញានៅក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល៥ថ្ងៃ ដែលរយៈពេលនេះគិតចាប់ពីថ្ងៃដែលតុលាការសម្រេចឃុំខ្លួន។

**អានុភាពនៃបណ្តឹងឧទ្ធរណ៍៖** នៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបានបង្អង់សិន ប៉ុន្តែជនជាប់ចោទ ដែលត្រូវបានជាប់ឃុំដែលបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ទាប ហើយត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញានេះ និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងព្រហ្មទណ្ឌ នោះជនជាប់ចោទ ត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច។ ក្នុងករណីដែលតុលាការជាន់ទាបបានសម្រេចឲ្យរួចខ្លួន ឬ បានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬ ស្មើនឹង រយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឲ្យមានសេរីភាពមុនពេលផុតកំណត់ នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ រយៈពេលប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ។ នៅក្នុងករណីដែលសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍ពីជនជាប់ចោទតែម្នាក់ប៉ុណ្ណោះ នោះសាលាឧទ្ធរណ៍មិនអាចដាក់ទម្ងន់ទោសដល់ជននោះបានទេ។ សាលាឧទ្ធរណ៍ អាចសាលដីកាថ្មីបានក្នុងន័យដែលអនុគ្រោះដល់ជននោះ សាលាឧទ្ធរណ៍មិនអាចបន្ថែមទោសពីលើមូលទោសបានទេ។ សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើសដែលកំណត់ដោយតុលាការជាន់ដំបូងដោយឈ្មោះបទល្មើសមួយទៀតបានប៉ុន្តែមិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទបានទេ។

(៤៦) មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧
(៤៧) មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

ម្យ៉ាងទៀត ប្រសិនបើបណ្តឹងនោះបានធ្វើដោយជនជាប់ចោទនោះ សាលាឧទ្ធរណ៍មិនអាចបន្ថែមចំនួនទឹកប្រាក់សម្រាប់ជួសជុលការខូចខាតឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីបានទេ[៤៨]។

### ៣.៣. បណ្តឹងសាទុក្ខ

បណ្តឹងសារទុក្ខ ធ្វើឡើងនៅពេលដែលព្រះរាជអាជ្ញា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកតំណាងស្របច្បាប់មិនសុខចិត្តចំពោះសាលដីកាសាលាឧទ្ធរណ៍[៤៩] ។ រយៈពេលដើម្បីធ្វើបណ្តឹងសារទុក្ខ ១(មួយ)ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍១៥(ដប់ប្រាំថ្ងៃ) ចំពោះសាលដីការបស់សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ ៥ (ប្រាំថ្ងៃ) ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។ កាលណាសាលដីកាដែលបណ្តឹងសារទុក្ខនេះ ជាសាលដីការចំពោះមុខ រយៈពេលប្តឹងសាទុក្ខត្រូវគិតពីថ្ងៃប្រកាសសាលដីកា។ កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ថាចំពោះមុខ រយៈពេលត្រូវផ្តើមពីការឲ្យដំណឹង។ កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់[៥០]។ បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យបណ្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានចេញសេចក្តីសម្រេច។ ពាក្យបណ្តឹងត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍នេះ។ ជនជាប់ចោទ ឬពិរុទ្ធជន និងបុគ្គលដែលត្រូវគេទាមទារក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័នអាចតំណាងដោយមេធាវី ហើយ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្តឹងសាទុក្ខ។ ប៉ុន្តែជនជាប់ចោទ ឬពិរុទ្ធជន ជាអនីតិជនត្រូវតំណាងដោយឪពុកម្តាយ ឬអ្នកអាណាព្យាបាល ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ [៥១]។

(៤៨) មាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៤៩) មាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៥០) មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៥១) មាត្រា ៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

# ជំពូកទី ៣
# សិទ្ធិរបស់ទណ្ឌិត ក្នុងអំឡុងពេលអនុវត្តទោស

# ជំពូកទី៣
# សិទ្ធិរបស់ទណ្ឌិតក្នុងអំឡុងពេលអនុវត្តទោស

## ផ្នែកទី១៖ សិទ្ធិរបស់ទណ្ឌិតជាទូទៅក្នុងអំឡុងពេលអនុវត្តទោស

មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មដទៃទៀត ឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងពិធីសារបន្ថែម។ ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវបានហាមឃាត់ជាដាច់ខាត តាមបញ្ញត្តិមាត្រា ៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦។ ហើយអនុសញ្ញាប្រឆាំងទារុណកម្ម បានបញ្ជាក់សារជាថ្មីអំពីការហាមឃាត់នោះ ហើយផ្តល់ការការពារបន្ថែម ដើម្បីធានាថា ការធ្វើទារុណកម្ម និងការអនុវត្តស្រដៀងគ្នានេះ មិនអាចកើតមានឡើយ។ តួយ៉ាង នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ ប្រទេសកម្ពុជា បានចូលជាភាគី នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម នេះ ហើយរដ្ឋធម្មនុញ្ញ (៥២) ធានាថា អនុសញ្ញានេះ គឺជាផ្នែកមួយ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាផងដែរ។ បន្ថែមពីនេះមានបទដ្ឋានគតិយុត្តិមួយចំនួន ដែលបានចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងនោះក៏មានសិទ្ធិរបស់ទណ្ឌិតផងដែរ ហើយដែលលិខិតបទដ្ឋានគតិយុត្តិទាំងនោះរួមមាន៖ រដ្ឋធម្មនុញ្ញ(៥៣) អនុសញ្ញាស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម ច្បាប់ស្តីពីការគ្រប់គ្រងពន្ធនាគារ ច្បាប់ព្រហ្មទណ្ឌ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន សារាចរស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យពន្ធនាគារស៊ីវិល យុទ្ធសាស្ត្រគ្រប់គ្រងពន្ធនាគារតាមគោលការណ៍សិទ្ធិមនុស្ស...។

ជាក់ស្តែង បន្ទាប់ពីជនត្រូវចោទ ទទួលបានការជំនុំជម្រះចំពោះមុខច្បាប់រួចមក តុលាការនឹងកំណត់រយៈពេលសមស្របមួយ ដើម្បីធ្វើការវិនិច្ឆ័យសេចក្តី និងសម្រេចដាក់ទោសទៅលើពិរុទ្ធជនទៅតាម ប្រភេទនៃបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ហើយនៅក្នុងអំឡុងពេលដែលជនជាប់ចោទត្រូវបានតុលាការសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារបានចូលជាស្ថាពរ ទៅតាមប្រភេទ នៃបទល្មើសដែលខ្លួនបានប្រព្រឹត្តរួចមក នោះជនជាប់ចោទ នឹងត្រូវបានច្បាប់ហៅថា "ទណ្ឌិត"។ តួយ៉ាង ចំពោះទណ្ឌិតដែលត្រូវជាប់ឃុំនៅក្នុងពន្ធនាគារ គឺត្រូវដកហូតសិទ្ធិសេរីភាពមួយផ្នែកធំ ក៏ប៉ុន្តែដោយឡែក ទោះបីជាមានការដកហូតសិទ្ធិសេរីភាពយ៉ាងនេះក្តី ក៏ទណ្ឌិតនូវតែទទួលបានសិទ្ធិមួយចំនួននៅក្នុងពន្ធនាគារផងដែរ។ សិទ្ធិទាំងនោះរួមមាន៖

(៥២) មាត្រា ៣១នៃរដ្ឋធម្មនុញ ព្រះរាជាណាចក្រកម្ពុជា ១៩៩៣

(៥៣)មាត្រា ៣៨ នៃរដ្ឋធម្មនុញព្រះរាជាណាចក្រកម្ពុជា ១៩៩៣

### ១.១. ការទទួលបាននូវសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ចាំបាច់

នៅពេលដែលទណ្ឌិតអំឡុងពេលជាប់ឃុំនៅក្នុងពន្ធនាគារទណ្ឌិតត្រូវបានទទួលសម្លៀកបំពាក់ដែលជាឯកសណ្ឋានអ្នកទោស និងទទួលបានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ នៅក្នុងបន្ទប់ឃុំឃាំងរបស់ខ្លួនឲ្យសមស្របទៅតាមលក្ខខណ្ឌអាកាសធាតុ សម្រាប់ប្រើប្រាស់ក្នុងរយៈពេលពន្ធនាគារ សម្រាប់រយៈពេល១ (មួយ) ឆ្នាំ ហើយចំពោះសម្ភារៈទាំងនោះត្រូវថែរក្សាឲ្យនៅក្នុងស្ថានភាពល្អនិងត្រូវផ្លាស់ប្តូរបើសិនជាចាំបាច់ផងដែរ។ ដោយសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនទាំងនោះរួមមានដូចខាងក្រោម[៥៤]៖

| | |
|---|---|
| -ខោវែង អាវវែង ក្រណាត់តេតារុង | ចំនួន ១ សំរាប់ |
| -ខោខ្លី អាវខ្លី ក្រណាត់តេតារុង | ចំនួន ១ សំរាប់ |
| -មុងនីឡុង | ចំនួន ១ |
| -ភួយ | ចំនួន ១ |
| -កន្ទេល នីឡុង | ចំនួន ១ |
| -ក្រម៉ា អំបោះ | ចំនួន ១ |
| -កន្សែងពោះគោទំហំតូច | ចំនួន ២ |
| -ស្បែកជើងផ្ទាត់ | ចំនួន ២គូ |
| -ចានទាបអាលុយមីញ៉ូម | ចំនួន ២ |
| -ស្លាបព្រាជ័រ | ចំនួន ២ |
| -កែវជ័រ | ចំនួន ២ |
| -ម្សៅសាប៊ូ | ចំនួន ៣ គីឡូក្រាម |
| -សាប៊ូដុំសម្រាប់ការពារជម្ងឺមាស់ | ចំនួន ៦ដុំ |
| -ច្រាសដុសធ្មេញ | ចំនួន ២ដើម |
| -ថ្នាំដុសធ្មេញធុនមធ្យម | ចំនួន ៦បំពង់ |
| -ក្រណាត់ប៉ារ៉ាតង់ | ចំនួន ១ សម្រាប់ ១៥នាក់ |

### ១.២. ការទទួលបានរបបអាហារ និងទឹក

ចំពោះចំណីអាហារវិញ ទណ្ឌិតទាំងអស់ទទួលបានម្ហូបអាហារដែលមានជីវជាតិសមល្មមដែលអាចជួយទ្រទ្រង់ ថែរក្សាសុខភាព និងរូបរាងកាយបាន រួមទាំងទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃក្នុងអំឡុងពេលអនុវត្តទោស។

(៥៤) មាត្រា ១២ នៃអនុក្រឹត្យស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត

បន្ថែមពីនេះ ប្រសិនបើជាថ្ងៃបុណ្យជាតិ មានដូចជា ថ្ងៃបុណ្យចូលឆ្នាំសកល ថ្ងៃ៧មករា (ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍) ថ្ងៃបុណ្យចូលឆ្នាំខ្មែរ និងថ្ងៃបុណ្យភ្ជុំបិណ្ឌចំពោះរបបអាហាររបស់ទណ្ឌិតគ្រប់រូប ត្រូវបានទទួលបន្ថែមមួយជាពីរនៃថ្ងៃធម្មតា(៥៥) ។ ម្យ៉ាងវិញទៀត ទណ្ឌិតក៏អាចទទួលបានម្ហូបអាហារពីខាងក្រៅពន្ធនាគារដែលទិញដោយថវិកាផ្ទាល់ខ្លួន ឬមានការផ្តល់ដោយអ្នកសួរសុខទុក្ខ ប៉ុន្តែម្ហូបអាហារទាំងនោះត្រូវបានត្រួតពិនិត្យ និងមានការអនុញ្ញាតដោយមន្ត្រីពន្ធនាគារជាមុនសិន មុននឹងប្រគល់ឲ្យទណ្ឌិត។

ទោះបីជាទណ្ឌិតមិនមានសិទ្ធិចេញពីពន្ធនាគារទៅជួបក្រុមគ្រួសារក្តី ក៏ប៉ុន្តែទណ្ឌិតមានសិទ្ធិទទួលបានការសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារ ឬមិត្តភក្តិយ៉ាងតិចបំផុតបានរយៈពេល ១(មួយ) ម៉ោង ក្នុង(១) មួយសប្តាហ៍ទៅតាមពេលវេលាកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងដែលរៀបចំដោយប្រធានពន្ធនាគារ។ បន្ថែមពីនេះ ទណ្ឌិតក៏នៅមានសិទ្ធិទទួលបានការសួរសុខទុក្ខពីសំណាក់មេធាវីការសិទ្ធិ និងអ្នកតំណាងស្របច្បាប់តាមផ្លូវច្បាប់របស់ខ្លួនក្នុងពេលម៉ោងធ្វើការនិងប្រព្រឹត្តឡើងជាការសម្ងាត់ដែរ។

### ១.៣. សិទ្ធិទទួលបានពត៌មាន និង ស្វ័យសិក្សា

ថ្វីត្បិតតែទណ្ឌិត មិនមានសេរីភាពដើរហើរចេញទៅក្នុងសង្គមខាងក្រៅយ៉ាងណាក៏ដោយ ក៏ទណ្ឌិត នៅតែត្រូវទទួលបានការស្វ័យសិក្សាដោយខ្លួនឯងដើម្បីបង្កើនចំណេះដឹង ដោយត្រូវបានអនុញ្ញាតឲ្យចូលសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឲ្យខ្ចីឯកសារយកទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំង។ ជាងនេះទៅទៀត ជនជាប់ឃុំ ត្រូវបានអនុញ្ញាតឲ្យទទួលដំណឹង ឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន អំពីតថភាពសង្គមខាងក្រៅផងដែរ (៥៦)។

### ១.៤. សិទ្ធិខាងជំនឿសាសនា

យោងមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិថា *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿសាសនា សេរីភាពខាងជំនឿ និងប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត [...]*។ ហើយជនជាប់ឃុំមានសិទ្ធិប្រតិបត្តិសាសនាតាមជំនឿរបស់ខ្លួន និងមិនត្រូវបានបង្ខិតបង្ខំឲ្យប្រតិបត្តិសាសនាណាមួយឡើយ។

ទាំងនេះសបញ្ជាក់ឲ្យឃើញថា ទណ្ឌិតគ្រប់រូប រួមទាំងទណ្ឌិតជាជនបរទេស មានសិទ្ធិប្រកាន់យកសាសនាទៅតាមជំនឿរបស់ខ្លួន ក្នុងអំឡុងពេលអនុវត្តទោសផងដែរ។ បន្ថែមជាមួយគ្នានេះ ទណ្ឌិតមានសិទ្ធិទទួលបាននូវសម្ភារៈសម្រាប់ធ្វើសក្ការៈតាមបែបនៃសាសនា ដែលខ្លួនប្រកាន់ខ្ជាប់ផងដែរ (៥៧)។

(៥៥) មាត្រា ៣៤ នៃច្បាប់ស្តីពីពន្ធនាគារ

(៥៦) មាត្រា ៣៧ នៃច្បាប់ស្តីពីពន្ធនាគារ

(៥៧) មាត្រា ២៩ នៃច្បាប់ស្តីពីពន្ធនាគារ

### ១.៥. ការទទួលបានសេវាពេទ្យ

ទណ្ឌិតគ្រប់រូប ត្រូវបានផ្តល់នូវការថែទាំសុខភាពក្នុងអំឡុងពេលជាប់ឃុំនៅក្នុងពន្ធនាគារ ដោយនៅក្នុងពន្ធនាគារនីមួយៗមានប៉ុស្តិ៍សុខភាពដែលគ្រប់គ្រងដោយមន្ត្រីពេទ្យពន្ធនាគារ សម្រាប់ការផ្តល់ជូននូវការពិនិត្យសុខភាព ការពិនិត្យព្យាបាលសង្គ្រោះបន្ទាន់ រួមទាំងការពិនិត្យសុខភាពទៅតាមអាការៈ និងតម្រូវការចាំបាច់របស់ទណ្ឌិតផងដែរ។ តួយ៉ាង នៅក្នុងប៉ុស្តិ៍សុខភាពក៏មានការផ្តល់ជូននូវកម្មវិធីអប់រំផ្នែកសុខភាពទៅឲ្យទណ្ឌិតគ្រប់រូប ឲ្យបានយល់ដឹងទាក់ទងទៅនិង ការធ្វើអនាម័យផ្ទាល់ខ្លួន អានាម័យពន្ធនាគារ ជម្ងឺឆ្លង ការអប់រំលើបញ្ហាប្រឈមចំពោះគ្រឿងញៀន ការអប់រំពីរបៀប ឬការថែទាំងមុន និងក្រោយពេលសម្រាលទារក និងអាហារូបត្ថម្ភជាដើម។ នៅពេលទណ្ឌិតមានអាការៈជម្ងឺធ្ងន់ធ្ងរ ដែលត្រូវការសម្រាកព្យាបាលជាបន្ទាន់នៅមន្ទីរពេទ្យ មន្ត្រីពេទ្យពន្ធនាគារ នឹងធ្វើការជូនដំណឹងជាបន្ទាន់ទៅដល់ប្រធានពន្ធនាគារដើម្បីជួយសម្រួលដោយបញ្ជូនទណ្ឌិតទៅកាន់មន្ទីរពេទ្យរដ្ឋក្រោមសេវាគ្របដណ្តប់របស់ក្រសួងសុខាភិបាល ដោយភ្ជាប់ទៅជាមួយនូវសំណុំឯកសារសុខភាពរបស់ទណ្ឌិតនោះ។ ហើយទណ្ឌិត ក៏ទទួលបានការតាមដានជម្ងឺពីសំណាក់មន្ត្រីពេទ្យពន្ធនាគារជារៀងរាល់ថ្ងៃនៅឯមន្ទីរពេទ្យផងដែរ។ ដោយឡែក ទណ្ឌិតម្នាក់ៗ ត្រូវទទួលបានរបបប្រចាំខែសម្រាប់សេវាអប់រំ ជាងនេះទៅទៀត សិទ្ធិរបស់ទណ្ឌិតដែលមិនអាចខ្វះបាននៅពេលអនុវត្តទោស ក្នុងពន្ធនាគារ គឺសិទ្ធិរបស់ទណ្ឌិតទទួលបានកម្មវិធីលំហាត់ប្រាណ ការងារ ការអប់រំ និងជាពិសេស គឺសិទ្ធិត្រូវទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ជំនាញក្នុងការលើកស្ទួយជីវភាពរស់នៅ និងស្តារនីតិសម្បទារបស់ទណ្ឌិត ដែលជាសារប្រយោជន៍នៅពេលដែលទណ្ឌិតវិលត្រឡប់ចូលទៅរស់នៅក្នុងសង្គមវិញ [៥៨]។

### ១.៦. ការទទួលបានការប្រើប្រាស់ថវិកាផ្ទាល់ខ្លួន

បើទោះបីជា ទណ្ឌិតត្រូវបានជាប់ឃុំ មិនអាចចេញមកសង្គមខាងក្រៅដើម្បី ដើរទិញទំនិញ ឬសម្ភារៈចាំបាច់សម្រាប់ប្រើប្រាស់នៅទីផ្សារបានដោយ ក៏មិនមែនមានន័យថា ពិរុទ្ធជន និងទណ្ឌិតមិនអាចប្រើប្រាស់ថវិកានៅក្នុងអំឡុងពេលជាប់ឃុំដែរ ពោលគឺទណ្ឌិត ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ដើម្បីទិញ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ឬទទួលសម្ភារៈប្រើប្រាស់ពីសំណាក់ក្រុមគ្រួសារ ញាតិមិត្ត ឬពីប្រភពផ្សេងៗ ប្រសិនជាមានការយល់ព្រមនិងត្រួតពិនិត្យជាមុនដោយមន្ត្រីពន្ធនាគារ។[៥៩]

(៥៨) មាត្រា ៣៨ នៃច្បាប់ស្តីពីពន្ធនាគារ

(៥៩) មាត្រា ៣៥ នៃច្បាប់ស្តីពីពន្ធនាគារ

### ១.៧. ការទទួលបានរបបជីវភាព

នៅក្នុងអំឡុងពេលជាប់ឃុំ ពិរុទ្ធជន និងទណ្ឌិត ច្បាស់ណាស់ថាមិនអាចប្រកបមុខរបរដើម្បីរកប្រាក់កម្រៃបានឡើយ។ ប៉ុន្តែទោះបីជាយ៉ាងនោះក្តី ក៏រាជរដ្ឋាភិបាលនៅតែយកចិត្តទុកដាក់សម្រួលជីវភាពចំពោះជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ដោយផ្តល់ឲ្យរបបហូបចុកប្រចាំថ្ងៃចំនួន ២.៨០០ រៀល (៦០)។ បន្ថែមពីនេះផងដែរ ចំពោះពិរុទ្ធជន និងទណ្ឌិត ដែលមានកូនអាយុក្រោម៦ (ប្រាំមួយ) ឆ្នាំ ដែលរស់នៅក្នុងពន្ធនាគារជាមួយនោះ រាជរដ្ឋាភិបាលបានផ្តល់របបហូបចុក ស្មើនិងចំនួនពាក់កណ្តាល នៃរបបរបស់ពិរុទ្ធជន និងទណ្ឌិតមួយនាក់ ពោលគឺស្មើនឹងទឹកប្រាក់ចំនួន ១.៤០០រៀល។ ដោយឡែក នៅក្នុងអំឡុងពេលមានបុណ្យជាតិធំៗដូចជា បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ បុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ និងបុណ្យឯករាជ្យជាតិ ពិរុទ្ធជន និង ទណ្ឌិត ទាំងអស់ត្រូវទទួលបានរបបបន្ថែមទ្វេដង។ ហើយយ៉ាងណាមិញ ចំពោះកូនដែលរស់នៅជាមួយម្តាយ ក៏ត្រូវបានទទួលរបបបន្ថែមទ្វេដងផងដែរក្នុងទិវាសិទ្ធិកុមារអន្តរជាតិ ១ មិថុនា (៦១)។ ចំពោះ ទណ្ឌិត ដែលបានចូលរួមអនុវត្តកម្មវិធីឧហ្សាហកម្ម កសិកម្មពន្ធនាគារ ត្រូវទទួលបានផលកម្រៃដោយផ្ទាល់ និងការលើកទឹកចិត្តដទៃទៀតតាមរយៈការកំណត់ក្នុងនីតិវិធីស្តីពីការគ្រប់គ្រងឧហ្សាហកម្ម កសិកម្មពន្ធនាគាររបស់ក្រសួងមហាផ្ទៃ (៦២)។ ហើយ នៅពេលដែលទណ្ឌិត បានបញ្ចប់ការអនុវត្តទោស និងត្រូវបានដោះលែងចេញពីពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ នោះទណ្ឌិតម្នាក់ ត្រូវទទួលបានខោអាវថ្មីមួយសំរាប់ និង ប្រាក់ឧបត្ថម្ភចំនួន ៥០.០០០រៀលសម្រាប់ធ្វើដំណើរ (៦៣)។

## ផ្នែកទី២៖ សិទ្ធិរបស់ទណ្ឌិតជាពិសេស ក្នុងអំឡុងពេលអនុវត្តទោស

### ២.១. សិទ្ធិរបស់ទណ្ឌិតជាស្ត្រី

នៅក្នុងពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា ជនជាប់ឃុំ ជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជន ត្រូវបានដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត។ ដោយឡែក ជនជាប់ឃុំជាស្ត្រី ត្រូវបានដាក់បំបែកចេញពីជនជាប់ឃុំជាបុរស ជនជាប់ឃុំជាអនីតិជនត្រូវបានដាក់បំបែកចេញពីជនជាប់ឃុំជានីតិជន ជនជាប់ឃុំដែលមានជម្ងឺឆ្លង ត្រូវបានដាក់បំបែកចេញពីជនជាប់ឃុំដទៃទៀត(៦៤) ។ បន្ថែមពីនេះ ទណ្ឌិតជាស្ត្រី ត្រូវបានទទួល ការថែទាំជាពិសេសជាងជនជាប់ឃុំជាបុរសពីព្រោះ ស្ត្រីត្រូវបានពិភពលោកទទួលស្គាល់ថា ជាភេទទន់ខ្សោយ។ ចំពោះសិទ្ធិពិសេសបន្ថែមទៅលើសិទ្ធិជាទូទៅដែលពិរុទ្ធជន និង ទណ្ឌិតជាស្ត្រីត្រូវទទួលបានរួមមាន៖

- ត្រូវទទួលបានការផ្តល់សេវាគាំពារមាតា និងទារកនៅមុន និងក្រោយពេលសម្រាលកូន។

(៦០) មាត្រា ៧ នៃអនុក្រឹត្យស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត

(៦១) មាត្រា ១០ នៃអនុក្រឹត្យស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត

(៦២) មាត្រា ២៣ នៃអនុក្រឹត្យស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត

(៦៣) មាត្រា ២៥ នៃអនុក្រឹត្យស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត

(៦៤) មាត្រា ២៦ នៃច្បាប់ស្តីពីពន្ធនាគារ

- មានសិទ្ធិសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅ ពន្ធនាគារ។
- ត្រូវបានអនុញ្ញាតដោយស្វ័យប្រវត្តិឲ្យស្នាក់នៅក្នុងពន្ធនាគារ ចំពោះកូនដែលតាមម្តាយត្រឹមអាយុក្រោម ៣ (បី)ឆ្នាំ និងត្រូវបានទទួលការផ្តល់ម្ហូបអាហារ សម្លៀកបំពាក់ និងសេវាថែទាំសុខភាព។
- ត្រូវទទួលបានសារុងចំនួន២ និងសំឡីអនាម័យចំនួន ១២ដុំធំក្នុងមួយឆ្នាំ។
- ក្នុងពេលសំរាលកូន ត្រូវទទួលបានក្រណាត់ទេសឯក ចំនួន ៤ ម៉ែត្របន្ថែមទៀត។

## ២.២. សិទ្ធិជាមូលដ្ឋានរបស់ទណ្ឌិតជាអនីតិជន

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសសុទ្ធតែត្រូវបានផ្តន្ទាទោសតាមកំណត់ច្បាប់ទាំងអស់ទៅតាមប្រភេទនៃបទល្មើសដែលបានប្រព្រឹត្តនោះ (អ្នកណាប្រព្រឹត្ត អ្នកនោះអ្នកទទួលខុសត្រូវ)។ នីតិជន គ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទ ថាបានប្រព្រឹត្តបទល្មើសណាមួយ ត្រូវតែគោរពតាមនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬអយ្យការ ឬចៅក្រមស៊ើបសួរជាដើម។ បើទោះបីជា ទណ្ឌិតជាអនីតិជន ត្រូវបានដកហូតសិទ្ធិសេរីភាពមួយផ្នែកធំយ៉ាងណាក៏ដោយក៏ច្បាប់ជាតិ និងច្បាប់អន្តរជាតិ នៅតែមិនមើលរំលង ផ្ទុយមកវិញជំនួសដោយការយកចិត្តទុកដាក់យ៉ាងជាពិសេសក្នុងការអប់រំ កែប្រែ តម្រង់ទិស ព្យាបាលថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដល់អនីតិជន គ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវបានទទួលសិទ្ធិជាមូលដ្ឋានផងដែរ [៦៥]។

ជាងនេះទៀតសោត នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន នោះតម្រូវ លើកលែងតែករណីមានចែងពិសេសក្នុងច្បាប់ផ្សេងទៀត[៦៦] ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថា កាលៈទេសៈរបស់ជនល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវឲ្យអនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌនោះ ក៏ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនមិនអាចស្ថិតនៅលើគោលការណ៍ស្មើភាពគ្នាដូចនីតិជនឡើយ។

ការជំនុំជម្រះក្នុងរឿងសំណុំរឿងក្តីរបស់អនីតិជន ត្រូវបានប្រព្រឹត្តដោយអសាធារណៈ ដោយការធ្វើបែបនេះគឺដើម្បីគាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ [៦៧]។ ទណ្ឌិតជាអនីតិជន ត្រូវបានដាក់ឃុំនៅក្នុងមណ្ឌលយុវនីតិសម្បទា ដែលចំណុះឲ្យអគ្គនាយដ្ឋានបច្ចេកទេស នៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[៦៨] ដែលគ្រប់គ្រងក្មេងពីអាយុ ៧ (ប្រាំពីរ) ឆ្នាំ ដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។ ហើយទណ្ឌិតជាអនីតិជន ត្រូវបានយកចិត្តទុកដាក់ដោយឡែក ទាក់ទងនិងតម្រូវការ [៦៨]៖

(៦៥) មាត្រា ០៦ នៃច្បាប់ស្តីពីពន្ធនាគារ

(៦៦) មាត្រា ០៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

(៦៧) មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

(៦៨) មាត្រា ០១ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា

- សិទ្ធិទទួលបានការអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើផ្លូវកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ។
- សិទ្ធិទទួលបានវិធានការដាក់វិន័យស្របតាមសេចក្ដីថ្លៃថ្នូររបស់អនីតិជន។
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច។
- សិទ្ធិផ្ដល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី។
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជម្ងឺ ឬរបួស និងផ្ដល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី។
- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកឬមិត្តភ័ក្រ្ត។
- សិទ្ធិទទួលបានយន្តការបណ្ដឹងប្រកបដោយប្រសិទ្ធភាពនិងរក្សាការសម្ងាត់ទាក់ទងនិងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន។
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន។

ជាងនេះទៅទៀត ទណ្ឌិតជាអនីតិជន ត្រូវទទួលបានការមើលថែរក្សា គាំពារយ៉ាងខ្លាំងដោយច្បាប់ស្ដីពីយុត្តិធម៌អនីតិជន និងមានសិទ្ធិពិសេសនៅក្នុងអំឡុងពេលអនុវត្តទោសដូចជា៖

- ក្នុងករណីដែលទណ្ឌិតជាអនីតិជន បានទទួលរងនូវទោសក្នុងមណ្ឌលយុវនីតិសម្បទា បុគ្គលដែលអាចដាក់ពាក្យស្នើសុំដោះលែងដោយមានលក្ខខណ្ឌគឺ ទណ្ឌិតជាអនីតិជន ឬមេធាវីរបស់ជននោះ អ្នកតំណាងដោយច្បាប់បានកំណត់ ប្រធានមណ្ឌលយុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ច ដែលពាក់ព័ន្ធនឹងរឿងក្ដីអនីតិជននោះ និងបេសកកម្មការទូត ឬកុងស៊ុលបរទេស ករណីអនីតិជននោះជាជនបរទេស (៧០)។

- សិទ្ធិស្នើសុំឲ្យមានការស្ដារនីតិសម្បទាឡើងវិញ តាមផ្លូវតុលាការ (៧១)។

- ទទួលបានសេវាសម្រាប់

(៦៩) មាត្រា ៨០ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន

(៧០) មាត្រា ៧៣ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន

(៧១) មាត្រា ៧៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន

### ២.៣. សិទ្ធិរបស់ទណ្ឌិតជាជនបរទេស

ក្នុងប្រព័ន្ធពន្ធនាគារនៅគ្រប់តំបន់ នៃពិភពលោកយើងនេះ ចំនួនជនជាប់ឃុំបរទេសមានយ៉ាងច្រើនគួរកត់សម្គាល់។ ហើយក្នុងនោះ បណ្តាប្រទេសជាច្រើន ចំនួននេះកំពុងតែកើនឡើងដោយសារតែការចល័តផ្នែកភូមិសាស្រ្តមានការកើនឡើង។ ពាក្យ "ជនជាប់ឃុំបរទេស" គ្របដណ្តប់លើជំពូកមនុស្សជាច្រើន។ ពាក្យនេះប្រើសម្រាប់ជនជាប់ឃុំមកពីប្រទេសកំណើតរបស់ខ្លួន ហើយបន្ទាប់មកត្រូវបានកាត់ឲ្យជាប់ទោសពន្ធនាគារក្នុងប្រទេសមួយផ្សេងទៀត។ ពាក្យនេះទៀតសោត ក៏សំដៅលើជនជាប់ឃុំរស់នៅ និងអាចជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសដែលខ្លួនជាប់ពន្ធនាគារ ប៉ុន្តែមិនមានសញ្ជាតិនៅប្រទេសនោះទេ។ ពាក្យនេះផងដែរ ក៏អាចប្រើសម្រាប់ជនជាប់ពន្ធនាគារដែលមិនមែនជាប់ពីបទល្មើសព្រហ្មទណ្ឌ ក៏ប៉ុន្តែដោយសារមូលហេតុអន្តោប្រវេសន៍។ ម្យ៉ាងវិញទៀត ជនជាប់ឃុំបរទេស អាចនៅដាច់ដោយឡែកពីជនជាប់ឃុំដទៃទៀត ដោយសារភាសា និងវប្បធម៌របស់ខ្លួន។ ក្នុងប្រទេសមួយចំនួន ជនជាប់ឃុំបរទេសប្រើប្រាស់ភាសាដូចគ្នា ឬមកពីប្រទេសដូចគ្នា ត្រូវបានដាក់ក្នុងពន្ធនាគារតែមួយ ឬផ្នែកណាមួយនៃពន្ធនាគាររួមគ្នា ដើម្បីឲ្យជនជាប់ឃុំទាំងនោះជួយគ្នាទៅវិញទៅមក។ ដោយឡែក បើក្រឡេកមកមើលប្រព័ន្ធគ្រប់គ្រងពន្ធនាគារ របស់ប្រទេសកម្ពុជាវិញ គឺមិនខុសពីគ្នានោះ ឡើយ។ ហេតុនេះ ក្រៅពីទទួលបានសិទ្ធិជាទូទៅខាងលើនេះហើយ ទណ្ឌិតជាជនបរទេស មានសិទ្ធិដូចខាងក្រោម៖

- **សិទ្ធិទទួលបានជំនួយពីស្ថានកុងស៊ុល៖** ជនជាប់ពន្ធនាគារនៅបរទេស អាចកើតមានបញ្ហាជាច្រើនសម្រាប់ជនជាប់ឃុំដែលរដ្ឋបាលពន្ធនាគារមិនអាចដោះស្រាយបាន ហើយដូច្នេះ រដ្ឋបាលពន្ធនាគារត្រូវតែធានាថាខ្លួនគោរពដល់សិទ្ធិជនជាប់ឃុំបរទេសក្នុងការទទួលជំនួយពីតំណាងការទូតមកពីប្រទេសកំណើតរបស់ជនជាប់ឃុំ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងការទូត និងមាត្រា ៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងពន្ធនាគាររបស់ប្រទេសកម្ពុជា។ នៅពេលណាដែលជនជាប់ឃុំបរទេសទាំងនោះជាប់ពន្ធនាគារក្នុងប្រទេសមួយដែលមិនមានតំណាងការទូតអ្នកទាំងនោះត្រូវទទួលបានការអនុញ្ញាតឲ្យទាក់ទងជាមួយតំណាងការទូតដែលតំណាងឲ្យប្រទេសរបស់ខ្លួន។

## ផ្នែកទី៣. សិទ្ធិទទួលបានការលើកលែងទោស ឬការបន្ធូរបន្ថយទោស

ជាបឋម មានពាក្យចំនួនបី ដែលត្រូវពន្យល់គឺ៖ **"ការបន្ធូរបន្ថយទោស" "ការលើកលែងទោស" និង "ការអនុគ្រោះទោស"** ។ ការបន្ធូរបន្ថយទោស គឺជាការកាត់បន្ថយទោសឲ្យនៅសល់រយៈពេលកាន់តែខ្លី និងឆាប់បញ្ចប់ទោស ដែលត្រូវអនុវត្តទោស។ រីឯ ការលើកលែងទោសត្រូវបានបែងចែកជាពីរប្រភេទគឺ៖ ការលើកលែងទោសជាទូទៅ និងការលើកលែងទោសធម្មតា។ ការលើកលែងទោសជាទូទៅ សំដៅទៅលើការលើកលែងទោសដល់ជនប្រព្រឹត្តបទឧក្រិដ្ឋជាក្រុម តាមរយៈច្បាប់អនុម័តដោយសភា គឺច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ដោយប្រយោលដែលស្ថិតនៅក្នុងប្រភេទនេះ។ ចំណែកឯ ការលើកលែងទោសជាធម្មតា ឬអាចហៅបានថា

ជាការអនុគ្រោះទោស សំដៅដល់ការលើកលែងទោស ដែលផ្តល់ជូនដោយព្រះមហាក្សត្រ ចំណុចនេះ មានលក្ខណៈខុសគ្នារវាង ការបន្ធូរបន្ថយទោស ពីព្រោះ ការលើកលែងទោស និងបញ្ចប់ការអនុវត្តទោសដែលនៅសល់ ហើយណ្ឌិតនឹងមានសេរីភាពវិញ។ ជាទូទៅ ទណ្ឌិតត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដូចជាការកែប្រែអត្តចរិតល្អ ហើយទទួលទោសក្នុងពន្ធនាគារបានរយៈពេលកំណត់មួយ មុននឹងទទួលបានការលើកលែងទោស។

ម៉្យាងវិញ ការលើកលែងទោសមិនមានភ្ជាប់នូវលក្ខខណ្ឌ ឬជាប់កាតព្វកិច្ចអ្វីទេ។ ការលើកលែងទោស ធម្មតា ខុសពីការត្រួតពិនិត្យតាមផ្លូវតុលាការ (ដោយចៅក្រមស៊ើបអង្កេត) ក្នុងអំឡុងមុនពេលសវនាការ ដាក់ឲ្យជនត្រូវចោទនៅមន្ទីរឃុំឃាំងភ្ជាប់ជាមួយលក្ខខណ្ឌនៃការគោរពកាតព្វកិច្ចមួយចំនួន(៧២)។ វៀរលែងតែករណីលើកលែងទោសជាទូរទៅ ការលើកលែងទោសធម្មតា មិនបានបញ្ចប់នូវសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះឡើយ (៧៣)។

## ៣.១. សិទ្ធិក្នុងការទទួលបានការលើកលែងទោស និង ការបន្ធូរបន្ថយទោសក្រោមវិធានច្បាប់អន្តរជាតិ

ផ្អែកតាមស្មារតី មាត្រា ៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងអំពីសិទ្ធិរស់រានមានជីវិត ហើយក្នុងនោះទៀតសោត បានចែងអំពីករណីលើកលែងចំពោះការអនុវត្តទោសប្រហារជីវិត។ បន្ថែមពីលើនេះ មាត្រានេះបានចែងតម្រូវឲ្យមានការបន្ធូរបន្ថយទោស ពីទោសប្រហារជីវិត មកទោសដាក់ពន្ធនាគារមួយជីវិត។ ហើយ មាត្រា ១៤ នៃកតិកាសញ្ញាដដែល បានចែងនូវការលើកលែង ឬបន្ធូរបន្ថយទោស ក្នុងករណីមានការប្រព្រឹត្តអយុត្តិធម៌ (៧៤)។ ទោះបីជា គេមិនអាចនិយាយថាមាត្រានេះអនុវត្តចំពោះតែករណីបុគ្គលទទួលទោសប្រហារជីវិត ហើយមិនអនុវត្តសម្រាប់ករណីដទៃទៀតដូចជា ករណីបុគ្គលទទួលទោសដាក់ពន្ធនាគារមានរយៈពេលមិនកំណត់ ឬការបន្ធូរបន្ថយទោស និងការលើកលែងទោស ដោយផ្អែកលើមូលដ្ឋានផ្សេងៗទៀតដូចជា ការកែចរិតមារយាទបានល្អ វាជាការមិនត្រឹមត្រូវទេ ពីព្រោះការដាក់ពន្ធនាគារសុទ្ធសាធ គឺជាការកម្រិតសិទ្ធិមួយដែលត្រូវធ្វើឡើងក្នុងករណីចាំបាច់ និងប្រាស្រ័យសិទ្ធិ គឺជាវិធានទូទៅ។ គោលបំណងរបស់កតិកាសញ្ញា គឺដើម្បីការពារ និងធានាសិទ្ធិបុគ្គល ដូចនេះ ការលើកនូវភាពខ្វះខាតមិនបានចែង ឬចែងមិនគ្រប់ជ្រុងជ្រោយដើម្បីបដិសេធបុគ្គល អាចនឹងផ្ទុយគោលបំណងនេះ។ ការបកស្រាយរបៀបនេះ ក៏អាចនឹងនាំឲ្យមានការប្រព្រឹត្តមិនស្មើគ្នារវាងប្រភេទនៃទណ្ឌិត ហើយបើសិនជាគ្មានហេតុផលសមស្រប នោះនឹងនាំឲ្យរំលោភគោលការណ៍មិនរើសអើង ដែលចែងក្នុងកតិកាសញ្ញានេះផងដែរ។ បន្ថែមពីលើនេះ ការប្រព្រឹត្តខុសគ្នា អាចនឹងមិនសមស្របទៅនឹងគោលការណ៍ស្តានីតិសម្បទានៃប្រព័ន្ធដាក់ទណ្ឌកម្ម។

(៧២) មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

(៧៣ មាត្រា ០៧ នៃក្រមព្រហ្មទណ្ឌ ២០០៩

(៧៤) មាត្រា ១០ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបា

## ៣.២. សិទ្ធិទទួលបានការលើកលែង ឬបន្ធូរបន្ថយទោសក្រោមច្បាប់ជាតិ

មានបទប្បញ្ញត្តិ នៃច្បាប់ជាច្រើនរបស់កម្ពុជា ដែលចែងអំពីការលើកលែងទោស ឬបន្ធូរបន្ថយទោស ក្នុងនោះរួមមាន ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងច្បាប់ស្តីពីពន្ធនាគារឆ្នាំ ២០១១ ជាដើម។ ច្បាប់ទាំងនេះបានចែងនូវការលើកលែងទោសជាទូទៅ[៧៥] និងការលើកលែងទោសធម្មតាដោយ អង្គព្រះមហាក្សត្រ [៧៦]។ ហើយផ្អែកតាមស្មារតីមាត្រា ៧៧ នៃច្បាប់ស្តីពីពន្ធនាគារបានផ្តល់បុព្វសិទ្ធិដល់រាជរដ្ឋាភិបាល ក្នុងការស្នើសុំនៅពេលណាក៏បាន នូវការលើកលែងទោសដល់ទណ្ឌិត។ បន្ថែមពីនេះ លិខិតបទដ្ឋានគតិយុត្តក៏ អនុញ្ញាតឲ្យមានការបន្ធូរបន្ថយទោសផងដែរ។ ក្នុងករណីដែលពាក្យ "ទណ្ឌិត" សំដៅលើតែបុគ្គលដែលត្រូវបាន ប្រកាសថាមានទោស តាមរយៈសាលក្រមមិនទាន់ចូលជាស្ថាពរ វាមានន័យថា រាជរដ្ឋាភិបាលអាចធ្វើការស្នើលើក លែងទោសដល់អ្នកមិនទាន់មានទោសតាមអំណាចសាលក្រមចូលជាស្ថាពរហាក់មិនស៊ីសង្វាក់គ្នាជាមួយខ្លឹម សារមាត្រាដទៃទៀត ដែលអនុញ្ញាតឲ្យមានការលើកលែងទោស ឬបន្ថយទោស ក្នុងករណីអនុវត្តទោសក្នុងពន្ធនាគារ អស់រយៈពេលកំណត់មួយតាមរយៈសាលក្រមស្ថាពរ។ ក្នុងពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងការបន្ធូរបន្ថយ ឬការលើក លែងទោស។ ដោយអនុលោមតាមមាត្រា ១ មាត្រា២ និងមាត្រា៣ នៃក្រឹត្យលេខ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ១៩៨៨ បានចែងថា "ទណ្ឌិតត្រូវមានកិរិយាមារយាទល្អ ទទួលរងទោសចំនួន ២ ភាគ៣ នៃទោសដាក់ពន្ធនាគារមាន កំណត់ ឬទទួលទោសបាន ១៥ ឆ្នាំ ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទើបអាចសុំលើកលែងទោស"។ រីឯការ បន្ធូរបន្ថយទោស ក្រៅពីមានកិរិយាមារយាទល្អ ទណ្ឌិតត្រូវទទួលទោសបាន ១ភាគ៣ នៃទោសដាក់ពន្ធនាគារមាន កំណត់ ឬទទួលទោសបាន ១៥ឆ្នាំ ចំពោះទោសដាក់ពន្ធនាគារមួយជីវិត។ហើយ ទោសចន្លោះពី១ដល់ ១០ឆ្នាំ ទណ្ឌិត អាចទទួលបានការបន្ធូរបន្ថយទោសបាន ៦ (ប្រាំមួយ) ខែ ក្នុងពេលស្នើសុំម្តង។ទោសចន្លោះពី ១០ ដល់ ១៥ ឆ្នាំ អាច ទទួលបានការបន្ធូរបន្ថយទោសបាន ៩ (ប្រាំបួន) ខែ ក្នុងពេលស្នើសុំម្តង ហើយទោសចន្លោះពី ១៥ ដល់ ២០ ឆ្នាំ អាច ទទួលបានការបន្ធូរបន្ថយបាន ១២ (ដប់ពីរ) ខែម្តងក្នុងរយៈពេលមួយឆ្នាំ។ សម្រាប់ទណ្ឌិត ដែលជាប់ទោសក្នុង ពន្ធនាគារមួយជីវិតត្រូវទទួលបន្ថយទោសលើកទី១ ពីទោសមួយជីវិត មកត្រឹម ទោស២០ ឆ្នាំ។

បើយោងតាមកិខិតរបស់ក្រសួងយុត្តិធម៌ លេខ២៨២៖ "*ទណ្ឌិតណាដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដូចជា បទសម្លាប់មនុស្សដោយចេតនា សម្លាប់មនុស្សដោយចេតនាគិតទុកជាមុន បទរំលោភសេពសន្ថវៈរួចសម្លាប់ បទប្លន់ ប្រដាប់អាវុធ ឬប្រព្រឹត្តបទល្មើសជាបន្តបន្ទាប់មិនរាងចាល ...ជាពិសេសគឺបទឧក្រិដ្ឋ គួរគប្បីពិចារណាឲ្យបាន ច្បាស់លាស់ មិនគួរធ្វើសំណើសុំមកក្រសួងយុត្តិធម៌ សុំឲ្យដោះលែងដោយគ្មានលក្ខខណ្ឌ*

៧៥) មាត្រា ៩០ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ១៩៩៣

(៧៦) មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ១៩៩៣

*នោះឡើយ"* មានន័យថា លិខិតនេះមិនបានហាមឃាត់មិនឲ្យបន្ធូរបន្ថយទោស ឬលើកលែងទោសទេ។ ក្រៅពីមាត្រា ៧៧ ដែលចែងច្បាស់ពីស្ថាប័នដែលនឹងធ្វើសំណើលើកលែងទោស (រាជរដ្ឋាភិបាល) ជូនព្រះមហាក្សត្រ មាត្រាផ្សេងទៀត ពាក់ព័ន្ធនឹងការលើកលែង ឬបន្ធូរបន្ថយទោសមិនបានចែងហាមទណ្ឌិតធ្វើសំណើដាក់មកប្រធានពន្ធនាគារ ដើម្បីពិចារណាសំណើ និងបញ្ជូនបន្តទៅគណៈកម្មាធិការដើម្បីសម្រេចដាក់ជូនរាជរដ្ឋាភិបាលនោះទេ (៧៧)។ ដូចនេះ មានន័យថា គ្រប់ទណ្ឌិតទាំងអស់មានសិទ្ធិធ្វើសំណើសុំលើកលែង ឬបន្ធូរបន្ថយទោសបាន ក៏ប៉ុន្តែ ការសម្រេចព្រម ឬមិនព្រមជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច ដោយមានមូលដ្ឋានសមស្រម និងមិនរំលោភច្បាប់ដែលពាក់ព័ន្ធ។ ជាងនេះទៀតសោត តាមស្មារតីបញ្ញាតមាត្រា ៧៦ នៃច្បាប់ស្តីពី ពន្ធនាគារ ចែងថា *"[...] ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារស្នើសុំឲ្យសមីខ្លួន នោះសមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ... ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ"* ទាំងនេះសបញ្ជាក់ឲ្យឃើញថា ទណ្ឌិតមានសិទ្ធិក្នុងការដាក់សំណើផ្ទាល់៕

(៧៧) មាត្រា ៧៥ នៃ ច្បាប់ស្តីពីពន្ធនាគារ

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ក្រោយពីសង្គ្រាមលោកលើទី២ ត្រូវបានរលត់ផុតទៅ បានញ៉ាំងឲ្យមនុស្សជាតិទាំងឡាយ ទាមទារសិទ្ធិសេរីភាពរបស់ខ្លួន ដោយហេតុថា ឥទ្ធិពលនៃសង្គ្រាមបានធ្វើឲ្យពួកគេបាត់បង់សិទ្ធិក្នុងការរស់នៅ។ ជាក់ស្តែង មហាសន្និបាតអង្គការសហប្រជាជាតិ បានរកឃើញ និងធ្វើការតាក់តែងចងក្រងជាបទប្បញ្ញត្តិច្បាប់ ដើម្បីមូលដ្ឋានគ្រឹះក្នុងការរស់នៅរបស់មនុស្សជាតិទាំងឡាយ ពីព្រោះ បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពផ្ទាល់ខ្លួន ដោយរាប់បញ្ចូលទាំងជនជាប់ឃុំ ឬទណ្ឌិតផងដែរ។

នៅមុនអំឡុងឆ្នាំ១៩៨៩ ប្រទេសកម្ពុជា ជាប្រទេសមួយ ដែលធ្លាប់មានការដាក់ទោសប្រហារជីវិតទៅលើទណ្ឌិត។ ហើយដោយហេតុថាប្រទេសកម្ពុជា ជាប្រទេសដែលកាន់សាសនាព្រះពុទ្ធ ជាប្រទេសកាន់របបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ជាសមាជិកអាស៊ាន ហើយក៏ជាប្រទេសដែលមានបំណងយ៉ាងមុតមាំក្នុងការចង់លុបបំបាត់នូវទោសប្រហារជីវិតផងនោះ ទើបរហូតមកដល់អំឡុងឆ្នាំ១៩៨៩ ប្រទេសកម្ពុជា បានលុបចោលនូវទោសប្រហារជីវិត និងមានរយៈពេលយូររហូតមកដល់បច្ចុប្បន្ន។ កាលពីទស្សវត្តន៍កន្លងទៅ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តនៅក្នុងការលុបបំបាត់ចោលទោសប្រហារជីវិតដោយបានធ្វើការបោះឆ្នោតគាំទ្រសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការព្យួរទុកជាបណ្តោះអាសន្ន នូវការប្រើប្រាស់ទោសប្រហារជីវិត ដែលមានបញ្ញត្តិក្នុងមាត្រា ៣ និងមាត្រា ៤ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ដោយបានចែងថា ដើម្បីលុបចោលទោសប្រហារជីវិត "បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន និង គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តកម្មកាច សាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ។

ប៉ុន្តែដោយមួយរយៈពេលកន្លងមក នៅក្នុងពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជាជួបបញ្ហាកង្វះខាត កន្លែងស្នាក់នៅ ផ្នែកស្បៀងអាហារ ការអប់រំអនាម័យសុខភាព សម្លៀកបំពាក់ ជាពិសេស គឺមានការធ្វើទារុណកម្មលើរូបរាងកាយពីសំណាក់ទណ្ឌិតដូចគ្នា ឬពីសំណាក់មន្ត្រីពន្ធនាគារជាដើម ដែលផ្ទុយពី អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មដទៃទៀត ឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងពិធីសារបន្ថែម ។

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ២០០៨ នូវកម្មវិធីដ៏មុតមាំស្តីពីកំណែទម្រង់ប្រព័ន្ធពន្ធនាគាររបស់ខ្លួនដែលបានចង្អុរបង្ហាញយ៉ាងទូលាយដោយបញ្ញត្តិបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងជនជចាប់ឃុំនិងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធដទៃទៀត។ការគោរពសិទ្ធិមនុស្សនៅក្នុងពន្ធនាគារ គឺត្រូវពឹងផ្អែកលើតម្លៃស្នូលនៃការគ្រប់គ្រងពន្ធនាគារឲ្យបានល្អតាមរយៈការប្រាស្រ័យទាក់ទងការងារប្រចាំថ្ងៃរវាងមន្ត្រីពន្ធនាគារ និងជនជាប់ឃុំ ឬទណ្ឌិត ពីព្រោះការគោរពសិទ្ធិរបស់ជនជាប់ឃុំ ជាសិទ្ធិទាំងឡាយ

ដែលជនជាប់ឃុំគ្រប់រូបត្រូវតែទទួលបាន បើទោះបីជាជនទាំងនោះស្ថិតនៅក្នុងពន្ធនាគារក៏ដោយ។ បន្ថែមពីនេះ លិខិតតុបករណ៍សំខាន់ៗស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាសន្ធិសញ្ញាដែលចងក្រងកាតព្វកិច្ចតាមផ្លូវច្បាប់ទៅបណ្តារដ្ឋទាំងអស់ដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកក្នុងសន្ធិសញ្ញាទាំងនេះ។ ដូចនេះ វាជាការចាំបាច់ និងជារឿងដ៏សំខាន់ដែល ជនជាប់ឃុំគ្រប់រូបត្រូវតែយល់ដឹង និងត្រូវទទួលបានសិទ្ធិរបស់ខ្លួន ក្នុងអំឡុងពេលអនុវត្តទោស។ យ៉ាងណាមិញ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ប្រទេសកម្ពុជា បានអនុម័ត ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងរដ្ឋបរទេសដែលធ្វើសំណើទាំងអស់ ទោះបីជារដ្ឋធ្វើសំណើនោះមិនមានកិច្ចព្រមព្រៀងជាមួយនឹងប្រទេសកម្ពុជាក៏ដោយ។ទាំងអស់នេះ សបញ្ជាក់ឲ្យឃើញថា បើទោះបីជាជនជាប់ឃុំត្រូវបានដកហូតសិទ្ធិសេរីភាពមួយចំនួនក៏ដោយ ក៏ពួកគេនៅតែមានសិទ្ធិដែរផ្តល់ឲ្យយ៉ាងសមរម្យសម្រាប់ការរស់រាននៅក្នុងពេលជាប់ឃុំ និង ពេលអនុវត្តទោសក្នុងពន្ធនាគារ។

# អនុសាសន៍

# អនុសាសន៍

នៅប្រទេសកម្ពុជា ជាង ៧០% នៃចំនួនអ្នកជាប់ពន្ធនាគារជិត ៤០,០០០ នាក់ គឺជាអ្នកដែល រង់ចាំសាលក្រមចូលជាស្ថាពរ និងជាប់ឃុំបណ្តោះអាសន្ន ប៉ុន្តែត្រូវបានជាប់ក្នុងទីដែលខ្វះអនាម័យ និងណែនចង្អៀតដូចអ្នកទោសនានាដែរ។ ហើយក្នុងពេលបច្ចុប្បន្ននេះ ក្រសួងយុត្តិធម៌បានដាក់បន្ទុកលើចំនួនអ្នកជាប់ពន្ធនាគារ ទៅលើការកកស្ទះសំណុំរឿងនៅតុលាការ និងបានចាប់ផ្តើមយុទ្ធនាការដោះស្រាយ ចាប់តាំងពីខែឧសភា ឆ្នាំ២០២០ មកម្ល៉េះ។ ម្យ៉ាងវិញទៀត ដោយគិត្រឹមបំណាច់ឆ្នាំ ២០២០ គឺតុលាការបានដោះស្រាយបានចំនួន ៣៥,១០០ នៃចំនួនសំណុំរឿងព្រហ្មទណ្ឌចាស់ប្រមាណជិត ៤០.០០០ ដែលបានកកស្ទះ។ ថ្វីត្បិតតែ ដំណើរការនៃការនុវត្តទោសរបស់ជនជាប់ឃុំ ឬទណ្ឌិត ប្រព្រឹត្តទៅបានយ៉ាងរលូនយ៉ាងណាក្តី ប៉ុន្តែដោយហេតុថា មានចំនួនអ្នកទោសច្រើនហួសចំណុះដូចនេះគួរគម្បីះ

- ចាត់វិធានការ ដើម្បីកាត់បន្ថយចំនួនអ្នកជាប់ឃុំឃាំងជាបណ្តោះអាសន្ន តាមរយៈការពន្លឿននីវិធីតុលាការ។
- ធានាថាប្រធានពន្ធនាគារបំពេញនូវការទទួលខុសត្រូវរបស់ខ្លួនក្នុងការជូនដំណឹងទៅតុលាការអំពីការផុតរយៈពេលឃុំខ្លួនបណ្តោះអាសន្ន។
- ពិនិត្យទៅលើមធ្យោបាយផ្សេងទៀត ដែលជាជម្រើសសម្រាប់ការដាក់ទណ្ឌកម្ម ហើយពិចារណាឡើងវិញទៅលើរយៈពេលនៃទោសជាប់ពន្ធនាគារ សម្រាប់បទល្មើសតូចតាច។
- ផ្តល់អាទិភាពដល់ការងារសាងសង់ និងជួសជុលកែលអរឡើងវិញ ចំពោះពន្ធនាគារដែលមានភាពចំណាស់ និងកង្វះជាសុភាព។

**ម្ហូបអាហារ និងទឹក**

- គ្រប់គ្រងចាត់ចែងថវិកាឲ្យបានល្អប្រសើរឡើងថែមទៀត ដើម្បីធានាថាមិនមានការដកយកថវិកាសម្រាប់អាហារឧបត្ថម្ភអ្នកទោស ទៅចំណាយលើសម្ភារៈ ឬសេវាផ្សេងៗទៀតឡើយ ហើយត្រូវត្រួតពិនិត្យមើលដើម្បីថារបបអាហារដែលមានតម្លៃអប្បបរមា ១០០០ រៀល បានដល់អ្នកទោសម្នាក់ៗជារៀងរាល់ថ្ងៃដោយមិនត្រូវឲ្យបាត់បង់ទៅលើអំពើពុកលួយឡើយ។
- ធានាផ្តល់ឲ្យបានទៀងទាត់នូវទឹកស្អាតសម្រាប់ផឹក នៅគ្រប់ពន្ធនាគារទាំងអស់ ដោយផ្តល់អាទិភាពឲ្យពន្ធនាគារនៅតាមបណ្តាខេត្តឆ្ងាយៗ ដូចជា ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ ជាអាទិ៍។

**សុខភាព និងសេវាពេទ្យ**

- ធានាថា ប្រាក់ដែលត្រូវចំណាយទៅលើអ្នកទោស និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានទទួលទាន់ពេលវេលា និងគ្រប់ចំនួនតាមរយៈការផ្ទេរដោយផ្ទាល់ពីនាយកដ្ឋានហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ទៅរតនាគារតាមខេត្ត។

- បង្កើតគោលនយោបាយសម្រាប់អ្នកទោសដែលមានជំងឺអេដស៍ និងធ្វើការលើកលែងទោសដល់អ្នកកើតជំងឺទាំងឡាយណា ដែលស្ថិតក្នុងស្ថានភាពចុងក្រោយនៃជំងឺអេដស៍។

**រដ្ឋបាលពន្ធនាគារ**

- ធានាថា ពន្ធនាគារត្រូវមានថវិកាគ្រប់គ្រាន់ និងស្របទៅតាមគម្រោងជាពិសេសតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រី និងឆ្មាំពន្ធនាគារ ផ្តល់ប្រាក់បៀវត្សរ៍សមស្របអាចឲ្យពួកគេផ្គត់ផ្គង់ជីវភាពសរនៅ និងកន្លែងស្នាក់នៅសមរម្យ។

- ធានាថា បុគ្គលិករដ្ឋបាលនៃពន្ធនាគារនីមួយៗ មានចំនួនសមាមាត្រទៅនិងចំនួនអ្នកទោស។

- ធានាការផ្តល់ឲ្យមានឆ្មាំពន្ធនាគារជាស្ត្រី សម្រាប់អ្នកទោសជាស្ត្រី។

**ការគំរាមកំហែងដល់សុវត្ថិភាព**

- ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីដាក់អ្នកទោសទៅតាម ភេទ អាយុ (ក្មេង ឬមនុស្សពេញវ័យ) ឋានៈខាងផ្លូវច្បាប់( ពិរុទ្ធជន ឬទណ្ឌិត) ភាពធ្ងន់ធ្ងរនៃបទល្មើស និងស្ថានភាពខាងសុខភាព។

- នាំមកកាត់ទោសជនទាំងឡាយណា ដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម ហើយត្រូវបានតុលាការអាចធ្វើសេចក្តីសម្រេច ដោយសេរីភាពគ្មានការគាបសង្កត់ពីបុគ្គលណាម្នាក់។

- ហាមប្រើប្រាស់អ្នកទោសដែលខ្លួនចូលចិត្ត និង ជាមេបន្ទប់

- គោរពបទបញ្ញត្តិច្បាប់ទាក់ទងនិងការប្រើប្រាស់ឧបករណ៍ទប់ទល់នឹងអ្នកទោស ដោយធានាថា ខ្នោះដៃត្រូវបានប្រើប្រាស់តែក្នុងពេលដឹកជញ្ជូនអ្នកទោស ឬក្នុងស្ថានការណ៍បន្ទាន់ណាមួយ ហើយការប្រើប្រាស់ខ្នោះជើយ ត្រូវបានលុបបំបាត់ចោល។

**សិទ្ធិខាងផ្លូវច្បាប់**

- បង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។
- ធានាថា អ្នកទោសត្រូវបានផ្តល់ឲ្យនូវសម្លៀកបំពាក់ស៊ីវិលនៅពេលបង្ហាញខ្លួននៅតុលាការ។
- ទប់ស្កាត់ការបើកសវនាការកំបាំងមុខ ចំពោះអ្នកទោសដែលស្ថិតនៅក្នុងមន្ទីរឃុំឃាំង ហើយមិនអាចចូលរួមសវនាការបាន ដោយសារខ្វះមធ្យោបាយដឹងជញ្ជូន។
- ដោះលែងជាបន្ទាន់ អ្នកទោសដែលកំពុងរង់ចាំសវនាការនៅសាលាឧទ្ធរណ៍ ហើយដែលបានអនុវត្តទោសចប់សព្វគ្រប់ហើយ។

# ឯកសារយោង

# ឯកសារយោង

## ក្រឹត្យច្បាប់

- ក្រឹត្យច្បាប់លេខ ២៨ ក្រ. ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស។

## ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៣០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស។

## អនុក្រឹត្យ

- ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៣០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស។
- អនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងការលើកលែងទោស។
- អនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា។
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពី ការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត។

## ប្រកាសព្រឹត្តិបត្រ

- ព្រឹត្តិបត្រមេធាវីលេខ ១៣ ចុះខែមេសា -មិថុនា ឆ្នាំ២០១៧ ស្តីពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

## អនុសញ្ញា

-អនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងកុងស៊ុល។

-ក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ២០០៧

-ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ២០០៧

## សៀវភៅបោះពុម្ពគេហទំព័រ

-World Prison Brief data -khmer.voanews.

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

នស/រកម/០៨០៩/០១៤

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃ សាធារណរដ្ឋឥណ្ឌាស្ដីពីការផ្ទេរទណ្ឌិត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំ [illegible] ហើយដែលមានសេចក្ដីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាស្តីពីការផ្ទេរទណ្ឌិត

**មាត្រា ១.–**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្តីពីការផ្ទេរទណ្ឌិត ដែលធ្វើនៅញូវដែលី នាថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

នស.រកម.០៨០៩.០៣៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា
ស ខេង

លេខ: ៧៦៤ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

## កិច្ចព្រមព្រៀង
## រវាង
## រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា
## ស្តីអំពីការផ្ទេរទណ្ឌិត

**រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាដែលហៅថា**

**"រដ្ឋភាគីលេខី"**

- **ដោយមានបំណង**ជួយសម្រួលការស្តារនីតិសម្បទាសង្គមនៃទណ្ឌិតទាំងឡាយ នៅក្នុងប្រទេសរបស់ជនទាំងនោះ និង
- **ដោយបានពិចារណាឃើញថា** គោលបំណងនេះអាចសម្រេចទៅបាន ដោយផ្តល់អោយជនបរទេសទាំងឡាយដែលត្រូវបានផ្តន្ទាទោស និងដាក់ទោសរួចហើយ ដោយសារការប្រព្រឹត្តបទល្មើសឧក្រិដ្ឋរបស់ជននោះ ដើម្បីមានឱកាសទៅទទួលទោសនៅក្នុងសង្គមរបស់ខ្លួន ។

**បានព្រមព្រៀងដូចតទៅ :**

### មាត្រា ១
### និយមន័យ

**សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

ក- **"ការវិនិច្ឆ័យ"** មានន័យថា ជាសេចក្តីសម្រេច ឬ ជាដីកាបង្គាប់របស់តុលាការ ឬ របស់សាលាជំរះក្តី ដែលកំណត់ការដាក់ទណ្ឌកម្ម ។

ខ- **"រដ្ឋទទួល"** មានន័យថា ជារដ្ឋដែលមានទណ្ឌិតអាចត្រូវបានផ្ទេរ ឬ ត្រូវបានផ្ទេរ ដើម្បីឱ្យទណ្ឌិតនោះទទួលទោសបន្ត ។

គ- **"ការដាក់ទោស"** មានន័យថា ជាការដាក់ទណ្ឌកម្ម ឬ វិធានការណាមួយដែលពាក់ព័ន្ធដល់ការដក- ហូតសេរីភាពមានថេរវេលាកំណត់ ឬ ការដាក់ពន្ធនាគារអស់មួយជីវិតបង្គាប់ដោយតុលាការ ឬ សាលាជំរះក្តីក្នុងការអនុវត្តន៍យុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួន ។

ឃ- **"ទណ្ឌិត"** មានន័យថា ជាជនដែលកំពុងទទួលទោសឱ្យជាប់ពន្ធនាគារ ក្រោមដីកាបង្គាប់ដោយតុលាការព្រហ្មទណ្ឌ រួមមានតុលាការទាំងឡាយដែលត្រូវបង្កើតឡើងដោយច្បាប់សម្រាប់រយៈពេលមួយ នៅក្នុងរដ្ឋហត្ថលេខី ។

CS Scanned with CamScanner

ង- "រដ្ឋផ្ទេរ" មានន័យថា ជារដ្ឋដែលបានដាក់ទោសទៅលើជនដែលអាចនឹងត្រូវបានផ្ទេរ ឬ ត្រូវបានផ្ទេររួចហើយ ។

## មាត្រា ២

## គោលការណ៍ទូទៅ

១- ជនណាដែលបានកាត់ទោសនៅក្នុងទឹកដីនៃរដ្ឋហត្ថលេខីមួយ អាចត្រូវបានផ្ទេរទៅកាន់ដែនដីនៃរដ្ឋហត្ថលេខីមួយទៀត ស្របទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដើម្បីឱ្យជននោះទទួលទោសដែលបានដាក់ចំពោះខ្លួន ។ ចំពោះរឿងនេះ ជននោះអាចបញ្ជាក់ជូនរដ្ឋជាអ្នកផ្ទេរ ឬ រដ្ឋជាអ្នកទទួល នូវបំណងរបស់ខ្លួនអំពីការស្នើសុំផ្ទេរ ក្រោមកិច្ចព្រមព្រៀងនេះ ។

២- ការផ្ទេរខ្លួន អាចត្រូវបានស្នើឡើងដោយទណ្ឌិតណាមួយ ដែលជាជនជាតិនៃរដ្ឋហត្ថលេខី ឬ ដោយជនដទៃណាម្នាក់ដែលមានសិទ្ធស្នើសុំក្នុងនាមទណ្ឌិត ស្របទៅតាមច្បាប់នៃរដ្ឋហត្ថលេខី ដោយដាក់ពាក្យស្នើសុំទៅកាន់រដ្ឋហត្ថលេខី និងទៅតាមលំនាំដែលកំណត់ដោយរដ្ឋាភិបាលនៃរដ្ឋហត្ថលេខី ។

## មាត្រា ៣

## លក្ខខណ្ឌនៃការផ្ទេរទណ្ឌិត

១- ទណ្ឌិតអាចត្រូវបានផ្ទេរយោងទៅតាមកិច្ចព្រមព្រៀងនេះ តាមតែលក្ខខណ្ឌដូចតទៅ:

ក- ទណ្ឌិតនោះជាសញ្ជាតិនៃរដ្ឋទទួល

ខ- ទណ្ឌិតនោះមិនត្រូវបានកាត់ទោសប្រហារជីវិត

គ- ការវិនិច្ឆ័យទោសរបស់តុលាការ ត្រូវបានចូលជាស្ថាពរ

ឃ- គ្មានការស៊ើបសួរ គ្មានការបើកសវនាការ ឬ នីតិវិធីណាផ្សេងទៀត ដែលត្រូវរង់ចាំយកមកអនុវត្តទៅលើទណ្ឌិត នៅក្នុងរដ្ឋជាអ្នកផ្ទេរ ។

ង- នៅពេលទទួលសំណើសុំផ្ទេរ ទណ្ឌិតត្រូវសល់ទោសយ៉ាងតិចបំផុត ៦ខែទៀត ឬ ត្រូវជាប់ពន្ធនាគារអស់មួយជីវិត

ច- សកម្មភាព ឬ ការខកខានមិនបានបំពេញកាតព្វកិច្ចដែលបណ្តាលអោយជាប់ទោសនៅក្នុងរដ្ឋផ្ទេរ គឺជាអំពើ ដែលនាំអោយមានទោសឧក្រិដ្ឋនៅក្នុងរដ្ឋទទួល ឬ អាចជាបទល្មើសព្រហ្មទណ្ឌ ប្រសិនបើប្រព្រឹត្តនៅក្នុងដែនដីរបស់រដ្ឋទទួល ។

ឆ- ទណ្ឌិតមិនត្រូវបានកាត់ទោសពីបទល្មើសដោយច្បាប់យោធា

ជ- ការផ្ទេរការឃុំឃាំងទណ្ឌិតទៅអោយរដ្ឋទទួល មិនត្រូវធ្វើអោយប៉ះពាល់ដល់អធិបតេយ្យភាព សន្តិសុខ ឬ ផលប្រយោជន៍ណាមួយរបស់រដ្ឋផ្ទេរឡើយ

Scanned with CamScanner

ឈ- ការយល់ព្រមផ្ទេរត្រូវមានការឯកភាពពីទណ្ឌិតនោះ ឬ ពីជនណាផ្សេង ដែលជាតំណាងស្របច្បាប់ យោង ទៅតាមច្បាប់នៃរដ្ឋហត្ថលេខីនោះ ក្នុងករណីដែលទណ្ឌិតមានបញ្ហាអាយុ ឬ បញ្ហាកាយសម្បទា ឬ ជម្ងឺសរសៃប្រសាទដែលរដ្ឋហត្ថលេខី គិតថាចាំបាច់ ហើយ

៣- រដ្ឋផ្ទេរ និង រដ្ឋទទួលត្រូវឯកភាពគ្នាចំពោះការផ្ទេរ ។

២- ក្នុងករណីពិសេស រដ្ឋផ្ទេរ និង រដ្ឋទទួល ក៏អាចសំរុះសំរួលគ្នាដើម្បីធ្វើការផ្ទេរទណ្ឌិត ទោះបីជា ថេរវេលាដែល នៅសេសសល់ដើម្បីទទួលទោសមានរយៈពេលតិចជាង ៦ខែ ក៏ដោយ ។

## មាត្រា ៤

## ភារកិច្ចក្នុងការផ្តល់ព័ត៌មាន

១- ប្រសិនបើទណ្ឌិតបានសំដែងបំណងចំពោះរដ្ឋជាអ្នកកាត់ទោស ចង់អោយមានការផ្ទេររូបខ្លួន សមស្របតាម កិច្ចព្រមព្រៀងនេះ រដ្ឋផ្ទេរត្រូវបញ្ជូនព័ត៌មាន និង ឯកសារដូចខាងក្រោមនេះ ទៅអោយរដ្ឋទទួល វៀរលែងតែរដ្ឋផ្ទេរ ឬ រដ្ឋទទួលបានសំរេចរួចទៅហើយថា គេមិនយល់ព្រម ចំពោះការផ្ទេរនោះទេ :

ក- ឈ្មោះ និង សញ្ជាតិ កាលបរិច្ឆេទ និង ទីកន្លែងកំណើតរបស់ទណ្ឌិត

ខ- អាស័យដ្ឋានរបស់ទណ្ឌិត ប្រសិនបើមាននៅក្នុងរដ្ឋទទួល

គ- របាយការណ៍ស្តីអំពីបទល្មើសដែលតម្រូវអោយដាក់ទណ្ឌកម្ម

ឃ- ប្រភេទ រយៈពេល និងកាលបរិច្ឆេទចាប់ផ្តើមនៃទោស

ង- ច្បាប់ចំលងនៃការវិនិច្ឆ័យដែលបញ្ជាក់ជាផ្លូវការ និង ច្បាប់ចំលងនៃបទញ្ញត្តិរបស់ច្បាប់ពាក់ព័ន្ធ ដែល បានពោលយោងសំរាប់ផ្តន្ទាទោសទណ្ឌិត

ច- របាយការណ៍ផ្នែកវេជ្ជសាស្ត្រ សង្គម ឬព័ត៌មាននានាស្តីពីទណ្ឌិត ទៅតាមតម្រូវការដើម្បីចាត់ការ ចំពោះពាក្យសុំរបស់ទណ្ឌិត ឬដើម្បីធ្វើការសំរេចលើប្រភេទនៃការឃុំឃាំងចំពោះទណ្ឌិត ។

ឆ- ព័ត៌មានដទៃទៀតដែលរដ្ឋទទួល អាចនឹងបញ្ជាក់ថាខ្លួនត្រូវការសំរាប់គ្រប់ករណី ដើម្បីអាចពិចារណា ពីលទ្ធភាពទទួលយកការផ្ទេរ និង ផ្តល់ដំណឹងអោយទណ្ឌិតបានដឹងអំពីផលវិបាកនៃការផ្ទេរ ដោយអនុលោមតាមច្បាប់របស់ខ្លួន

ជ- សំណូមពរស្នើសុំផ្ទេរខ្លួនរបស់ទណ្ឌិត ឬ របស់ជនដែលមានសិទ្ធលើកសំណើក្នុងនាមទណ្ឌិត អនុលោម តាមច្បាប់របស់រដ្ឋផ្ទេរ និង

ឈ- របាយការណ៍ដែលបញ្ជាក់ពីរយៈពេលផ្តន្ទាទោសដែលទណ្ឌិតបានបំពេញរួចហើយ រួមទាំងពត៌មានស្តីពី ការឃុំឃាំងមុនពេលបើកសវនាការ ការបន្ធូរបន្ថយទោស ឬ កត្តាដទៃផ្សេងៗ ទាក់ទងដល់ការ

អនុវត្តន៍ សាលក្រម ។

២- ក្នុងគោលបំណងជួយដល់ការធ្វើសេចក្តីសំរេចលើសំណូមពរតាមកិច្ចព្រមព្រៀងនេះ រដ្ឋទទួលត្រូវ បញ្ជូនពត៌មាន និង ឯកសារដូចតទៅនេះទៅអោយរដ្ឋផ្ទេរ វៀរលែងតែរដ្ឋទទួល ឬ រដ្ឋផ្ទេរបានសំរេចរួចហើយថា នឹងមិនយល់ព្រមចំពោះការផ្ទេរនោះទេ :

ក- សេចក្តីរៀបរាប់ ឬ ឯកសារដែលបញ្ជាក់ថាទណ្ឌិតជាសញ្ជាតិរបស់រដ្ឋទទួល

ខ- ច្បាប់ចំលងនៃច្បាប់ពាក់ព័ន្ធរបស់រដ្ឋទទួលដែលចែងពីសកម្មភាព ឬការខកខានមិនបានបំពេញកាតព្វកិច្ច ដែលដោយសារហេតុផលនេះ ទើបមានការវិនិច្ឆ័យទោសនៅក្នុងរដ្ឋផ្ទេរ បើសកម្មភាព ឬ ការខកខានបំពេញកាតព្វកិច្ចនោះ ក៏ជាបទល្មើសយោងតាមច្បាប់របស់រដ្ឋទទួល ឬក៏អាចកំណត់ថាជាបទល្មើស ប្រសិនបើបានប្រព្រឹត្តនៅលើទឹកដីរបស់រដ្ឋទទួល

គ- សេចក្តីរៀបរាប់ពីអនុភាពរបស់ច្បាប់ ឬ បទបញ្ញត្តិដែលទាក់ទងនឹងរយៈពេលនិងការអនុវត្តន៍សាលក្រមនៅក្នុងរដ្ឋទទួលបន្ទាប់ពីការផ្ទេរខ្លួនទណ្ឌិត ហើយបើសិនជាអាចអនុវត្តបានត្រូវមានទាំងសេចក្តីរៀបរាប់ពីអនុភាពនៃវគ្គខ័ណ្ឌ ២ មាត្រា ៨ នៃកិច្ចព្រមព្រៀង នេះ ស្តីពីការផ្ទេរទណ្ឌិត

ឃ- ឆន្ទៈរបស់រដ្ឋទទួល ក្នុងការឯកភាពលើការផ្ទេរទណ្ឌិត និងការទទួលរ៉ាប់រងចាត់ចែងអនុវត្តទណ្ឌកម្ម ដែលនៅសេសសល់ចំពោះទណ្ឌិត និង

ង- ពត៌មាន និងឯកសារដទៃទៀត ដែលរដ្ឋផ្ទេរអាចយល់ឃើញថាជាការចាំបាច់ ។

## មាត្រា ៥

## សំណើសុំ និង ការឆ្លើយតប

១- សំណើសុំផ្ទេរទណ្ឌិតត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ តាមបែបបទដែលបានកំណត់រួចហើយ និង បញ្ជូនតាមរយៈអាជ្ញាធរកណ្តាលរបស់រដ្ឋជាអ្នកផ្ទេរ តាមផ្លូវការទូតទៅកាន់អាជ្ញាធរកណ្តាលរបស់រដ្ឋដែលត្រូវទទួល ។ ការឆ្លើយតបត្រូវបញ្ជូនតាមបណ្តាញដូចគ្នានេះ ។

២- ចំពោះគោលបំណងនៃកថាខ័ណ្ឌទី ១ នៃមាត្រានេះ អាជ្ញាធរកណ្តាលរបស់ឥណ្ឌា គឺក្រសួងកិច្ចការផ្ទៃក្នុង និង អាជ្ញាធរកណ្តាលរបស់ប្រទេសកម្ពុជា គឺក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ។

៣- រដ្ឋដែលត្រូវបានគេស្នើសុំ ត្រូវផ្តល់ពត៌មានជាបន្ទាន់ទៅឱ្យរដ្ឋជាអ្នកស្នើអំពីការសំរេចរបស់ខ្លួន ថាតើយល់ព្រមឬក៏មិនយល់ព្រមចំពោះការផ្ទេរទណ្ឌិតនេះ ។

## មាត្រា ៦

## ការយល់ព្រម និង ការបញ្ជាក់ពីការយល់ព្រម

Scanned with CamScanner

១- រដ្ឋផ្ទេរត្រូវធានាថា ការផ្ទេរនោះគឺធ្វើឡើងដោយមានការយល់ព្រមពីទណ្ឌិតចំពោះការផ្ទេរខ្លួន ដែលស្របតាមកថាខណ្ឌ ១ ចំណុច (ឃ) មាត្រា ៣ នៃកិច្ចព្រមព្រៀងនេះ ត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត និងដោយការយល់ដឹងពេញលេញ អំពីផលវិបាកនៃច្បាប់តទៅថ្ងៃក្រោយ។ នីតិវិធីក្នុងការផ្តល់ការយល់ព្រមបែបនេះ នឹងត្រូវធ្វើទៅតាមច្បាប់របស់រដ្ឋផ្ទេរ ។

២- រដ្ឋផ្ទេរត្រូវលៃលកផ្តល់ឱកាសអោយរដ្ឋជាអ្នកទទួលដើម្បីបានបញ្ជាក់ថា ការយល់ព្រមនោះត្រូវបានផ្តល់ឱ្យសមស្របទៅតាមល័ក្ខខ័ណ្ឌចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

## មាត្រា ៧·

## បច្ច័យនៃការផ្ទេរសំរាប់រដ្ឋទទួល

១- អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋទទួលត្រូវបន្តអនុវត្តការដាក់ទណ្ឌកម្ម តាមរយៈការបញ្ជាផ្នែកតុលាការ ឬ ផ្នែករដ្ឋបាលតាមដែលច្បាប់ជាតិរបស់ខ្លួនតម្រូវ យោងទៅតាមល័ក្ខខ័ណ្ឌចែងក្នុងមាត្រា ៨ នៃកិច្ចព្រម ព្រៀងនេះ ។

២- ផ្អែកទៅលើបទបញ្ញត្តិចែងក្នុងមាត្រា ១០ នៃកិច្ចព្រមព្រៀងនេះ ការអនុវត្តដាក់ទណ្ឌកម្មនឹងត្រូវគ្រប់គ្រងដោយច្បាប់របស់រដ្ឋទទួល ហើយរដ្ឋនេះតែម្នាក់ឯងមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសំរេចសមស្របនានា ។

## មាត្រា ៨

## ការបន្តអនុវត្តន៍សាលក្រម

១- រដ្ឋទទួលត្រូវអនុវត្តតាមចរិកតតិយុត្តិ និងទម្ងន់ទោស ដែលរដ្ឋផ្ទេរបានសំរេចហើយ ។

២- ទោះជាយ៉ាងណា បើសិនជាសាលក្រមមានចរិកតតិយុត្តិ និងទម្ងន់ទោស ឬ លក្ខណៈទាំងពីរប្រភេទនេះ មិនសមស្របទៅតាមច្បាប់របស់រដ្ឋទទួល ឬ ច្បាប់របស់រដ្ឋទទួលត្រូវការដូច្នោះ រដ្ឋនោះអាចយកលំនាំតាមសាលក្រម ឬ វិធានការដែលមានចែងក្នុងច្បាប់របស់ខ្លួន តាមបទបញ្ជាតុលាការ ឬ នីតិវិធីតាមផ្លូវរដ្ឋបាល ។ ដោយចរិកតតិយុត្តិ និង ទម្ងន់ទោសរបស់វា ការដាក់ទណ្ឌកម្ម ឬ វិធានការនានា ត្រូវធ្វើតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីអោយស៊ីគ្នាជាមួយនឹងការវិនិច្ឆ័យ ដែលរដ្ឋផ្ទេរបានសំរេចហើយ ។ ទោះបីយ៉ាងណា ដោយចរិកតតិយុត្តិ និង ទម្ងន់ទោសរបស់ខ្លួន រដ្ឋទទួលមិនត្រូវបន្ថែមស្ថានទម្ងន់ទោស ទៅលើសាលក្រមដែលត្រូវបានកំណត់រួចហើយនៅក្នុងរដ្ឋផ្ទេរឡើយ ។

## មាត្រា ៩

## បច្ច័យនៃការទទួលទោសចប់សព្វគ្រប់សំរាប់រដ្ឋផ្ទេរ

កាលណារដ្ឋទទួលបញ្ជាក់ប្រាប់រដ្ឋផ្ទេរតាមវាក្យខ័ណ្ឌ ១(ក) នៃមាត្រា១២ នៃកិច្ចព្រមព្រៀង នេះថាទោសត្រូវបានទទួលចប់សព្វគ្រប់ហើយ ការបញ្ជាក់បែបនេះមានប្រសិទ្ធិភាពនៃការរួចទោសនៅក្នុងរដ្ឋផ្ទេរហើយ ។

Scanned with CamScanner

## មាត្រា ១០

## ការអនុគ្រោះទោស ការលើកលែងទោស ឬ ការបូរទោស និង បណ្តឹងសើរើចំពោះការវិនិច្ឆ័យ

១- រដ្ឋផ្ទេរទណ្ឌិត អាចនឹងសំរេចចំពោះពាក្យស្នើសុំអោយសើរើការវិនិច្ឆ័យ ។

២- រដ្ឋណាមួយនៃរដ្ឋហត្ថលេខី អាចផ្តល់ការអនុគ្រោះទោស ការលើកលែងទោស ឬ ការបូរទោស អនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗរបស់ខ្លួន ។

## មាត្រា ១១

## ការបញ្ចប់ការអនុវត្តន៍សាលក្រម

រដ្ឋទទួលត្រូវបញ្ចប់ការអនុវត្តន៍សាលក្រមភ្លាម នៅពេលដែលបានទទួលពត៌មាន ពីរដ្ឋផ្ទេរ ស្តីពីការសំរេច ឬ វិធានការនានា ទាក់ទងទៅនឹងការបញ្ចប់ការអនុវត្តន៍សាលក្រម ។

## មាត្រា ១២

## ពត៌មានស្តីពីការអនុវត្តន៍សាលក្រម

១- រដ្ឋទទួលត្រូវបញ្ជាក់ជូនរដ្ឋផ្ទេរ :

ក- កាលណាការអនុវត្តន៍សាលក្រមត្រូវបានបញ្ចប់ ឬ

ខ- ប្រសិនបើទណ្ឌិតរត់ពីការឃុំឃាំងមុនពេលការអនុវត្តន៍សាលក្រមត្រូវបានបញ្ចប់ ក្នុងករណីបែបនេះ រដ្ឋទទួលត្រូវចាត់វិធានការចាប់ខ្លួនទណ្ឌិត និងដាក់ឱ្យទទួលខុសត្រូវពីការប្រព្រឹត្តបទល្មើសនេះ តាមច្បាប់ពាក់ព័ន្ធរបស់រដ្ឋទទួល ។

២- រដ្ឋទទួលត្រូវផ្តល់របាយការណ៍ពិសេសទាក់ទងទៅនឹងការអនុវត្តន៍សាលក្រម ប្រសិនបើរដ្ឋផ្ទេរមានស្នើសុំ ។

## មាត្រា ១៣

## ដំណើរឆ្លងកាត់

ប្រសិនបើរដ្ឋហត្ថលេខីណាមួយចាត់ការរៀបចំផ្ទេរទណ្ឌិតជាមួយរដ្ឋទីពា រដ្ឋហត្ថលេខីមួយទៀត ត្រូវសហការដើម្បីសំរួលដំណើរឆ្លងកាត់ តាមរយៈទឹកដីនៃទណ្ឌិតដែលត្រូវបានផ្ទេរ លើកលែងតែរដ្ឋហត្ថលេខីមួយ ទៀតនោះអាចបដិសេធការឆ្លងកាត់ចំពោះទណ្ឌិតណាដែលជាសញ្ជាតិរបស់ខ្លួន ។ រដ្ឋហត្ថលេខីដែលមានបំណងធ្វើការផ្ទេរបែបនេះ ត្រូវជូនដំណឹងជាមុនទៅរដ្ឋហត្ថលេខីមួយទៀត អំពីដំណើរឆ្លងកាត់បែបនេះ ។

Scanned with CamScanner

## មាត្រា ១៤

### ការចំណាយ

រាល់ការចំណាយក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវជាបន្ទុករបស់រដ្ឋទទួល លើកលែងតែការចំណាយដោយឡែកផ្សេងៗនៅក្នុងទឹកដីរបស់រដ្ឋផ្ទេរ ។ យ៉ាងណាក៏ដោយ រដ្ឋទទួលស្វែងរកឱ្យមានការចំណាយទាំងស្រុង ឬជាចំណែកខ្លះពីទណ្ឌិត ឬ ពីប្រភពដទៃទៀត ។

## មាត្រា ១៥

### ការអនុវត្តន៍នៅលើទឹកដី

១- កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះ :

ក- សាធារណរដ្ឋឥណ្ឌា និង

ខ- ព្រះរាជាណាចក្រកម្ពុជា

ព្រមទាំងស្ថាប័ន និង អង្គភាពចំណុះទឹកដីរបស់រដ្ឋហត្ថលេខី ក៏ត្រូវបានបកស្រាយតាមបែបដូច្នេះដែរ ។

២- ការអនុវត្តន៍កិច្ចព្រមព្រៀងនេះចំពោះទឹកដីណាមួយ មានថេរវេលាយូរប៉ុន្មាន សមស្របទៅតាម វគ្គខ័ណ្ឌ ១ នៃមាត្រានេះ អាចនឹងត្រូវបញ្ចប់កាលណារដ្ឋហត្ថលេខីណាមួយផ្តល់ដំណឹងពីការអស់សុពលភាព ៦ខែ ជាមុនទៅអោយរដ្ឋហត្ថលេខីមួយទៀត តាមរយៈផ្លូវការទូត ។

## មាត្រា ១៦

### ភាសា

រាល់ការស្នើ និងឯកសារពាក់ព័ន្ធនានា ត្រូវធ្វើទំនាក់ទំនងជាភាសាអង់គ្លេស ។

## មាត្រា ១៧

### វិសាលភាពនៃការអនុវត្តន៍

កិច្ចព្រមព្រៀងនេះ ត្រូវបានយកទៅអនុវត្តលើចំពោះសាលក្រមដែលកំណត់រួចហើយ ទោះជាមុន ឬក្រោយពេលកិច្ចព្រមព្រៀងនេះ ចូលជាធរមានក៏ដោយ ។

## មាត្រា ១៨

### ការធ្វើវិសោធនកម្ម

ការធ្វើវិសោធនកម្ម ឬ ការកែតម្រូវលើកិច្ចព្រមព្រៀងនេះ ដែលបានឯកភាពដោយរដ្ឋហត្ថលេខីទាំងពីរ នឹងមានអនុភាពគតិយុត្តិ កាលណាមានការបញ្ជាក់ដោយការផ្លាស់ប្តូរកំណត់ទូត ។

Scanned with CamScanner

## មាត្រា ១៩

## អវសានបញ្ញត្តិ

១- កិច្ចព្រមព្រៀងនេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន និងត្រូវចូលជាធរមាន នៅពេលដែលលិខិតតូបករណ៍ នៃការផ្តល់សច្ចាប័នត្រូវបានប្តូរគ្នា ។

២- កិច្ចព្រមព្រៀងនេះនឹងនៅតែមានអនុភាពគតិយុត្តិរហូតដល់ ៦ ខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋហត្ថលេខីណាមួយ ផ្តល់សេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអោយរដ្ឋហត្ថលេខីមួយទៀត អំពីបំណងរបស់ខ្លួនដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះ ។

៣- ដោយមិនចាំបាច់គិតគូរដល់ការបញ្ចប់ កិច្ចព្រមព្រៀងនេះនឹងបន្តអនុវត្តចំពោះការអនុវត្តន៍ដាក់ទណ្ឌកម្មទៅលើទណ្ឌិតដែលត្រូវបានផ្ទេរតាមកិច្ចព្រមព្រៀងនេះ រហូតដល់មុនកាលបរិច្ឆេទដែលការបញ្ចប់ត្រូវចូលជាធរមាន ។

ជាសក្ខីភាព អ្នកចុះហត្ថលេខាជាមន្ត្រីទទួលសិទ្ធិអំណាចត្រឹមត្រូវជាតំណាងរបស់រដ្ឋាភិបាលរៀងៗខ្លួន ត្រូវចុះហត្ថលេខា លើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅញូវដេលី ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ជាពីរច្បាប់ដើម ភាសាខ្មែរ ហិណ្ឌី និងអង់គ្លេស គ្រប់អត្ថបទមានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នាអត្ថបទជាភាសាអង់គ្លេស នឹងត្រូវប្រើជាអត្ថបទផ្លូវការ ។

| ជូនមុខអោយរាជរដ្ឋាភិបាលកម្ពុជា | ជូនមុខអោយរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា |
| --- | --- |
| ហោ ណាំហុង | (SHIVRAJ PATIL) |
| ឧបនាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |
| រដ្ឋមន្ត្រីការបរទេសនិង | |
| សហប្រតិបត្តិការអន្តរជាតិ | |

Scanned with CamScanner

ច្បាប់ចម្លង

**ព្រះរាជក្រឹត្យ**

**ស្តីពី**

នស/រកត/០១២១/ ០៣០

**ការបន្ធូរបន្ថយទោស និងការលើកលែងទោស**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ត្រាស់បង្គាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

CS Scanned with CamScanner

មាត្រា១.-

ព្រះរាជក្រឹត្យនេះកំណត់អំពីពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មទណ្ឌិតនោះឱ្យចូលទៅរស់នៅក្នុងសង្គមវិញ ឬក្នុងគោលបំណងផ្នែកមនុស្សធម៌។

មាត្រា២.-

ព្រះរាជក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ទៅលើការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិតទាំងអស់ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា និងចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃបរទេស ប៉ុន្តែ ត្រូវបានបញ្ជូនមកឱ្យអនុវត្តទោសនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមការព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ។

ព្រះរាជក្រឹត្យនេះមិនអនុវត្តចំពោះការលើកលែងទោសឱ្យទណ្ឌិត ដូចមានបញ្ញត្តិក្នុងមាត្រា ៧៧ នៃច្បាប់ស្តីពីពន្ធនាគារឡើយ។

## ជំពូកទី២
## ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោស

មាត្រា៣.-

ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំ ដូចតទៅ៖

១-ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍។

២-ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

៣-ពិធីបុណ្យវិសាខបូជា។

៤-ពិធីបុណ្យឯករាជ្យជាតិ។

៥-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើផងដែរក្នុងពិធីបុណ្យ ឬព្រឹត្តិការណ៍ធំៗរបស់ជាតិ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នា។

## ជំពូកទី៣
## លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស
### ផ្នែកទី១
### លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

[illegible]

កា[illegible]លបានការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ [illegible]លបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ អាចទទួលបានការ[illegible] ជាការបន្ធូរបន្ថយទោស ឬជាការលើកលែងទោសបាន។

Scanned with CamScanner

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពរប៉ុណ្ណោះ។

**មាត្រា៥.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមារយាទឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត។

**មាត្រា៦.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តផងដែរក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស

**មាត្រា៧.-**

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការបន្ធូរបន្ថយទោសបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់។

ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន។

**មាត្រា៨.-**

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ ដូចខាងក្រោម៖

១- ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ) ឆ្នាំ ដល់ក្រោម ៥ (ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៣ (បី) ខែ។

Scanned with CamScanner

២-ទោសដាក់ពន្ធនាគារកំណត់ពី ៥ (ប្រាំ) ឆ្នាំ ដល់ក្រោម ១០ (ដប់) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៣-ទោសដាក់ពន្ធនាគារកំណត់ពី ១០ (ដប់) ឆ្នាំ ដល់ក្រោម ២០ (ម្ភៃ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៩ (ប្រាំបួន) ខែ ឬ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៤-ទោសដាក់ពន្ធនាគារកំណត់ពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០(សាមសិប) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ១២ (ដប់ពីរ) ខែ ឬ៩ (ប្រាំបួន) ខែ ឬ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៥-ទោសដាក់ពន្ធនាគារមួយជីវិត អាចនឹងបន្ថយទោសលើកទី១ មកនៅត្រឹម ៣០ (សាមសិប) ឆ្នាំ។

**មាត្រា៩..**

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសបានតែម្តងគត់ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ។

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសច្រើនដងបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោសពាក់កណ្តាលនៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។

ចំពោះទណ្ឌិតដែលត្រូវបានកំណត់ទោសដាក់ពន្ធនាគារមួយជីវិត ក្រោយពីបានបន្ថយមកនៅត្រឹម ៣០(សាមសិប)ឆ្នាំ អាចនឹងបានទទួលការបន្ធូរបន្ថយទោសច្រើនដងទៀតបាន។ ប៉ុន្តែ ទោះជាទណ្ឌិតនោះបានទទួលការបន្ធូរបន្ថយទោសច្រើនដងក៏ដោយ ក៏រយៈពេលនៃការទទួលរងទោសទាំងអស់ត្រូវឱ្យបានយ៉ាងតិច ២០(ម្ភៃ)ឆ្នាំ។

## ផ្នែកទី៣
## លក្ខខណ្ឌដោយឡែកនៃការលើកលែងទោស

**មាត្រា១០..**

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការលើកលែងទោស ក្នុងករណីទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគារ៖

១-ចំនួនពីរភាគបីនៃទោស។

២-ទណ្ឌិតដែលទទួលទោសដាក់ពន្ធនាគារអស់មួយជីវិត អាចទទួលការលើកលែងទោស ប្រសិនបើទណ្ឌិតនោះបានអនុវត្តទោសយ៉ាងតិច ៣០(សាមសិប)ឆ្នាំ ឬ២០(ម្ភៃ)ឆ្នាំ ក្នុងករណីដែលមានការបន្ធូរបន្ថយទោស។

## ជំពូកទី៤
## បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

**មាត្រា១១..**

ប្រធានពន្ធនាគារត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយ ឬលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនមកគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ត្រូវពិនិត្យ និងវាយតម្លៃអំពី[illegible]សម្បត្តិរបស់ទណ្ឌិតម្នាក់ៗដែលបំពេញគ្រប់លក្ខខណ្ឌអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែង

Scanned with CamScanner

ទោស និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យនេះ។

គំរូបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវកំណត់ដោយគណៈកម្មការថ្នាក់ជាតិ។

**មាត្រា១២.-**

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែ មិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួន ឬអ្នកតំណាងស្របច្បាប់មានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។ ពាក្យបណ្តឹងតវ៉ានេះ ត្រូវដាក់នៅគណៈកម្មការថ្នាក់ជាតិ ដោយផ្ទាល់ ឬតាមរយៈប្រធានពន្ធនាគារ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ានេះ ប្រធានពន្ធនាគារត្រូវបញ្ជូនពាក្យប្តឹងនេះ មកគណៈកម្មការថ្នាក់ជាតិ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តទោសរបស់ទណ្ឌិតនោះ។

**មាត្រា១៣.-**

គណៈកម្មការថ្នាក់ជាតិ ត្រូវប្រជុំពិនិត្យ និងវាយតម្លៃលើបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស និងរៀបចំបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥
## ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសំណៅចែកផ្សាយជូនក្រសួងយុត្តិធម៌ដើម្បីចាត់ចែងអនុវត្ត ក្រោយពីបានទទួលព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស។

**មាត្រា១៥.-**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស ទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច ដើម្បីអនុវត្ត។

**មាត្រា១៦.-**

ចំពោះទណ្ឌិតដែលត្រូវបានលើកលែងទោសដោយព្រះរាជក្រឹត្យ នឹងត្រូវដោះលែងឱ្យមានសេរីភាព ដោយប្រធានពន្ធនាគារ បន្ទាប់ពីទទួលបានដីកាបង្គាប់ឱ្យដោះលែងទណ្ឌិតរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។

ចំពោះទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ លើកលែងឱ្យទណ្ឌិតនោះរួចផុតពីការអនុវត្តទោសសម្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ។ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

CS Scanned with CamScanner

ទោស និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យនេះ។

គំរូបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវកំណត់ដោយគណៈកម្មការថ្នាក់ជាតិ។

**មាត្រា១២.-**

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែ មិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួន ឬអ្នកតំណាងស្របច្បាប់មានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។ ពាក្យបណ្តឹងតវ៉ានេះ ត្រូវដាក់នៅគណៈកម្មការថ្នាក់ជាតិ ដោយផ្ទាល់ ឬតាមរយៈប្រធានពន្ធនាគារ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ានេះ ប្រធានពន្ធនាគារត្រូវបញ្ជូនពាក្យប្តឹងនេះ មកគណៈកម្មការថ្នាក់ជាតិ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តទោសរបស់ទណ្ឌិតនោះ។

**មាត្រា១៣.-**

គណៈកម្មការថ្នាក់ជាតិ ត្រូវប្រជុំពិនិត្យ និងវាយតម្លៃលើបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស និងរៀបចំបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥
## ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសំណៅចែកផ្សាយជូនក្រសួងយុត្តិធម៌ ដើម្បីចាត់ចែងអនុវត្ត ក្រោយពីបានទទួលព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស។

**មាត្រា១៥.-**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស ទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច ដើម្បីអនុវត្ត។

**មាត្រា១៦.-**

ចំពោះទណ្ឌិតដែលត្រូវបានលើកលែងទោសដោយព្រះរាជក្រឹត្យ នឹងត្រូវដោះលែងឱ្យមានសេរីភាពភ្លាម ដោយប្រធានពន្ធនាគារ បន្ទាប់ពីទទួលបានដីកាបង្គាប់ឱ្យដោះលែងទណ្ឌិតរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។

ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ លើកលែងឱ្យទណ្ឌិតនោះរួចផុតពីការអនុវត្តទោសសម្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ។ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង

រាជធានី ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយព្រះរាជក្រឹត្យបន្ធូរបន្ថយទោស ដល់ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោស។

**មាត្រា១៧.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោស និងលើកលែងទោសនោះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

ក្រឹត្យលេខ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៤ រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

នស/រកត/០១២១/០៣៦

**បានប្រូវបាប់ព្រះរាជលញ្ឆករហើយ**

នរោត្ដម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

CS Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..៨៨..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និង ជនជាប់ឃុំ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**



Scanned with CamScanner

**មាត្រា១.–**

អនុក្រឹត្យនេះមានគោលបំណងកែសំរួលរបបផ្គត់ផ្គង់ជីវភាព ពិរុទ្ធជន និង ទណ្ឌិត និង បង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការគោរពសិទ្ធិជនដែលត្រូវបានដកហូតសេរីភាព ។

**មាត្រា២.–**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តនៅគ្រប់ពន្ធនាគារ និង មណ្ឌលអប់រំកែប្រែជនស៊ីវិល ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣.–**

ជនដែលត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន នៅតាមពន្ធនាគារ ឬ មណ្ឌលអប់រំកែប្រែ ហៅថា: "ពិរុទ្ធជន" ។

ជនដែលត្រូវបានឃុំខ្លួន ហើយមានសាលក្រមផ្តន្ទាទោសជាស្ថាពរ ហៅថា : "ទណ្ឌិត" ។

**មាត្រា៤.–**

ពិរុទ្ធជន និង ទណ្ឌិត ត្រូវបានទទួលរបបហូបចុក សំលៀកបំពាក់ និង សំភារៈប្រើប្រាស់ប្រចាំថ្ងៃដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ ។

**មាត្រា៥.–**

កូនរបស់ពិរុទ្ធជន ឬ ទណ្ឌិតមានអាយុតិចជាង៦ឆ្នាំ ដែលពុំអាចបំបែកចេញពីម្តាយ ត្រូវបានទទួលរបបជីវភាពដែលកំណត់ដោយអនុក្រឹត្យនេះ ។

**មាត្រា៦.–**

ទណ្ឌិតទាំងអស់ ត្រូវបានទទួលការអប់រំកែប្រែ ស្តារនីតិសម្បទា និង បណ្តុះបណ្តាលវិជ្ជាជីវៈស្របតាមកម្មវិធីអប់រំកែប្រែនៅក្នុងមណ្ឌលអប់រំកែប្រែ ឬ ពន្ធនាគារ ។

## ជំពូកទី២
## អំពីរបបហូបចុក

**មាត្រា៧.–**

ពិរុទ្ធជន និង ទណ្ឌិតម្នាក់ៗ ត្រូវបានទទួលរបបហូបចុកប្រចាំថ្ងៃចំនួន ២.៨០០រៀល ។

**មាត្រា៨.–**

កូនមួយនាក់របស់ ពិរុទ្ធជន និង ទណ្ឌិត រស់នៅជាមួយម្តាយក្នុងពន្ធនាគារ ឬ មណ្ឌលអប់រំកែប្រែ ដែលមានអាយុក្រោម ៦ឆ្នាំ ត្រូវបានទទួលរបបហូបចុកស្មើនឹងពាក់កណ្តាលនៃរបបពិរុទ្ធជន ឬ ទណ្ឌិត មួយនាក់ ។

**មាត្រា៩.–**

ពិរុទ្ធជន និង ទណ្ឌិត ទាំងអស់ត្រូវបានទទួលរបបបន្ថែមទ្វេដងសំរាប់ថ្ងៃ បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ បុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ និង បុណ្យឯករាជ្យជាតិ ។

**មាត្រា១០.–**

ក្នុងថ្ងៃបុណ្យ ដូចមានចែងក្នុងមាត្រា ៩ និង ក្នុងទិវាកុមារអន្តរជាតិ ១ មិថុនា កូនដែលរស់នៅជាមួយម្តាយត្រូវបានទទួលរបបបន្ថែមទ្វេដងផងដែរ ។

Scanned with CamScanner

**មាត្រា១១.-**

ក្នុងករណីម្តាយជាពិរុទ្ធជន ឬ ទណ្ឌិត មានជំងឺពុំអាចបំបៅកូនក្រោមអាយុ ១២ ខែ របស់ខ្លួនបានត្រូវផ្តល់ទឹកដោះគោ ចំនួន ២គីឡូក្រាម ក្នុង១ខែ។

## ជំពូកទី៣
## អំពីសំលៀកបំពាក់ និង សំភារៈប្រើប្រាស់ផ្ទាល់ខ្លួន

**មាត្រា១២.-**

ពិរុទ្ធជន និង ទណ្ឌិតម្នាក់ៗ ត្រូវបានទទួលរបបស្បៀកពាក់ និង សំភារៈប្រើប្រាស់ផ្ទាល់ខ្លួនសំរាប់រយៈពេល១ឆ្នាំ រួមមាន ៖

| | |
|---|---|
| - ខោវែង អាវវែង ក្រណាត់តេតូរុង | ចំនួន ១ សំរាប់ |
| - ខោខ្លី អាវខ្លី ក្រណាត់តេតូរុង | ចំនួន ១ សំរាប់ |
| - មុងនីឡុង | ចំនួន ១ |
| - ភួយ | ចំនួន ១ |
| - កន្ទេល នីឡុង | ចំនួន ១ |
| - ក្រមា អំបោះ | ចំនួន ១ |
| -កន្សែងពោះគោធុនតូច | ចំនួន ២ |
| - ស្បែកជើងផ្ទាត់ | ចំនួន ២គូ |
| - ចានទាបអាលុយមីនីញ៉ូម | ចំនួន ២ |
| - ស្លាបព្រាជ័រ | ចំនួន ២ |
| - កែវជ័រ | ចំនួន ២ |
| - ម្សៅសាប៊ូ | ចំនួន ៣ គីឡូក្រាម |
| - ធោយទឹកជ័រ | ចំនួន ១ សំរាប់៥នាក់ |
| - សាប៊ូដុំសំរាប់ការពារជម្ងឺរមាស់ | ចំនួន ៦ដុំ |
| - ច្រាសដុសធ្មេញ | ចំនួន ២ដើម |
| - ថ្នាំដុសធ្មេញធុនមធ្យម | ចំនួន ៦បំពង់ |
| -ក្រណាត់ប៉ារ៉ាតង់ | ចំនួន ១ សំរាប់១៥នាក់ |

**មាត្រា១៣.-**

ក្រៅពីរបបខាងលើ ពិរុទ្ធជន និង ទណ្ឌិតជាស្ត្រី ត្រូវបានទទួលសារុងចំនួន ២ និង សំឡីអនាម័យចំនួន១២ដុំធំ ក្នុងមួយឆ្នាំ។ ក្នុងពេលសំរាលកូន ត្រូវបានផ្តល់ក្រណាត់ទេសឯក ចំនួន ៤ម៉ែត្រ។



Scanned with CamScanner

**មាត្រា១៤.-**

កូនរបស់ពិរុទ្ធជន ឬ ទណ្ឌិត ដែលមានចែងក្នុងមាត្រា១៣ ត្រូវបានទទួលក្រណាត់តេត្រូរុង ចំនួន ៦ម៉ែត្រក្នុងមួយឆ្នាំ។

**មាត្រា១៥.-**

គំរូ ពណ៌ សំលៀកបំពាក់ និង សំភារៈប្រើប្រាស់របស់ ពិរុទ្ធជន និង ទណ្ឌិត ត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា១៦.-**

ចំពោះទណ្ឌិត ដែលធ្វើការនៅកន្លែងងាយរងគ្រោះថ្នាក់ ឬ ប៉ះពាល់ដល់សុខភាព ត្រូវបានទទួលសំលៀកបំពាក់ និង សំភារៈការពារខ្លួន តាមការកំណត់នៃច្បាប់ការងារ ។

**មាត្រា១៧.-**

សំភារៈប្រើប្រាស់ដែលត្រូវផ្តល់អោយរោងបាយសំរាប់ពិរុទ្ធជន និង ទណ្ឌិត ចំនួន១០០នាក់ ប្រើប្រាស់ក្នុងរយៈពេល១ឆ្នាំ រួមមាន ៖

| | |
|---|---|
| - ខ្ទះគ្នោតធំ | ចំនួន ៣ |
| - ឡាំងស៊ីង | ចំនួន ១ |
| - ឆ្នាំងធំ | ចំនួន ៤ |
| - វែកធំ | ចំនួន ៤ |
| - ផ្តិលចំហុយបាយ | ចំនួន ២០០ |
| - កាធុនសំរាប់លាងអង្ករ | ចំនួន ៤ |
| - កញ្ច្រែងជ័រសំរាប់លាងបន្លែ | ចំនួន ៤ |
| - កាំបិតចិតបន្លែ | ចំនួន ៤ |
| - កាំបិតកាប់សាច់ | ចំនួន ២ |

\+ នៅពេលហូបបាយពិរុទ្ធជន និង ទណ្ឌិត ចំនួន៦នាក់ ត្រូវបានផ្តល់អោយ :

| | |
|---|---|
| - ឆ្នាំងតូចសំរាប់ដាក់សំឡ | ចំនួន ១ |
| - ចានទាបសំរាប់ដាក់ម្ហូប | ចំនួន ១ |
| - ចានចង្កឹសជ័រ | ចំនួន ១ |
| - វែកដួសសំឡ | ចំនួន ១ |

## ជំពូកទី៤

## អំពីប្រាក់របបសំរាប់សេវាអប់រំកែប្រែ សុខាភិបាល និងស្ថានីតិសម្បទា

**មាត្រា១៨.-**

ទណ្ឌិតម្នាក់ៗ ត្រូវបានទទួលរបបប្រចាំខែ សំរាប់សេវាអប់រំកែប្រែ ចំនួន ៥.០០០រៀល ។

**មាត្រា១៩.-**

Scanned with CamScanner

**មាត្រា២០.-**

ពិរុទ្ធជន និង ទណ្ឌិត ដែលមានជំងឺត្រូវបានព្យាបាលនៅតាមប៉ុស្តិ៍សុខភាព ឬ មន្ទីរពេទ្យរដ្ឋក្រោមសេវាគ្រប់ដណ្តប់របស់ក្រសួងសុខាភិបាល ។

**មាត្រា២១.-**

ការដឹកជញ្ជូន ពិរុទ្ធជន និង ទណ្ឌិត ព្រមទាំងតម្លៃ អគ្គិសនី ទឹក នៅតាមពន្ធនាគារ និង មណ្ឌលអប់រំកែប្រែទាំងអស់នៅទូទាំងប្រទេសជាបន្ទុករបស់រដ្ឋ ។

## ជំពូកទី៥
## អំពីគោលនយោបាយ និង របបឧបត្ថម្ភផ្សេងៗ

**មាត្រា២២.-**

រដ្ឋឧបត្ថម្ភថវិកាសំរាប់ការអភិវឌ្ឍន៍កម្មវិធីឧស្សាហកម្ម កសិកម្មពន្ធនាគារ សំដៅពង្រឹងសេវាអប់រំកែប្រែស្តារនីតិសម្បទាទណ្ឌិត ដើម្បីបង្កលក្ខណៈសមាហរណកម្មចូលសហគមន៍ជាតិវិញ។ ក្រសួងមហាផ្ទៃត្រូវធ្វើគំរោងថវិកាប្រចាំឆ្នាំ ដើម្បីរៀបចំទីតាំងហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍ សំភារៈបច្ចេកទេស ពូជដំណាំ បសុសត្វ និង ទុនបំរើអោយការផលិត ។

**មាត្រា២៣.-**

ទណ្ឌិត ដែលបានចូលរួមអនុវត្តកម្មវិធីឧស្សាហកម្ម កសិកម្មពន្ធនាគារ ត្រូវបានទទួលផលកំរៃដោយផ្ទាល់ និង ការលើកទឹកចិត្តដ៏ទៃទៀត តាមការកំណត់ដូចបានចែងក្នុងនីតិវិធីស្តីពីការគ្រប់គ្រងឧស្សាហកម្ម កសិកម្មពន្ធនាគាររបស់ក្រសួងមហាផ្ទៃ។

**មាត្រា២៤.-**

ពិរុទ្ធជន ឬ ទណ្ឌិត ម្នាក់ស្លាប់ ត្រូវបានទទួលប្រាក់ចំនួន ៣០០.០០០រៀល សំរាប់រៀបចំ ធ្វើបុណ្យសពតាមប្រពៃណីជាតិ។

**មាត្រា២៥.-**

នៅពេលត្រូវបានដោះលែងចេញពីពន្ធនាគារ ឬ មណ្ឌលអប់រំកែប្រែ ទណ្ឌិតម្នាក់ ត្រូវបានទទួលខោអាវថ្មីមួយសំរាប់ និង ប្រាក់ឧបត្ថម្ភ ចំនួន៥០.០០០រៀល សំរាប់ធ្វើដំណើរ ហូបចុកតាមផ្លូវ ។

## ជំពូកទី៦
## អំពីនីតិវិធី និងការដោះស្រាយបទល្មើស

**មាត្រា២៦.-**

ជនណាដែលបានកិបកេង ឬ កាត់បន្ថយបរិមាណ និង គុណភាពរបបជីវភាព ប្រាក់រង្វាន់ ឬប្រាក់ឧបត្ថម្ភរបស់ពិរុទ្ធជន និង ទណ្ឌិត ត្រូវទទួលវិន័យ ឬ ផ្តន្ទាទោសតាមច្បាប់ជាធរមាន ។



CS Scanned with CamScanner

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៧.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជំរាបជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ២៨
- -រាជកិច្ច
- - ឯកសារ កាលប្បវត្តិ

Prisoner exiting.doc

CS Scanned with CamScanner

ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល
អធិការដ្ឋាននគរបាលក្រុងតាខ្មៅ
[illegible]
លេខសំណុំរឿង ១០[illegible]/២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុស្ដីពីការឃាត់ខ្លួន

នៅ [illegible] ឆ្នាំ [illegible]
ខែ [illegible] ថ្ងៃ [illegible] វេលាម៉ោង [illegible] និង [illegible] នាទី
យើង [illegible] ជាមន្ត្រីនគរបាលយុត្តិធម៌
បាន: [illegible]
បន្ទាប់ពីសើបអង្កេតក្នុងបទល្មើស ៖ [illegible]
តាមបញ្ញាប្បដិកា [illegible]
[illegible]
ជំនួយការដោយលោក [illegible]
[illegible]

បានដំណើរការឃាត់ខ្លួន (1) ៖

- ជនសង្ស័យត្រូវរកឃើញទាន់ពេលកំពុងប្រព្រឹត្តបទល្មើស ☑
- ជនសង្ស័យត្រូវបានបង្ហាញដោយមានសាក្សីគ្រប់គ្រាន់ ឬជនរងគ្រោះនៅកន្លែងកើតហេតុ ☐
- ជនសង្ស័យកំពុងភៀសខ្លួនពីទីកន្លែងកើតហេតុ ☐

បន្ទាប់ពីបានពិនិត្យអត្តសញ្ញាណរួចហើយ យើងខ្ញុំបានជូនដំណឹងទៅកាន់ជនដែលត្រូវឃាត់ខ្លួន និងបានបង្ហាញអំពីសមត្ថកិច្ច និងគោលដៅដើម្បីឃាត់ខ្លួននិងធ្វើការស្តាប់ចម្លើយ ៖

- គោត្តនាម និង នាម ...... ឈ្មោះហៅក្រៅ ......
- ភេទ [illegible] អាយុ [illegible] ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ
- ថ្ងៃ ខែ ឆ្នាំ កំណើត ១៩៨[illegible]
- ស្រុកកំណើត [illegible]
- ទីលំនៅអចិន្ត្រៃយ៍ ......
- ទីលំនៅបច្ចុប្បន្ន [illegible]
- អត្តសញ្ញាណប័ណ្ណលេខ ...... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ......
- ផ្ដល់នៅ ......

(1)សូមគូសសញ្ញា ✓ លើប្រអប់ណាមួយក្នុងចំណោមប្រអប់ទាំង ៣ ។

[signature]

Scanned with CamScanner

- លិខិតឆ្លងដែនលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...
- ផ្តល់នៅ ... "សម្រាប់ជនបរទេស"
- មុខរបរ [illegible] .
- កម្រិតវប្បធម៌ ថ្នាក់ទី ០៦ .
- ទូរស័ព្ទលេខ ...
- ចាប់មកជាមួយ ៖ ថ្នាំញៀន ០៤កញ្ចប់ [illegible] - ម៉ូតូ ០១ គ្រឿង ម៉ាក SUZUKI nex ពណ៌ស [illegible] 1BP-0465 ទូរស័ព្ទ ០២ គ្រឿង NOKIA ... [illegible] ..
- បទល្មើស ៖ ជាក់ស្តែង .
- ស្ថានភាពជនល្មើស ៖ ... [illegible] ...

ចំពោះមុខអ្នកបកប្រែ "សម្រាប់ជនបរទេស" ៖

- គោត្តនាម និង នាម ... ឈ្មោះហៅក្រៅ ...
- ភេទ ... អាយុ ... ឆ្នាំ ជនជាតិ ... សញ្ជាតិ ...
- ថ្ងៃ ខែ ឆ្នាំ កំណើត ...
- ស្រុកកំណើត ...
- ទីលំនៅអចិន្ត្រៃយ៍ ...
- ទីលំនៅបច្ចុប្បន្ន ...
- អត្តសញ្ញាណប័ណ្ណលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...

ផ្តល់នៅ ...

- លិខិតឆ្លងដែនលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...
- ផ្តល់នៅ ... "សម្រាប់ជនបរទេស"
- មុខរបរ ...
- កម្រិតវប្បធម៌ ...
- ទូរស័ព្ទលេខ ...

យើងប្រាប់ដល់ជនសង្ស័យអំពីសិទ្ធិនូវមាត្រា ៩៨ (ជំនួយរបស់មេធាវីពេលឃាត់ខ្លួន)

អំពីហេតុការណ៍ដែលកើតឡើង ៖

...

Scanned with CamScanner

[illegible] ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible]
[illegible]
ឈ្មោះ [illegible] ភេទប្រុស អាយុ [illegible] ឆ្នាំ
មានទីលំនៅ ភូមិ [illegible] ឃុំ [illegible] ស្រុក [illegible]
ខេត្តកណ្ដាល ។ [illegible]
[illegible]
[illegible]
[illegible] ខេត្តកណ្ដាល ។

កំណត់ហេតុស្ដីពីការឃាត់ខ្លួន បានបញ្ចប់នៅថ្ងៃ ខែ ឆ្នាំ ដដែល វេលាម៉ោង ..ដប់ប្រាំ...... និង ..សែសិប ... នាទី បានអានឲ្យស្ដាប់ឡើងវិញដោយមន្ត្រីនគរបាលយុត្តិធម៌ ឬសាមីខ្លួនអានផ្ទាល់ ហើយអះអាងថា ពិតជាត្រឹមត្រូវ និងផ្ដិតម្រាមដៃទុកជាភស្តុតាង ។

| ស្នាមម្រាមដៃជនត្រូវឃាត់ខ្លួន | ជំនួយការ | មន្ត្រីនគរបាលយុត្តិធម៌ |
| --- | --- | --- |

CS Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ . . .អ.ក
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០

## កំណត់ហេតុយកចម្លើយ

ឆ្នាំពីរពាន់ម្ភៃ ខែធ្នូ ថ្ងៃទីដប់បួន វេលាម៉ោងពីរ និងសែសិបនាទីរសៀល។

យើង **ស៊ិន យ៉ឺត** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល ដោយមានលោក ជុំ គុល ជាក្រឡាបញ្ជីអម បានសួរកត់យកចម្លើយឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ ជាជនសង្ស័យ បានចូលមកឆ្លើយដូចខាងក្រោម៖

នាមត្រកូល និងនាមខ្លួនឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរសិប្បកម្មកៃច្នៃ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិទេពអរជូន ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" ប្រពន្ធឈ្មោះ កូន០២នាក់ ជានិតិជន ធ្លាប់ជាប់ពន្ធនាគារពីរឆ្នាំ ពីបទៈ រក្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

សួរ ឆ្លើយៈ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង០៩ និង១០នាទីព្រឹក ខ្ញុំបាទបានជិះម៉ូតូម្នាក់ឯងចេញពីផ្ទះសំដៅទៅទិញថ្នាំញៀននៅម្ដុំរង្វង់មូលគួរស្រូវពីបុរសម្នាក់មិនស្គាល់ឈ្មោះ ចំនួន ៦០ម៉ឺនរៀល បាន៨កញ្ចប់(ធំ០៣ មធ្យម០១) ។ពេលទិញថ្នាំរួចខ្ញុំបាទបានជិះម៉ូតូសំដៅទៅផ្ទះវិញលុះដល់ចំនុចភូមិព្រែកហូរលិច ស្រាប់តែជួបសមត្ថកិច្ចកំពុងតែចុះល្បាត ហើយក៏បានហៅខ្ញុំបាទឲ្យឈប់ ពេលនោះខ្ញុំបាទភ័យពេក ក៏បានផ្ទួលម៉ូតូរត់ ប៉ុន្តែរត់មិនរួច ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនខ្ញុំបាទ និងបានឆែកឆេរក៏ឃើញថ្នាំញៀនដែលខ្ញុំបាទទិញនោះ ។

សួរ ឆ្លើយៈ ចំពោះថ្នាំញៀន ខ្ញុំបាទធ្លាប់ជួញដូរអស់រយៈពេលប្រហែល ១ខែ និងធ្លាប់ប្រើប្រាស់អស់រយៈពេល ៣ឆ្នាំ ។

សួរ ឆ្លើយៈ ចំពោះខ្ញុំបាទធ្លាប់ទិញថ្នាំញៀនពីបុរសម្នាក់មិនស្គាល់ឈ្មោះនេះ ចំនួន ៣ដងទាំងលើកនេះ ដោយទិញម្ដងៗពី៤០ម៉ឺន ទៅ៦០ម៉ឺន ។

ឈប់សួរ ហើយយើងបានអានឲ្យស្ដាប់ សាមីខ្លួនយល់ថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខាឬផ្តិតមេដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល
អធិការដ្ឋាននគរបាលក្រុងតាខ្មៅ
ប៉ុស្ដិ៍នគរបាលរដ្ឋបាលព្រែកហូរ

លេខសំណុំរឿង......................

## កំណត់ហេតុស្ដាប់ចម្លើយ

នៅ .................................... ឆ្នាំ ....................

ខែ .................... ថ្ងៃទី .................... វេលាម៉ោង .................... និង .................... នាទី

យើង .................................................... ជាមន្ត្រីនគរបាលយុត្តិធម៌

ឋានៈ ....................................................

បន្តការស៊ើបអង្កេតក្នុងបទល្មើសជាក់ស្ដែង ៖

ជំនួយការដោយលោក ....................................................

....................................................

យើងបានឲ្យនាំខ្លួនឈ្មោះ .................... ដែលជាអ្នកបានឆ្លើយឲ្យយើងដឹង

ដូចខាងក្រោម ៖

អំពីអត្តសញ្ញាណជនសង្ស័យ

ត្រូវបានឃាត់ខ្លួនក្នុងករណី ....................................................

មកចំពោះមុខយើង ដែលបានឆ្លើយឲ្យយើងដូចខាងក្រោម ៖

អំពីអត្តសញ្ញាណជនដែលត្រូវឃាត់ខ្លួន

- គោត្តនាម និង នាម ........ ឈ្មោះហៅក្រៅ ....................
- ភេទ .......... អាយុ .......... ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ
- ថ្ងៃ ខែ ឆ្នាំ កំណើត ....................
- ស្រុកកំណើត .......... ស្រុកស្អាង ខេត្តកណ្ដាល
- ទីលំនៅអចិន្ត្រៃយ៍
- ទីលំនៅបច្ចុប្បន្ន .......... ស្រុកស្អាង ខេត្តកណ្ដាល
- អត្តសញ្ញាណប័ណ្ណលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ
- ផ្តល់ដោយ ....................
- លិខិតឆ្លងដែនលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ
- ផ្តល់ដោយ ....................
- មុខរបរ ....................

-កម្រិតវប្បធម៌ ថ្នាក់ទី [illegible]

-ប្រពន្ធ ឬប្ដីឈ្មោះ

-ចំនួនកូនប៉ុន្មាននាក់ ០២ នាក់

-ឪពុកឈ្មោះ អាយុ ឆ្នាំ

-មុខរបរ [illegible]

-ម្ដាយឈ្មោះ អាយុ ៥៤ ឆ្នាំ

-មុខរបរ [illegible]

-ទោសពីមុន [illegible]

-ប្រវត្តិសកម្មភាព [illegible]

[illegible]

២០១៧ ដល់ ២០១៨ ។

សួរ និង ឆ្លើយ

ស [illegible] ?

ច [illegible] ។

ស [illegible] ?

ច [illegible] ។

ស [illegible] ?

ច [illegible] ២០ [illegible] ១០.០០០ [illegible] ។

ស [illegible] ?

ច [illegible] ។

ស [illegible] ?

ច នៅថ្ងៃទី ១៣ [illegible] ឆ្នាំ២០២០ [illegible] ម៉ូតូ [illegible] SUZUKI [illegible] ភ្នំពេញ 1BD 0465 [illegible] ១២ [illegible] ១៥ [illegible] ។

ស [illegible] ?

ច [illegible] ។

កំណត់ហេតុស្តាប់ចម្លើយ បានចប់នៅថ្ងៃ ខែ ឆ្នាំ ដដែល វេលាម៉ោង ដប់ប្រាំ និង សូន្យ នាទី និងបានអានដោយសាមីជនខ្លួនឯង ឬ ដោយមន្ត្រីនគរបាលយុត្តិធម៌បញ្ជាក់អះអាងថា ពិតជាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃ ឬ ចុះហត្ថលេខាដូចខាងក្រោម ។

ស្នាមមេដៃជនដែលត្រូវស្តាប់ចម្លើយ

ជំនួយការ

មន្ត្រីនគរបាលយុត្តិធម៌

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

មន្ទីរស៊ើបសួរអក្សរ "ទ"

សំណុំរឿងលេខ ......អ.ក

ចុះថ្ងៃទី.09.... ខែ.03......ឆ្នាំ២០២១

## កំណត់ហេតុស្តីពី

## ការសួរចម្លើយជនត្រូវចោទ

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែ........... ថ្ងៃទី ........... វេលាម៉ោង...........

យើង ជួន ទណ្ណៈ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

អមដោយលោក អ៊ិន សារ៉ាត ជាក្រឡាបញ្ជី ។

បានបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល និងនាមខ្លួន: ......ហៅ.........ភេទ......... អាយុ.15.....ឆ្នាំ

ជនជាតិ.........សញ្ជាតិ.........មុខរបរ:.........ទីកន្លែងកំណើត:ភូមិ...........

ឃុំ/~~សង្កាត់~~..........ស្រុក/~~ខណ្ឌ~~...........ខេត្ត/~~រាជធានី~~...........។

ទីលំនៅបច្ចុប្បន្ន:ភូមិ...........ឃុំ/~~សង្កាត់~~...........ស្រុក/~~ខណ្ឌ~~...........

ខេត្ត/~~រាជធានី~~...........ឪពុកឈ្មោះ ..."រ/ស" ម្តាយឈ្មោះ

"រ/ស" នៅ......... ប្តី/ប្រពន្ធឈ្មោះ................... មានកូន........នាក់ ជានីតិជន ឬអនីតិជន

កម្រិតវប្បធម៌ថ្នាក់ទី..6..................។

*ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ:*...........

ដែលមានលោក.................................ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ។

☐ ជននេះបានប្រកាសប្រាប់ថា: ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលស្ថិតនៅលំនៅឋានបច្ចុប្បន្ន។

☑ ជននេះ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

☐ ជននេះ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ក្រោយពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ឈ្មោះនេះរួច យើងបានប្រាប់ដល់ឈ្មោះនេះឱ្យបានដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលតំណាងអយ្យការបានប្តឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ.........................ដក.សស ចុះថ្ងៃទី............ខែ..................ឆ្នាំ២០...... ដែលជាហេតុនាំឲ្យជន

នេះ ត្រូវបានដាក់ឱ្យនៅក្រោមការពិនិត្យ និងការឃុំខ្លួនជាបណ្ដោះអាសន្ន តាមដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ:......................ដស.ឃខ ចុះថ្ងៃទី ..............ខែ..............ឆ្នាំ២០........។

យើងបានសួរចម្លើយជននេះ ហើយជននេះបានឆ្លើយប្រាប់យើងថា:

ស.ឆ: [illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| សាលាដំបូង... | |
| --- | --- |
| បណ្តឹង ឧទ្ធរណ៍ | [illegible] |

## ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរមានអាសយដ្ឋានបច្ចុប្ប[...] ភូមិក្រូចសើច ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្តាល**

**កម្មវត្ថុ** ៖ បណ្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣០ ប ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២[...] របស់សាលាដំបូងខេត្តកណ្តាល ។

**យោង** ៖ -ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។
-សំណុំរឿងព្រហ្មទណ្ឌលេខ ២៧៥ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំ[...] ខេត្តកណ្តាល។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាប[...] ការសម្រេចសេចក្តីក្នុងសាលក្រមព្រហ្មទណ្ឌលេខ ១៣០ ប ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០[...] របស់សាលាដំបូងខេត្តកណ្តាល បានផ្តល់ភាពអយុត្តិធម៌បំផុតចំពោះខ្ញុំបាទ ទើបខ្ញុំបាទស[...] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌខាងលើនេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាជ្រាប តាម[...] ច្បាប់ចាប់ពីពេលនេះតទៅ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

[illegible] ថ្ងៃទី 05 ខែសីហា ឆ្នាំ២០២០

ស្នាមមេដៃស្តាំ

**បានឃើញ**

[illegible] ថ្ងៃទី 05 ខែសីហា ឆ្នាំ២០២០

**ហត្ថលេខា និងត្រា**

មេធាវី
AVOCAT
ATTORNEY
AT LAW

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៥១១
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

លេខ.......

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

យើង ... ៦ខ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ... ជាក្រឡាបញ្ជី។

-បានឃើញ មាត្រា ២០៣ ដល់មាត្រា ២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ...៨ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ដែលទាក់ទងនឹង៖

-ឈ្មោះ ... ហៅ វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ ជនជាតិ ខ្មែរ ទីកន្លែងកំណើតភូមិ ... ឃុំ ... ស្រុក ... ខេត្ត ... ល អាសយដ្ឋានមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះ ...១ ផ្លូវលេខ ... ភូមិ ... សង្កាត់ ... ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឪពុកឈ្មោះ ... "រស់" ម្តាយឈ្មោះ ... "រស់" ជាអនីតិជន ទោសពីមុន ...

ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ ឃាតកម្ម ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវជាតិលេខ៦ ក្រុមទី០៣ ភូមិចំបក់មាស សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទ ល្មើស មានបញ្ញត្តិ និងឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី

## I-ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១-ក្នុងករណីបច្ចុប្បន្ន ជនត្រូវចោទឈ្មោះ ... ហៅ វីត ត្រូវចោទពីបទ ឃាតកម្ម។

២-កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង២០ និង៣០នាទី មានករណី ឃាតកម្ម បានកើតឡើងនៅចំណុចតាមបណ្តោយផ្លូវជាតិលេខ៦ ក្រុមទី០៣ ភូមិចំបក់មាស សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ បណ្តាលឱ្យជនរងគ្រោះឈ្មោះ ... ភេទ ប្រុ អាយុ ២០ ឆ្នាំ បានស្លាប់បាត់បង់ជីវិតក្រោយពេលបញ្ជូនដល់មន្ទីរពេទ្យ។ មុនពេលកើតហេតុនៅ វេលាម៉ោង ១៧ និង ១៥នាទី មានជនសង្ស័យមួយក្រុម ១.ឈ្មោះ ... ហៅ គោ ភេទ ប្រុស អាយុ ២០ ឆ្នាំ ២.ឈ្មោះ ...ាង ហៅ ប៊ិត ភេទ ប្រុស អាយុ ១៥ ឆ្នាំ ៣.ឈ្មោះ ... ហៅ វីត ភេទ ប្រុស អាយុ ១៥ឆ្នាំ ៤.ឈ្មោះ ... ហៅ ឆ្លាំង ភេទប្រុស អាយុ ១៦ឆ្នាំ ៥.ឈ្មោះ ...ង ភេទ ប្រុស អាយុ ១៧ឆ្នាំ ៦.ឈ្មោះ ... ភេទ ប្រុស អាយុ ១៦ឆ្នាំ ៧.ឈ្មោះ ... ភេទ ប្រុស អាយុ ២២ឆ្នាំ ៨.ឈ្មោះ ... ហៅ ឡា ភេទ ប្រុស អាយុ ២១ ឆ្នាំ ៩.ឈ្មោះ ...ទ ប្រុស អាយុប្រហែល ១៧ឆ្នាំ បាននាំគ្នាទិញស្រាបៀរយកទៅផឹកនៅលើសួនច្បារបុរហាយលេន ជាប់តាមបណ្តោយផ្លូវជាតិលេខ៦ ស្ថិតនៅភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដោយផឹករហូតដល់វេលាម៉ោង ២០ និង ២០ នាទី ក៏បានប្រទះឃើញក្រុមរបស់

រងគ្រោះ ១.រ          ១.ឈ្មោះ          និងផ្សេងទៀតដែលមានគ្នាប្រហែល១០នាក់ កំពុងជិះម៉ូតូទិសដៅពីត្បូងទៅជើង កត់ពីមុខកន្លែងដែលក្រុមជនសង្ស័យកំពុងផឹកស៊ី (មានសកម្មភាពគំរាម គ្នា បង្អួតម៉ូតូ និងធ្លាប់ចេញកាប់ភាគីជនសង្ស័យ) ឃើញដូចនោះក្រុមជនសង្ស័យដែលមានគ្នា ០៥នាក់ក៏បាននាំគ្នាឡើងម៉ូតូរៀងៗខ្លួន ជិះដេញតាមពីក្រោយក្រុម          ហៅ គោ ដែលបានជិះម៉ូតូរបស់ជនរងគ្រោះ លុះពេលជិះដល់ចំណុចកើតហេតុ ស្រាប់តែជនសង្ស័យឈ្មោះ          ហើយយកដៃស្តាំកាន់ដាវដែលបានត្រៀមរួចជាស្រេចតូតែម្នាក់ឯង បានយកដៃឆ្វេងរបស់ខ្លួនកាន់ហ្គែរម៉ូតូចំហៀងស្តាំ          និងកាប់ឯត្រូវក្បាលរបស់ជនរងគ្រោះឈ្មោះ          បណ្តាលឲ្យដួលទាំងម៉ូតូ ទាំងជនរងគ្រោះឈ្មោះ ៤.          ឈ្មោះ សំ ណាវ៉ាក់ ហើយជនសង្ស័យក៏បាននាំគ្នាជិះម៉ូតូរត់គេចខ្លួនទៅសំងំលាក់ខ្លួននៅផ្ទះរៀងខ្លួនៗ។          ហៅ វីត ផ្អែកលើ

៣-តំណាងអយ្យការ បានស្នើឱ្យឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទឈ្មោះ          សំអាងហេតុដូចតទៅ៖ ដើម្បីបញ្ចប់ ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ។

៤-ជនត្រូវចោទឈ្មោះ          ហៅ វីត សំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង។

**II-សំអាងហេតុនៃសេចក្តីសម្រេច**

៥-ជនត្រូវចោទឈ្មោះ          .ហៅ វីត ត្រូវចោទពីបទ ឃាតកម្ម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ)ឆ្នាំ (មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦-ដោយផ្អែកទៅតាមដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្តោះអាសន្ន របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ ដែលស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ដើម្បីបញ្ចប់ ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស និងផ្អែកទៅតាមចម្លើយរបស់ជនត្រូវចោទ យល់ឃើញថា ជនត្រូវចោទបានប្រព្រឹត្តបទល្មើសដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ហេតុដូច្នេះ តុលាការសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ដើម្បីបង្ការបទល្មើសកុំឱ្យកើតឡើងសារជាថ្មី និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធីតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និង អាចធានាឱ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ។

**ហេតុដូច្នេះសម្រេច**

ឃុំខ្លួនជនត្រូវចោទឈ្មោះ ដួង ចំរើន ហៅ វីត ជាបណ្តោះអាសន្នរយៈពេលអតិបរមា ០៤ (បួន) ខែ។

ថ្ងៃសៅរ៍ ០២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១

ចៅក្រមស៊ើបសួរ

បានទទួលដំណឹង

ថ្ងៃ................. ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ , ថ្ងៃទី....... ខែមករា ឆ្នាំ២០២១

ជ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

# ដីកាដំណោះស្រាយ

- ស៊ា តួរ ចៀប 19/4

លេខ: ...........

យើង ... ចៅក្រមស៊ើបសួរនៃសា ...ដំបូង ខេត្តកណ្តាល ។

បានឃើញ : ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជា ...ចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/ ០៨០៧/០២៤ ចុះថ្ងៃទី១០ ...ហា ឆ្នាំ២០០៧ ។

បានឃើញ : សំណុំរឿងព្រហ្មទណ្ឌលេខ: ... អក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ។

បានឃើញ : សំណុំរឿងស៊ើបសួរលេខ: ... សស ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ។

បានឃើញ : ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ... ដកសស ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ។

បានឃើញ : ដីកាសន្និដ្ឋានស្ថាពរលេខ: ... ដកសព.២០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ ២០២០ ។

**ក្រោយពីបានស៊ើបសួរមូលចប់សព្វគ្រប់លើជនត្រូវចោទហើយ ឃើញថា ៖**

១-ឈ្មោះ ... ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិលើ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ ... ) ម្តាយឈ្មោះ ... (រ) ប្តីឈ្មោះ ... មានកូន០១នាក់ ទោសពីមុន គ្មាន ។ (ថ្ងៃខែឆ្នាំក្នុងឃុំ ១៧.០៨.២០២០)

២-ឈ្មោះ ... ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិព្រៃកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ ... (រ) ម្តាយឈ្មោះ ... (រ) នៅលីវ ទោសពីមុន គ្មាន ។ (ថ្ងៃខែឆ្នាំក្នុងឃុំ ១៧.០៨.២០២០)

៣-ឈ្មោះ ខ្លី ភេទប្រុស នៅស្វាយប៉ាក រាជធានីភ្នំពេញ លេខទូរស័ព្ទ ... ៦ (គេចខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១និង០០នាទី មានឈ្មោះ ...ានទូរស័ព្ទទៅឈ្មោះ ...ា យកថ្នាំញៀនទៅឲ្យគេ នៅម្តុំវត្តខ្សាច់ ដោយឈ្មោះ ... ា បានកម្រៃពីឈ្មោះ ខ្លី ចំនួន២០ ដុល្លារអាមេរិក និងថ្នាំញៀន០១កញ្ចប់ សម្រាប់ប្រើប្រាស់ ។ បន្ទាប់មកឈ្មោះ នៅ រចនា បានជិះម៉ូតូ ទៅយកថ្នាំញៀនពីឈ្មោះ ... ពេលយកថ្នាំញៀនបានហើយឈ្មោះ ... ក៏ទៅដេកនៅផ្ទះសំណាក់ព្រែកតាមាក់ ។ លុះព្រឹកឡើងឈ្មោះ ... ក៏ជិះម៉ូតូជាមួយឈ្មោះ ... ដើម្បីយកថ្នាំញៀនទៅឲ្យគេនៅវត្តខ្សាច់ លុះមកដល់ចំណុចភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ក៏ត្រូវបានសមត្ថកិច្ចនគរបាលឃាត់ខ្លួននិងឆែកឆេរកឃើញថ្នាំញៀនចំនួន០៤កញ្ចប់(ធំ០១ តូច០៣)នៅនឹងខ្លួនឈ្មោះ ...

Scanned with CamScanner

បន្ទាប់មកសមត្ថកិច្ចក៏បានចាប់ឃាត់ខ្លួនជនត្រូវចោទឈ្មោះ និងឈ្មោះ បញ្ជូនមកកាន់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល ដើម្បីសាកសួរ និងចាត់ការតាមនីតិវិធី ។

**សំអាងហេតុ**

១-ពិតជាកើតមាននូវអំពើ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ដោយកាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ ស្ថិតនៅស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មានជនត្រូវចោទឈ្មោះ និងឈ្មោះ បានធ្វើសកម្មភាពយកថ្នាំញៀនពីឈ្មោះ ខ្លី បន្ទាប់មកបានយកថ្នាំនោះទៅឲ្យគេបន្ត ដោយបានកំរៃចំនួន ២០$(ម្ភៃដុល្លា) និងថ្នាំញៀនមួយកញ្ចប់ពីឈ្មោះ ខ្លី ក្រោយមកក៏ត្រូវបានសមត្ថកិច្ចនគរបាលឃាត់ខ្លួននិងឆែកឆេររកឃើញថ្នាំញៀនចំនួន ០៤កញ្ចប់ (ធំ០១ តូច០៣) ។

២-តាមចម្លើយជនត្រូវចោទឈ្មោះ បានឆ្លើយថា៖ កាលពីថ្ងៃកើតហេតុខ្លួនបានទៅយកថ្នាំញៀនពីឈ្មោះ មានលេខទូរស័ព្ទ ដើម្បីយកថ្នាំញៀនបន្តឲ្យគេ ។ ពេលមកដល់ស្ពានព្រែកព្នៅឈ្មោះ បានឲ្យមនុស្សប្រុសម្នាក់យកថ្នាំមកឲ្យខ្លួនចំនួន០២កញ្ចប់ (០១ធំ០១តូច) ដោយឈ្មោះ ប្រាប់ថា០១កញ្ចប់យកឲ្យគេ ០១កញ្ចប់ទៀតទុកឲ្យខ្លួនប្រើប្រាស់ បន្ទាប់មកខ្លួនក៏ត្រឡប់មកដេក ផ្ទះសំណាក់នៅព្រែកតាមាក់ ។ លុះព្រឹកឡើងខ្លួនបានទូរស័ព្ទរកឈ្មោះ ឲ្យ ជូនខ្លួនទៅយកលុយពីបងស្រី ពេលពួកខ្លួនធ្វើដំនើរដល់កំពង់ដរស្វាយជ្រុំ ស្រាប់តែមាន សមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួន និងឆែកឆេរ រកឃើញថ្នាំញៀនចំនួន០៤កញ្ចប់ (ធំ០១ តូច០៣) ។ ចម្លើយជនត្រូវចោទឈ្មោះ បានឆ្លើយថា៖ កាលពីថ្ងៃកើតហេតុមានឈ្មោះ បានទូរស័ព្ទមកខ្លួន ដោយពឹងឲ្យជូនទៅភូមិស្វាយជ្រុំ ដើម្បីយកលុយពីបងស្រី ខ្លួនក៏បានជូនឈ្មោះ ពេលមកដល់កំពង់ដរស្វាយជ្រុំបានមួយសន្ទុះក៏ស្រាប់តែសមត្ថកិច្ច មកដល់ឃាត់ខ្លួន និងឆែកឆេររកឃើញថ្នាំញៀនចំនួន០៤កញ្ចប់ (ធំ០១ តូច០៣) នៅនឹងខ្លួនឈ្មោះ នៅ រចនា ។ ឃើញថា ចម្លើយនេះគឺជនត្រូវចោទបានឆ្លើយសារភាពពីការប្រព្រឹត្តរបស់ខ្លួន ដែលការសារភាពនេះ មានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងថ្នាំញៀនដែលដកហូតបានជាក់ស្ដែង ។

៣-ទាំងចម្លើយរបស់ជនត្រូវចោទ និងរបាយការណ៍របស់មន្ត្រីនគបាលយុត្តិធម៌ ព្រមទាំងភស្តុតាងនានា ជាឯកសារពាក់ព័ន្ធ មានភាពស៊ីសង្វាក់គ្នាដែលកំណត់បានថា ជនត្រូវចោទពិតជាបានប្រព្រឹត្តបទល្មើសជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៤-អំពើរបស់ជនត្រូវចោទបានស្ដែងឡើងដោយមានចេតនា ទិញ លក់ និងប្រើប្រាស់ គ្រឿងញៀនដោយខុសច្បាប់ ដែលគ្រឿងញៀនជាប្រភេទម៉ាទឹកកក ជាសារធាតុមេតំហ្វេតាមីន មានកំរិតជាតុសុទ្ធ ៩,៦៧ក្រាម ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥-អំពើរបស់ជនត្រូវចោទបានធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ។

៦-ជនត្រូវចោទជានីតិជន បានប្រព្រឹត្តអំពើល្មើសច្បាប់ និងការយល់ដឹងពីអំពើនេះ ដូច្នេះជននេះត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះច្បាប់ ។

៧-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ នៅ រចនា និងឈ្មោះ ថាត ប៊ុនថៃ ដែលមានសាវតាជាតិដូចខាងលើ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត



Scanned with CamScanner

នៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨-តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ១ ជកសព.២០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ឃើញថាមានសំអាងហេតុគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើជនជាប់ចោទ គប្បីតុលាការលើកយកមកពិចារណា ។

៩-ជនត្រូវចោទឈ្មោះ ត្រូវបានតុលាការចេញដីកាឲ្យស៊ើបជំនួស អំពីសាវតាជាតិរួចហើយ ប៉ុន្តែនៅតែមិនមានលទ្ធផលអំពីសាវតាជាតិនេះទៀត គប្បីតុលាការសម្រេចលើកលែងចោទប្រកាន់លើជននេះ ដោយយោងតាមមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១០-ជនត្រូវចោទឈ្មោះ និងឈ្មោះ ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន គប្បីតុលាការសម្រេចរក្សា ជននេះឲ្យនៅក្នុងឃុំបន្តរយៈពេល ៤ខែ ដើម្បីរង់ការជំនុំជម្រះ ដោយយោងតាមមាត្រា២៤៩ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ

១១-វត្ថុតាងមាន៖ ម៉េ្សាសថ្លាប្រភេទម៉ាទឹកកក មានទម្ងន់ស្មើរនឹង ៩,៦៧ក្រាម ក្រោយពីការដកសំណាកយកទៅធ្វើកោសល្យវិច័យនៅសល់ ៩,០០ ក្រាម គប្បីបញ្ជូនទៅជំនុំជម្រះ ។

## ហេតុដូច្នេះសម្រេច

១-លើកលែងចោទប្រកាន់លើជនត្រូវចោទ៖

ឈ្មោះ (គ្មានសាវតាជាតិ) ។

ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ចោទប្រកាន់ និងបញ្ជូនជនត្រូវចោទ៖

២/១-ឈ្មោះ ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិលើ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ ក (រ) ប្តីឈ្មោះ មានកូន០១នាក់ ទោសពីមុន គ្មាន ។ (ថ្ងៃខែឆ្នាំក្នុងឃុំ ១៧.០៨.២០២០)

២/២-ឈ្មោះ ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) នៅលីវ ទោសពីមុន គ្មាន ។ (ថ្ងៃខែឆ្នាំក្នុងឃុំ ១៧.០៨.២០២០) ។

ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ទៅជំនុំជម្រះតាមនីតិវិធី ។

៣-រក្សាទុកជនត្រូវចោទឈ្មោះ ... និងឈ្មោះ ដែលមានសាវតាជាតិដូចខាងលើឲ្យនៅក្នុងឃុំជាបណ្តោះអាសន្នរយៈពេល៤ខែរង់ចាំការជំនុំជម្រះ ។



Scanned with CamScanner

CS Scanned with CamScanner

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខៈ . . អក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ និងវត្ថុតាង ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ ទៅសាលាដំបូងខេត្តកណ្ដាល ដើម្បីជំនុំជម្រះតាមនីតិវិធី ។ 19/1

ថ្ងៃច័ន្ទ៣កើត ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅខេត្តកណ្ដាល ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ

ថ្ងៃទី...19......ខែ...[illegible] ឆ្នាំ២០២០

**តំណាងអយ្យការ**

Scanned with CamScanner

CS Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សំណុំរឿងព្រហ្មទណ្ឌលេខៈ
ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

សាលក្រមព្រហ្មទណ្ឌលេខៈ
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩

## គាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងខេត្តព្រះសីហនុ លើកទី១ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ និងលើកទីពីរ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ជាប្រធានក្រុមប្រឹក្សា

លោក អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ ជាចៅក្រមប្រឹក្សា

លោក អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

### ក្រឡាបញ្ជីសវនាការ

លោក ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ។

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ដែលមាន៖

១. ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ២៨ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៦ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតនៅសង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ មានកូន០១ នាក់ ទោសពីមុនគ្មាន។ (ឃាត់ខ្លួន នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨)

ជាប់ចោទពីបទៈ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ២៩ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខ



Scanned with CamScanner

របរកម្មកររោងចក្រ កម្រិតវប្បធម៌មិនចេះអក្សរ ទីកន្លែងកំណើតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិគគីរ ឃុំបិត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ

) ម្ដាយឈ្មោះ ) ទោសពីមុនគ្មាន។ (ឃាត់ខ្លួន នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨)

៣. ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៦ នៅលីវ មុខរបរជាងដែក ទីកន្លែងកំណើតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ

) ម្ដាយឈ្មោះ ទោសពីមុនគ្មាន។ (ឃាត់ខ្លួន នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨)

ជាប់ចោទពីបទ: ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ តាមមាត្រា៤២, ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំង៣ នាក់ លោក

-បានឃើញ របាយការណ៍សំយោគលេខ: ។.ប.ក/១៨ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: អ.យ.គ/១៩ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ១ ត.ព/១៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោងដប់បី និងហាសិបនាទី កម្លាំងអធិការដ្ឋាននគរបាលស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយករណីនៅចំណុចភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយបានធ្វើការឃាត់ខ្លួនជនសង្ស័យបីនាក់ ក្នុងនោះមានឈ្មោះ , ឈ្មោះ និងជនសង្ស័យឈ្មោះ ព្រមទាំងបានដកហូតនូវម្សៅក្រាមពណ៌សថ្លាសង្ស័យថាជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនម៉ាទឹកកកចំនួនបីកញ្ចប់, ថ្នាំញៀនមេតំហ្វេតាមីនគ្រាប់ (WY) ចំនួន៣៨ គ្រាប់ និងទូរស័ព្ទដៃចំនួនបួនគ្រឿង ដើម្បី ចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ បានឆ្លើយសារភាពថា: ខ្លួននៅផ្ទះកំពុងប្រើប្រាស់ថ្នាំញៀន និងបានទៅលេងនៅរោងចក្រ។ មិនតែប៉ុណ្ណោះ ខ្លួនបានលក់ថ្នាំញៀនបានចំនួនពីរទៅបីដងមកហើយ នៅពេលខ្លួនត្រូវការថ្នាំញៀន ខ្លួនបានទូរស័ព្ទទៅគេ ហើយគេបានទម្លាក់ថ្នាំញៀនឱ្យខ្លួន ដោយខ្លួនទិញម្ដង១ចំនួនមួយកញ្ចប់



Scanned with CamScanner

CS Scanned with CamScanner

តម្លៃ១០០ ដុល្លារអាមេរិក។ ចំណែក ឈ្មោះ កំពុងដេកលើអគ្រែងចាំដីឱ្យគេ បន្ទាប់មកសមត្ថកិច្ចបានមកឃាត់ខ្លួន និងបានដកហូតទូរស័ព្ទម៉ាកអ៊ិនចុចពីល,ទូរស័ព្ទម៉ាកសាមសុង និងថ្នាំញៀនចំនួនបួនកញ្ចប់ និងថ្នាំញៀនប្រភេទ WY ចំនួន៣៨ គ្រាប់ ជារបស់ខ្លួនដែលបានទិញម្តងៗចំនួន៣០០ ទៅ៦០០ ដុល្លារមេរិក។

-ជនជាប់ចោទឈ្មោះ បានឆ្លើយសារភាពថា: ខ្លួនបានប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ ស៊ុម វិសុទ្ធ នៅពេលដែលខ្ញុំមកលេងផ្ទះប្អូនស្រីខ្លួន ដោយឈ្មោះ ជាអ្នកឱ្យខ្លួនប្រើប្រាស់ចំនួនមួយកញ្ចប់ ហើយខ្លួនប្រើប្រាស់បានប្រហែលមួយខែមកហើយៗ ក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ដោយបានដកហូតទូរស័ព្ទមួយគ្រឿង។

-ជនជាប់ចោទឈ្មោះ បានឆ្លើយសារភាពថា: ខ្លួនមិនដែលប្រើប្រាស់ថ្នាំញៀនជាមួយនឹងឈ្មោះ នោះទេ។ ខ្លួន ធ្លាប់ចូលលុយជាមួយនឹងឈ្មោះ . ចំនួនពីរដង និងបានប្រើប្រាស់ជាមួយនឹងឈ្មោះ ជាច្រើនដង។ ខ្លួនមិនដែលធ្វើការជួញដូរគ្រឿងញៀននោះទេ។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ នៅមន្ត្រីនគរបាលយុត្តិធម៌ថា: ខ្លួន ចេះប្រើប្រាស់ថ្នាំញៀន ហើយថ្នាំញៀនដែលខ្លួនប្រើប្រាស់នោះ គឺទិញពីបងម្នាក់ មិនស្គាល់អត្តសញ្ញាណបានចំនួនបីលើកមកហើយ ដោយលើកទីមួយ ខ្លួនបានទិញចំនួន៣០០ ដុល្លារអាមេរិក និងបានផ្ញើលុយតាមវីង ហើយខ្លួនបានយកទៅលក់បន្តដោយចំណេញក្នុងមួយកញ្ចប់១០ ទៅ២០ ដុល្លារអាមេរិក។ លើកទីពីរ ខ្លួនកុម្ម៉ង់ទិញចំនួន៥ កញ្ចប់ តម្លៃ៣០០ ដុល្លារអាមេរិក ខ្លួនបានផ្ញើលុយតាមវីង និងបានទៅយកថ្នាំញៀននោះនៅបង្គោលលេខ២១៦ ហើយខ្លួនបានយកថ្នាំញៀនោះ ទៅលក់ក្នុងមួយកញ្ចប់ ចំណេញបាន១០ ទៅ២០ ដុល្លារអាមេរិក។ លើកទីបី ខ្លួនបានកុម្ម៉ង់ចំនួន១០ កញ្ចប់ ក្នុងតម្លៃ៣០០ ដុល្លារអាមេរិក និងបានធ្វើការលក់ដូចពាល់ដងដែរ។ លុះដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោងប្រហែលដប់បី និងម្ភៃនាទី ខ្លួនបាននឹងកំពុងជក់ថ្នាំញៀន ហើយសមត្ថកិច្ចបានមកដល់បានធើការរកឆែក និងធើការដកហូតថាំញៀនចំនួនបីកញ្ចប់តែម្តង។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ . នៅមន្ត្រីនគរបាលយុត្តិធម៌ថា: ខ្លួន ចេះប្រើប្រាស់ថ្នាំញៀនបានប្រហែលបួនដងមកហើយ ដោយថ្នាំញៀនដែលខ្លួនប្រើប្រាស់នោះគឺឈ្មោះ ជាអ្នកឱ្យខ្លួនប្រើប្រាស់ ដោយឈ្មោះ មិនដែលឱ្យខ្លួនយកទៅឱ្យគេទេ។ លុះដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ខ្លួនកំពុងតែដេកនៅក្នុងអង្រឹង ស្រាប់តែសមត្ថកិច្ចបានមកដល់ និងបានធ្វើការឃាត់ខ្លួនតែម្តង។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ នៅមន្ត្រីនគរបាលយុត្តិធម៌ថា: ខ្លួន ធ្លាប់ប្រើប្រាស់ថ្នាំញៀនបានម្តងកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។ ខ្លួន បានមកធ្វើជាជាងផ្សារជាមួយនឹងបងថ្លៃឈ្មោះ ឆក នៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានមួយថ្ងៃ ហើយពេលល្ងាច បងថ្លៃឈ្មោះ ឆក បានយកថ្នាំញៀនឱ្យខ្លួនជក់។ ទន្ទឹមនឹងនេះដែរ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ បងថ្លៃរបស់ខ្លួនឈ្មោះ ឆក បាននាំខ្លួនមកផ្ទះនៅដែកកោង ស្រាប់តែសមត្ថកិច្ចបានមកដល់ក៏បានធ្វើការឃាត់ខ្លួនតែម្តង។



Scanned with CamScanner

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ: ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿង បញ្ជាក់ថា សំណាកទីមួយជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន (Methamphetamine) (ហៅក្រៅភាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៦.៤៥ ភាគរយនៃទម្ងន់សរុប ភស្តុតាងនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ: ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿង បញ្ជាក់ថា សំណាកទីពីរជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន (Methamphetamine) (ហៅក្រៅភាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ១៣.៦០ ភាគរយនៃទម្ងន់សរុប ភស្តុតាងនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ ស៊ីមវិសុទ្ធ ថាថ្ងៃកើតហេតុពិតជាបានយកថ្នាំញៀនឲ្យគេ។ ចំណែកជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ជាអ្នកចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូច្នេះតំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទុកដដែល សូមក្រុមប្រឹក្សាផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-លោក ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំង០៣នាក់ ធ្វើសេចក្តីសន្និដ្ឋានថា: តាមចម្លើយរបស់ជនជាប់ចោទឃើញថា ជនជាប់ចោទបានសារភាពទោសកំហុស ស្នើសុំតុលាការបន្ធូរបន្ថយទោស ។

ជនជាប់ចោទឈ្មោះ និយាយសំដីចុងក្រោយថា៖ អត់មានសំណូមពរ។

ជនជាប់ចោទឈ្មោះ និយាយសំដីចុងក្រោយថា៖ អត់មានសំណូមពរ។

ជនជាប់ចោទឈ្មោះ និយាយសំដីចុងក្រោយថា៖ ស្នើសុំបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទទាំងបីនាក់

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងបីនាក់

-ជនជាប់ចោទនិយាយសំដីចុងក្រោយរបស់ជនជាប់ចោទទាំងបីនាក់

-ក្រោយពីបានពិនិត្យ ឯកសារ និងភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ ដែលមានជនជាប់ឈ្មោះ ភេទប្រុស អាយុ២៨ ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវ



Scanned with CamScanner

សារធាតុញៀន ។ ចំណែកជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរនិងជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ ពីបទ ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៣.៣/១៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទ យោងតាមមាត្រា២៨៩, ២៩១ និងមាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២. ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច, ចម្លើយសារភាពរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាល ព្រមទាំងភស្តុតាងនានា ឃើញថា ជនជាប់ចោទឈ្មោះ ពិតជាបានជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។ ជនជាប់ចោទឈ្មោះ បានទិញគ្រឿងញៀនពីបងម្នាក់មិនស្គាល់អត្តសញ្ញាណបានចំនួនបីលើកមកហើយ ដោយលើកទីមួយ ជនជាប់ចោទបានទិញចំនួន៣០០ ដុល្លារអាមេរិក និងបានផ្ញើលុយតាមវីង ហើយជនជាប់ចោទបានយកទៅលក់បន្តដោយចំណេញក្នុងមួយកញ្ចប់១០ ទៅ២០ ដុល្លារអាមេរិក។ លើកទីពីរ ជនជាប់ចោទគុម្ម៉ង់ទិញចំនួន៥ កញ្ចប់ តម្លៃ៣០០ ដុល្លារអាមេរិក ជនជាប់ចោទបានផ្ញើលុយតាមវីង និងបានទៅយកថ្នាំញៀននោះនៅបង្គោលលេខ២១៦ ពេលជនជាប់ចោទបានយកថ្នាំញៀននោះទៅលក់ក្នុងមួយកញ្ចប់ចំណេញបាន១០ ទៅ២០ ដុល្លារអាមេរិក។ លើកទីបី ជនជាប់ចោទបានគុម្ម៉ង់ចំនួន១០ កញ្ចប់ ក្នុងតម្លៃ៣០០ ដុល្លារអាមេរិក និងបានធ្វើការលក់ដូររាល់ដងដែរ។ លុះដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោងប្រហែលដប់បី និងម្ភៃនាទី ជនជាប់ចោទកំពុងជក់ថ្នាំញៀន ហើយសមត្ថកិច្ចបានមកដល់បានធ្វើការឃាត់ខ្លួន និងធ្វើការដកហូតថ្នាំញៀនចំនួនបីកញ្ចប់តែម្តង។ អំពើរបស់ជនជាប់ចោទឈ្មោះ គឺជាអង្គហេតុត្រូវនឹងបទល្មើស ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច, ចម្លើយសារភាពរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាល ព្រមទាំងភស្តុតាងនានា ឃើញថា ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ចេះប្រើប្រាស់ថ្នាំញៀន និងបានចាត់ចែងឱ្យប្រើប្រាស់ថ្នាំញៀន នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ស្រាប់តែសមត្ថកិច្ចបានមកដល់ និងបានធ្វើការឃាត់ខ្លួនតែម្តង ។ អំពើរបស់ជនជាប់ចោទឈ្មោះ ដា ធម្មី ហៅ តឹប និងជនជាប់ចោទឈ្មោះ គឺជាអង្គហេតុត្រូវនឹងបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤. តាមកំណត់ហេតុស្តីពីការបើកបិទកញ្ចប់ និងដកហូតសំណាកដែលសង្ស័យថាជាថ្នាំញៀន ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ឃើញមានក្រាមសុទ្ធទម្ងន់ ៥,៦៤ ក្រាម។ រីឯ លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ: ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បញ្ជាក់ថាជាសារធាតុញៀនប្រភេទម្សៅឈ្មោះ មេតំហ្វេតាមីន (Methamphetamine) មានកម្រិតភាពសុទ្ធ ៧៦.៤៥ ភាគរយ គឺ



Scanned with CamScanner

CS Scanned with CamScanner

=៥,៦៤×៧៦.៤៥=៤.៤៤ ក្រាម ចំណុចនេះបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។
១០០

៥. តាមកំណត់ហេតុស្ដីពីការបើកបិទកញ្ចប់ និងដកហូតសំណាកដែលសង្ស័យថាជាថ្នាំញៀន ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ឃើញមានក្រាមសុទ្ធទម្ងន់ ៥.៦៤ ក្រាម។ រីឯ លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ: ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បញ្ជាក់ថាជាសារធាតុញៀនប្រភេទគ្រាប់ឈ្មោះ មេតំហ្វេតាមីន (Methamphetamine) មានកម្រិតភាពសុទ្ធ ១៣.៦០ ភាគរយ គឺ=
៣,៨២×១៣.៦០=០,៥១ ក្រាម ចំណុចនេះបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។
១០០

៦. ជនជាប់ចោទឈ្មោះ , ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៧. សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់ជនជាប់ចោទឈ្មោះ ពីបទ: ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។ ចំណែកជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ពីបទ: ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយសុតម្កលបទចោទប្រកាន់នេះទុកដដែលនោះគឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៨. មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ , ពីបទ: ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៩. មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ . និងជនជាប់ចោទឈ្មោះ ពីបទ: ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៤២, ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១០. អំពើដែលជនជាប់ចោទឈ្មោះ . ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ បានប្រព្រឹត្តបានធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ។ រីឯជនជាប់ចោទឈ្មោះ ជាអនីតិជន ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទនីមួយៗ តុលាការនឹងពិនិត្យពិចារណា។

១១.កំណត់ហេតុទទួលវត្ថុតាងរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះសីហនុលេខ: វ.ត/ ១៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ដែលដកហូតពីជនជាប់ចោទមាន: ម្សៅសថ្លាមេតំហ្វេតាមីនចំនួន៥,៩៤ ក្រាម, ថ្នាំញៀនប្រភេទ WY ចំនួន៣៨ គ្រាប់ មានទម្ងន់៣,៨២ ក្រាម ជាវត្ថុខុសច្បាប់គប្បីរឹបអូស ។ រីឯទូរស័ព្ទចំនួន ០៤ គ្រឿង ជាមធ្យោបាយទាក់ទងនិងអំពើល្មើស គប្បីរឹបអូស ។



Scanned with CamScanner

## សេចក្តីសម្រេច

១. ផ្តន្ទាទោសឈ្មោះ ភេទប្រុស អាយុ២៨ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល២ (ពីរ) ឆ្នាំ និង ៦ (ប្រាំមួយ) ខែ ពីបទ: ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ផ្តន្ទាទោសឈ្មោះ ភេទប្រុស អាយុ២៥ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល២ (ពីរ) ឆ្នាំ ពីបទ: ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ តាមមាត្រា៤២, ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. ផ្តន្ទាទោសឈ្មោះ ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល១ (មួយ) ឆ្នាំ ពីបទ: ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ តាមមាត្រា៤២, ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៤. រឹបអូសវត្ថុចាប់យក តាមកំណត់ហេតុទទួលវត្ថុតាងរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះសីហនុលេខ: ; ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ មាន: ម្សៅសថ្នាំមេតំហ្វេតាមីនចំនួន៥,៩៤ ក្រាម, ថ្នាំញៀនប្រភេទ WY ចំនួន៣៨ គ្រាប់ មានទម្ងន់៣,៨២ ក្រាម និងទូរស័ព្ទចំនួន០៤ គ្រឿង។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ និងលើកទីពីរ នៅថ្ងៃ១៦ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ ជនជាប់ចោទឈ្មោះ ; និងជនជាប់ចោទឈ្មោះ ។ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា ស | | | ហត្ថលេខា និងត្រា |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខេត្តព្រះសីហនុ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩

ក្រឡាបញ្ជីសវនាការ

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ



Scanned with CamScanner